ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

Ministry of Commerce

# របាយការណ៍

## បូកសរុបការងារពាណិជ្ជកម្មឆ្នាំ ២០០៩
## និង
## ទិសដៅការងារពាណិជ្ជកម្មឆ្នាំ ២០១០



# ថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្ម



## ឯកឧត្តម ចម ប្រសិទ្ធ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម



ឯកឧត្តម ឈួន ដារ៉ា
រដ្ឋលេខាធិការ



ឯកឧត្តម ម៉ា ខាង
រដ្ឋលេខាធិការ



ឯកឧត្តម កែវ សុខណៃ
រដ្ឋលេខាធិការ



ឯកឧត្តម ឡិក ប៊ុំ
រដ្ឋលេខាធិការ



ឯកឧត្តម គឹម ស៊ីថន
រដ្ឋលេខាធិការ



ឯកឧត្តម ប៉ាន សូរស័ក្តិ
រដ្ឋលេខាធិការ



ឯកឧត្តម ច័ន្ទ ណារ៉ា
រដ្ឋលេខាធិការ



ឯកឧត្តម ម៉ៅ ថូរ៉ា
រដ្ឋលេខាធិការ



ឯកឧត្តម ឱត ធីណា
អនុរដ្ឋលេខាធិការ



ឯកឧត្តម ភាន ច័ន្ទមេត្តា
អនុរដ្ឋលេខាធិការ



ឯកឧត្តម តាន់ ស៊ីនតូ
អនុរដ្ឋលេខាធិការ



ឯកឧត្តម ហុ សារ៉ាន់
អនុរដ្ឋលេខាធិការ



ឯកឧត្តម សុខ រុន
អនុរដ្ឋលេខាធិការ



ឯកឧត្តម ឯម សុគន្ធ
អនុរដ្ឋលេខាធិការ



ឯកឧត្តម ទេព សុធី
អនុរដ្ឋលេខាធិការ



លោកជំទាវ គឹមកេត កំរេង
អនុរដ្ឋលេខាធិការ

# មាតិកា

## របាយការណ៍បូកសរុបការងារពាណិជ្ជកម្ម ឆ្នាំ ២០០៩
## និងទិសដៅការងារពាណិជ្ជកម្ម ឆ្នាំ ២០១០


**I-កំណែទម្រង់ដើម្បីជំរុញអភិបាលកិច្ចល្អ** ទំព័រ ២

១-ការងាររដ្ឋបាល និងគ្រប់គ្រងធនធានមនុស្ស ទំព័រ ២

២-ការងារហិរញ្ញវត្ថុ ទំព័រ ៥

៣-ការងារសវនកម្ម និងអធិការកិច្ច ទំព័រ ៥

**II-សកម្មភាពពាណិជ្ជកម្មដើម្បីចូលរួមអនុវត្តយុទ្ធសាស្ត្រចតុកោណ** ទំព័រ ៦

១-ការអនុវត្តន៍យុទ្ធសាស្ត្រអភិក្រមគ្របដណ្តប់ទូទាំងវិស័យពាណិជ្ជកម្ម ( **Trade SWAp** ) ទំព័រ ៦

២-ការងារគ្រប់គ្រងជំនួយបច្ចេកទេស ទំព័រ ៧

***២.១-កម្មវិធីគាំទ្រការអភិវឌ្ឍន៍ពាណិជ្ជកម្ម (TDSP) :*** ទំព័រ ៧

***២.២- គម្រោងសមាហរណកម្មពាណិជ្ជកម្ម (EIF)*** ទំព័រ ៧

***២.៣- គម្រោងជំនួយបច្ចេកទេសផ្សេងៗទៀត*** ទំព័រ ៧

៣-ការបម្រើសេវាសាធារណៈ ទំព័រ ៧

*៣.១-ការចុះបញ្ជីពាណិជ្ជសញ្ញា និងការផ្តល់សេវាដែលពាក់ព័ន្ធ* ទំព័រ ៨

*៣.២-ការចុះបញ្ជីពាណិជ្ជកម្ម និងការផ្តល់សេវាដែលពាក់ព័ន្ធ* ទំព័រ ១០

*៣.៣-ការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម* ទំព័រ ១៣

*៣.៤-ការចុះបញ្ជីផ្តល់សិទ្ធិនាំចេញក្រោមប្រព័ន្ធអនុគ្រោះពន្ធ* ទំព័រ ១៣

*៣.៥-ការផ្តល់វិញ្ញាបនប័ត្រប្រភពដើមទំនិញ និងអាជ្ញាប័ណ្ណផ្សេងៗ* ទំព័រ ១៤

*៣.៦-សេវាពង្រឹងសុវត្ថិភាព គុណភាពទំនិញ និងការការពារអ្នកប្រើប្រាស់* ទំព័រ ១៧

*៣.៧-សកម្មភាពជំរុញពាណិជ្ជកម្ម* ទំព័រ ២៣

៤-សមិទ្ធកម្មសេដ្ឋកិច្ច និងទំហំពាណិជ្ជកម្មនាំចេញ-នាំចូល ទំព័រ ២៥

៥-សកម្មភាពបម្រើឱ្យសមាហរណកម្មកម្ពុជាក្នុងតំបន់ និងពិភពលោក ទំព័រ ២៨

*៥.១-សមាហរណកម្មតំបន់ និងអនុតំបន់* ទំព័រ ២៨

*៥.២-ការចរចាបង្កើតតំបន់ពាណិជ្ជកម្មសេរីជាមួយប្រទេសដៃគូអាស៊ាន* ទំព័រ ២៩

*៥.៣-កិច្ចការសហប្រតិបត្តិការអនុតំបន់* ទំព័រ ៣០

*៥.៤-សមាហរណកម្មពិភពលោក* ទំព័រ ៣៣

៦-សកម្មភាពកសាង និងផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ ទំព័រ ៣៥

*៦.១-ការកសាងច្បាប់ និងបញ្ញត្តិផ្សេងៗ* ទំព័រ ៣៥

*៦.២-ការងារតម្កល់លិខិតជូនដំណឹងប្រតិបត្តិការដែលមានកិច្ចធានា* ទំព័រ ៣៧

*៦.៣-ការងារបង្កើតមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម* ទំព័រ ៣៧

*៦.៤-ការងារផ្សព្វផ្សាយច្បាប់* ទំព័រ ៣៨

៧-ការងារក្របខ័ណ្ឌលេខាធិការដ្ឋាននៃគណៈកម្មការគ្រប់គ្រងផ្នែកទាំង៣ *នៃកម្មសិទ្ធិបញ្ញា* ទំព័រ ៣៩

*៧.១-ការងារផ្សព្វផ្សាយ និង សហប្រតិបត្តិការអន្តរជាតិ ផ្នែកកម្មសិទ្ធិបញ្ញា* ទំព័រ ៤0

*៧.២-ការងារសហប្រតិបត្តិការអន្តរជាតិខាងវិស័យកម្មសិទ្ធិកម្មសិទ្ធិបញ្ញា* ទំព័រ ៤0

*៧.៣-សហប្រតិបត្តិការគម្រោងរៀបចំច្បាប់ ស្តីពីការសំគាល់ភូមិសាស្ត្រទំនិញ* ទំព័រ ៤0

*៧.៤-ការងារបោះពុម្ពផ្សាយព្រឹត្តិប័ត្រផ្លូវការ* ទំព័រ ៤១

*៧.៥-គម្រោងកម្មសិទ្ធិបញ្ញា ៣៩ សកម្មភាព*(Pillar 1) ទំព័រ ៤១

*៧.៦-សហប្រតិបត្តិការគម្រោង*ECAP III ទំព័រ ៤១

*៧.៧-គម្រោងបង្កើនសមត្ថភាពកម្មសិទ្ធិបញ្ញា និងការអភិវឌ្ឍន៍ចីរភាព* ទំព័រ ៤១

*៧.៨-សហប្រតិបត្តិការកិច្ចព្រមព្រៀងក្របខ័ណ្ឌពាណិជ្ជកម្ម និងវិនិយោគ*(TIFA) *និង កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី* ទំព័រ ៤២

*៧.៩-ក្រុមការងារអាស៊ាន ស្តីពីកិច្ចសហប្រតិបត្តិការកម្មសិទ្ធិបញ្ញា*AWGIPC ទំព័រ ៤២

*៧.១០-កិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុន*Microsoft ទំព័រ ៤២

*៧.១១-គម្រោងបង្កើតអនុគណៈកម្មាធិការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា* ទំព័រ ៤២

*៧.១២-សេចក្តីពន្យល់នៃវិធាន សំរាប់អនុវត្តមាត្រា ១១ និង មាត្រា ១៣ នៃអនុសញ្ញាស្តីពីការត្រួតពិនិត្យថ្នាំជក់ ក្របខ័ណ្ឌអង្គការសុខភាពពិភពលោក* ទំព័រ ៤៣

៨-ការធានាសន្តិសុខស្បៀង ទំព័រ ៤៣

**III-ទិសដៅអនុវត្តការងារឆ្នាំបន្ត** ទំព័រ ៤៤

**IV-សេចក្តីសន្និដ្ឋាន** ទំព័រ ៥១

# របាយការណ៍

## បូកសរុបការងារពាណិជ្ជកម្ម ឆ្នាំ ២០០៩

## និង

## ទិសដៅការងារពាណិជ្ជកម្ម ឆ្នាំ ២០១០

ផ្ដើមចេញពីលទ្ធផល និងជោគជ័យដ៏ច្រះត្រចង់នៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ ដែលរាជរដ្ឋាភិបាលកម្ពុជាអាណត្តិមុនបានដាក់ចេញអោយអនុវត្ត ក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានក្លាយទៅជាមេរៀន និងបទពិសោធន៍ដ៏មានសារៈសំខាន់ ដែលមជ្ឈដ្ឋានជាតិ និងអន្តរជាតិសុទ្ធតែបានវាយតម្លៃថា សមិទ្ធិផលសង្គមជាតិលើគ្រប់វិស័យបានកើតមានឡើង និងរីកចម្រើនយ៉ាងឆាប់រហ័ស ឆ្លើយតបតាមបំណងប្រាថ្នារបស់ប្រជាពលរដ្ឋកម្ពុជានៅគ្រប់ទិសទី នាំមកវិញនូវការគាំទ្រយ៉ាងពេញទំហឹងពីប្រជាពលរដ្ឋទៅលើការដឹកនាំរបស់រាជរដ្ឋាភិបាល ដែលតថភាពនេះ បានបង្ហាញឡើងតាមរយៈលទ្ធផលបោះឆ្នោតសាកលជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៤កាលពី ខែកក្កដា ឆ្នាំ២០០៨ កន្លងទៅ។ ហេតុដូច្នេះហើយ បានជារាជរដ្ឋាភិបាលកម្ពុជាសម្រេចដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២បន្តទៀត នៅក្នុងអាណត្តិទី៤នៃរដ្ឋសភា ដើម្បីនាំមកនូវការអភិវឌ្ឍន៍ វិបុលភាព សន្តិភាព និងភាពសុខដុមរមនា ជូនប្រជាពលរដ្ឋយើង។

ឆ្នាំ២០០៩នៃដើមអាណត្តិទី៤នេះ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងពាណិជ្ជកម្ម បានធ្វើពលិកម្មគ្រប់បែបយ៉ាងរួមចំណែកអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២របស់រាជរដ្ឋាភិបាលឱ្យទទួលបានផ្លែផ្កា និងជោគជ័យច្រះត្រចង់ ទៅតាមទិសដៅដែលបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្ររបស់ក្រសួងសម្រាប់រយៈពេល ៥ឆ្នាំ (២០០៩-២០១៣) ជំរុញឱ្យឆ្នាំទី១នេះ ចាប់ផ្ដើមដោយសន្ទុះទៅមុខ និងគេចផុតពីវិបត្តិធ្ងន់ធ្ងរ សម្រាប់ជាគ្រឹះដល់ការអនុវត្តភារកិច្ចជំនាញគ្រប់វិស័យនៅឆ្នាំបន្តបន្ទាប់ទៀត។ ប៉ុន្តែ ទន្ទឹមនឹងការចាប់ផ្ដើមអាណត្តិថ្មីរបស់ខ្លួន រលកនៃវិបត្តិសេដ្ឋកិច្ចសកល ក៏បានចូលមកញាំញីដល់សេដ្ឋកិច្ចកម្ពុជាផងដែរ ជាហេតុធ្វើឱ្យរាំងដល់កិច្ចប្រឹងប្រែងរបស់យើងក្នុងការសម្រេចនូវកំណើនសេដ្ឋកិច្ចដែលបានរំពឹងទុក។ ដោយស្មារតីទទួលខុសត្រូវខ្ពស់ ក្រសួងពាណិជ្ជកម្មរួមសហការជាមួយក្រសួង ស្ថាប័នដែលពាក់ព័ន្ធ បានព្យាយាមដោះស្រាយនូវបញ្ហាធំៗជូនជាតិជាច្រើន ដើម្បីកាត់បន្ថយហានិភ័យ និងការគំរាមកំហែងគ្រប់បែបយ៉ាងដែលបង្កឡើងដោយសារវិបត្តិកលិយុគនៃសេដ្ឋកិច្ចសកលនោះ សំដៅធ្វើយ៉ាងណារក្សាឱ្យនៅក្នុងកម្រិតតិចអាចគ្រប់គ្រងបាន ឬមួយបញ្ចៀសឱ្យបាននូវបច្ច័យដែលអាចនាំខូចខាតដល់ម៉ាក្រូ និងមីក្រូសេដ្ឋកិច្ច រក្សាបាននូវស្ថេរភាពសង្គម និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ តាមរយៈការធ្វើឱ្យសម្រេចបាននូវស្នាដៃធំៗថែមទៀត។

លទ្ធផលការងារលេចធ្លោសំខាន់ៗដែលក្រសួងពាណិជ្ជកម្មអនុវត្តសម្រេចបានក្នុងឆ្នាំ២០០៩ កន្លងមកនេះ រួមមាន សមិទ្ធិផល និងស្នាដៃនៅតាមបណ្ដាផ្នែក និងវិស័យការងារដូចខាងក្រោម:

## I-កំណែទម្រង់ដើម្បីជំរុញអភិបាលកិច្ចល្អ

### ១-ការងាររដ្ឋបាល និងគ្រប់គ្រងធនធានមនុស្ស

#### *ក-ការងាររដ្ឋបាល*

ការងាររដ្ឋបាល គឺជាកិច្ចការសម្របសម្រួល និងទ្រទ្រង់ដល់ដំណើរប្រព្រឹត្តទៅនៃសកម្មភាពការងារទូទៅរបស់ក្រសួង និងបណ្តាអង្គភាពក្រោមឱវាទ។ ការងារចម្បងជាងគេគឺ ការអនុវត្តផែនការថវិកាសម្រាប់ដោះស្រាយសេចក្តីត្រូវការខាងផ្នែកសម្ភារៈ ឬថវិកា ជូនដល់គ្រប់អង្គភាព គ្រប់ផ្នែករបស់ក្រសួង ដើម្បីមានលទ្ធភាពបំពេញនូវតួនាទី និងធ្វើប្រតិបត្តិការប្រចាំថ្ងៃ ការគ្រប់គ្រងប្រកបដោយសុវត្ថិភាពទ្រព្យសម្បត្តិរបស់ក្រសួង ទាំងចលនៈវត្ថុ អចលនៈវត្ថុ និងឯកសារមានតម្លៃគ្រប់ប្រភេទ។ នៅក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ នៅមានចំណុចដែលគួរឱ្យកត់សំគាល់មួយទៀតគឺ ការបញ្ចប់ទាំងស្រុងសំណុំរឿងក្តីដែលក្រសួងបានដាក់ពាក្យបណ្តឹងទាមទារការកាន់កាប់អចលនៈវត្ថុជាដី ឃ្លាំង និងអគារអតីតក្រុមហ៊ុនកាំប៊ិចស៊ីមពីបុគ្គលឯកជនដែលជាអ្នកមានធនធានគួរសមមួយរូប ដោយតុលាការកំពូលបានសម្រេចចេញសាលដីកាឱ្យក្រសួងពាណិជ្ជកម្មឈ្នះក្តីប្រកបដោយគតិយុត្តិធម៌ ផ្តល់ផលប្រយោជន៍ដល់ក្រសួងក្នុងការចាត់ចែងប្រើប្រាស់ អគារ ឃ្លាំង និងដីនោះ សម្រាប់រៀបចំទីកន្លែងធ្វើការជូនអង្គភាពនានាតាមតម្រូវការ។

-បញ្ជូនលិខិតចេញទៅតាមក្រសួង-ស្ថាប័នពាក់ព័ន្ធនានា នូវលិខិតចំនួន ៤,៩០៨ ក្នុងនោះមាន លិខិតធម្មតាចំនួន ៣,៧៩៣ ប្រកាសរបស់ក្រសួងចំនួន ២៧៧ លិខិតបេសកកម្មចំនួន ៥៧៧ លិខិតអញ្ជើញចំនួន ២៣៦លើក និងដីកាអមចំនួន ២៥។ ក្រៅពីនោះ បានយកចិត្តទុកដាក់បម្រើរាល់ពិធីការផ្សេងៗសម្រាប់រាល់ដំណើរការរៀបចំកិច្ចប្រជុំ និងសិក្ខាសាលា ចំនួន ១១៩ លើក និងចាត់ចែងទទួលគណៈប្រតិភូជាតិ និងអន្តរជាតិ ចំនួន ២១លើក ដោយធានាបានសុវត្ថិភាព និងរបៀបរៀបរយល្អ។

#### ខ-ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស

ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្សគឺជាកិច្ចការដែលមានសារៈសំខាន់ ទ្រទ្រង់ដល់គ្រប់យន្តការទាំងអស់ឱ្យមានពលានុភាព ជំរុញការអនុវត្តនីគោលដៅជាយុទ្ធសាស្ត្រដែលក្រសួងបានកំណត់ ឆ្ពោះទៅសម្រេចភារកិច្ចដែលរាជរដ្ឋាភិបាលប្រគល់ឱ្យ។ ក្រសួងពាណិជ្ជកម្មយល់ច្បាស់នូវសារៈសំខាន់នេះ ហើយបានយកចិត្តទុកដាក់ដល់ការរៀបចំ ចាត់ចែងធនធានមនុស្សឱ្យសមស្របតាមរចនាសម្ព័ន្ធនៃបណ្តានាយកដ្ឋាន អង្គភាពជំនាញក្រោមឱវាទ គិតគូរជាអាទិភាពដល់ការបណ្តុះបណ្តាលមន្ត្រីរាជការ បង្កើនសមត្ថភាពមន្ត្រី និងពង្រឹងសមត្ថភាពស្ថាប័ន។

#### *ខ.១-ការងារគ្រប់គ្រងធនធានមនុស្ស*

ឆ្នាំ ២០០៩ នេះ ការគ្រប់គ្រងមន្ត្រីរាជការ ត្រូវបានប្រកាន់យកទៅតាមវិធានដែលរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចុះ ដោយបានអនុវត្តកិច្ចការសំខាន់ៗមួយចំនួនដូចជា : ការធ្វើបច្ចុប្បន្នភាពទិន្នន័យមន្ត្រីរាជការ ការធ្វើប័ណ្ណព័ត៌មាន និងការចងក្រងសំណុំឯកសារ និងជីវប្រវត្តិមន្ត្រីរាជការ ការត្រៀមរៀបចំធ្វើអត្តសញ្ញាណប័ណ្ណមន្ត្រីរាជការតាមគំរូថ្មី សម្រាប់ការគ្រប់គ្រងតាមប្រព័ន្ធព័ត៌មានវិទ្យា ដែលផ្តល់លទ្ធភាពដល់ការត្រួតពិនិត្យហ្មត់ចត់ និងធានាដល់ភាពប្រាកដប្រជានូវបរិមាណមន្ត្រីរាជការតាមអង្គភាពនីមួយៗ ដើម្បីរួមចំណែកកាត់បន្ថយការចំណាយលើបន្ទុកបុគ្គលិក

ខុសពីគោលដៅ បង្កើនប្រសិទ្ធភាព និងការទទួលខុសត្រូវរបស់មន្ត្រីរាជការ-អង្គភាព ដោយបានដាក់ចេញសេចក្តីណែនាំ លេខ ៣៤០៦ ពណ.បល ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០៩ ឆ្លើយតបទៅតាមការណែនាំរបស់រាជរដ្ឋាភិបាល ។

-បានសហការជាមួយគណៈកម្មាធិការត្រួតពិនិត្យលិខិតបទដ្ឋានគតិយុត្តិរបស់រាជរដ្ឋាភិបាល ជំរុញការដាក់មន្ត្រីរាជការដែលដល់ ឬហួសកាលកំណត់អាយុចូលនិវត្តន៍ ឱ្យចូលនិវត្តន៍ទាំងអស់ក្នុងឆ្នាំនេះ ហើយចាប់ពីខែមករា ឆ្នាំ ២០១០ តទៅ បែបបទចូលនិវត្តន៍ក៏នឹងត្រូវអនុវត្តឱ្យទាន់ពេលវេលាក្នុងខែនីមួយៗតែម្តង ។ សរុបចំនួនមន្ត្រីរាជការដែលត្រូវបានដាក់ឱ្យចូលនិវត្តន៍ក្នុងឆ្នាំ ២០០៩ នេះ មានចំនួន **៦៤**នាក់ នៅថ្នាក់កណ្តាល **២៥**នាក់ នៅថ្នាក់រាជធានី-ខេត្ត ចំនួន **៣៩**នាក់ ក្នុងនេះ ការដាក់ឱ្យចូលនិវត្តដោយការកាត់តម្រឹមឡើងវិញ តាមគោលការណ៍របស់រាជរដ្ឋាភិបាល មានចំនួន ៥នាក់។ ប៉ុន្តែ ចំណុចដែលនៅតែជាការលំបាកនោះគឺ នៅបណ្តាឆ្នាំខាងមុខមន្ត្រីរាជការនឹងបន្តចូលនិវត្តន៍ថែមទៀត ក្នុងពេលដែលការជ្រើសរើសថ្មីអំឡុងឆ្នាំ ២០១០នេះ ត្រូវបានផ្អាកមួយរយៈសិននោះ ធ្វើឱ្យស្ថានភាពមន្ត្រីរាជការ ពិតជាជៀសមិនរួចពីភាពខ្វះចន្លោះក្នុងការចាត់ចែងអនុវត្តភារកិច្ចទៅតាមរចនាសម្ព័ន្ធនៃអង្គភាពចំណុះនីមួយៗនោះឡើយ ។

-គិតមកដល់បំណាច់ឆ្នាំ២០០៩ ក្របខ័ណ្ឌមន្ត្រីរាជការសរុប មានចំនួន **១,៦៦២** នាក់ ស្រី **៤៥៦**នាក់ ក្នុងនោះ :

+នៅថ្នាក់រដ្ឋបាលកណ្តាល មានចំនួន **១,១២៨** នាក់ ស្រី **២៧២** នាក់ ចែកចេញជា :

- ក្របខ័ណ្ឌជាក់ស្តែង មានចំនួន ១,០៧៧នាក់
- ស្ថានតំណាងពាណិជ្ជកម្ម មានចំនួន ១១នាក់
- ដាក់ឱ្យស្ថិតនៅក្រៅក្របខ័ណ្ឌដើម មានចំនួន ៨នាក់ (រដ្ឋបាលកណ្តាល៣នាក់)
- ស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស មានចំនួន ១៥នាក់ (រដ្ឋបាលកណ្តាល១៤នាក់)
- មន្ត្រីថ្មីមិនទាន់មានសលាកប័ត្រ-ស្នាមមេដៃ មានចំនួន ៩៣នាក់ (រដ្ឋបាលកណ្តាល ២៣នាក់)

+ និងថ្នាក់រាជធានី-ខេត្ត មានចំនួន**៥៣៤** នាក់ ស្រី **១៨៤** នាក់

តាមការគិតគូរនៅចុងឆ្នាំ២០១០ ក្របខ័ណ្ឌមន្ត្រីរាជការអាចនឹងនៅសល់ត្រឹមចំនួននាក់ **១,៦០០** នាក់។ មិនតែប៉ុណ្ណោះ ក្រសួងបានធ្វើការកាត់បន្ថយចំនួនបុគ្គលិកជាប់កិច្ចសន្យា និងពលករអណ្តែត សម្រាប់ការប្រើប្រាស់ក្នុងឆ្នាំ២០១០ឱ្យនៅត្រឹមចំនួន ៥០%នៃឆ្នាំ២០០៩ប៉ុណ្ណោះ ទៅតាមគោលការណ៍របស់រាជរដ្ឋាភិបាល ពោលគឺ បុគ្គលិកជាប់កិច្ចសន្យារក្សាទុកក្នុងចំនួន **៦៦**នាក់ (រដ្ឋបាលកណ្តាល ៤៣នាក់) និងពលករអណ្តែតចំនួន **៦៥** នាក់ (រដ្ឋបាលកណ្តាល ៤៤នាក់) ។ ចំពេលដែលយើងកំពុងពើបប្រទះកង្វះខាតបរិមាណមន្ត្រីរាជការបែបនេះ បញ្ហាគុណភាព និងវិន័យការងារមន្ត្រីរាជការ គឺជាបញ្ហាសំខាន់ដែលត្រូវបានពង្រឹងបន្ថែម តាមរយៈការបង្កើតយន្តការដែលមានបេសកកម្មចុះត្រួតពិនិត្យនូវចំនួនមន្ត្រីដែលត្រូវមកបំពេញការងារជាក់ស្តែង ព្រមជាមួយនឹងការពង្រឹងរបៀបរបបធ្វើការងារ ការកំណត់បែងចែកភារកិច្ចទទួលខុសត្រូវដល់មន្ត្រីម្នាក់ៗទៅតាមឋានានុក្រម និងតាមរចនាសម្ព័ន្ធ។

-ក្នុងគោលបំណងពង្រឹងភាពដឹកនាំ លើកកំពស់ស្មារតីទទួលខុសត្រូវ ក្រសួងបានបំពេញបន្ថែមសមាសភាពថ្នាក់ដឹកនាំក្រសួង និង សម្រេចរៀបចំកែសម្រួលភារកិច្ច តែងតាំង ប្រគល់ភារកិច្ចជូនមន្ត្រីរាជការតាម

លំដាប់ថ្នាក់ ចំនួន **១១១** នាក់ ក្នុងនោះ :

+ថ្នាក់រដ្ឋលេខាធិការ ចំនួន ០១នាក់

+ថ្នាក់អនុរដ្ឋលេខាធិការ ចំនួន ០១នាក់

+ថ្នាក់អគ្គនាយករង ចំនួន ៤នាក់

+ថ្នាក់ប្រធាននាយកដ្ឋាន ចំនួន ៦នាក់

+ថ្នាក់អនុប្រធាននាយកដ្ឋាន និង ប្រធានមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ចំនួន ២១នាក់

+ថ្នាក់ប្រធានការិយាល័យរដ្ឋបាលកណ្តាល និង អនុប្រធានមន្ទីររាជធានី-ខេត្ត ចំនួន ២០នាក់

+ថ្នាក់អនុប្រធានការិយាល័យរដ្ឋបាលកណ្តាល និងប្រធានការិយាល័យរាជធានី-ខេត្ត ចំនួន ៤២នាក់

+ថ្នាក់អនុប្រធានការិ.រាជធានី-ខេត្ត ប្រធាន-អនុប្រធានការិ.ស្រុក-ក្រុង-ខណ្ឌ ចំនួន ១៤នាក់

ក្រៅពីនេះ បានចាត់តាំងមន្ត្រីឱ្យចូលរួមក្នុងគណៈកម្មការ អនុគណៈកម្មការ ក្រុមការងារ និងយន្តការផ្សេងៗរបស់ក្រសួង ឬជាអន្តរក្រសួង ចំនួន ២២យន្តការ ព្រមទាំងចាត់ឱ្យចូលរួមពិធីផ្សេងៗរបស់រាជរដ្ឋាភិបាលជាច្រើនលើក ដើម្បីចូលរួមចែករំលែកចំណេះដឹង ធនធានសម្ភារៈ ថវិកា បម្រើដល់កិច្ចអភិវឌ្ឍសេដ្ឋកិច្ចសង្គម ។

### *ខ.២-ការងារអភិវឌ្ឍន៍ធនធានមនុស្ស*

ដោយយល់ឃើញថា ធនធានមនុស្សជាកត្តាស្នូលសម្រាប់ការពង្រឹង និងអភិវឌ្ឍស្ថាប័ន ក្រសួងពាណិជ្ជកម្ម នៅតែយកចិត្តទុកដាក់ជាអាទិភាពដល់ការអភិវឌ្ឍន៍ធនធានមនុស្ស ដោយផ្តល់លទ្ធភាព និងបង្កឱកាសដល់មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ទទួលបាននូវការបណ្តុះបណ្តាលរយៈពេលខ្លី-វែង ទាំងក្នុង និងក្រៅប្រទេស ក្រោមរូបភាពជាវគ្គសិក្សា វគ្គសិក្ខាសាលា វេទិកា កិច្ចប្រជុំផ្សេងៗ ជាច្រើនប្រធានបទ និងមុខជំនាញ ដូចជា: ការងារ WTO ការងារក្នុងក្របខ័ណ្ឌអាស៊ាន ការងារពាណិជ្ជកម្មអន្តរជាតិ ការងារវិនិយោគ និងគោលនយោបាយសេដ្ឋកិច្ច-ពាណិជ្ជកម្ម ច្បាប់ ការងារគ្រប់គ្រង និងដឹកនាំស្ថាប័ន កំណែទម្រង់រដ្ឋបាល កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការងារអភិបាលកិច្ច ការងារកម្មសិទ្ធិបញ្ញា ជំនាញភាសាអង់គ្លេស កុំព្យូទ័រ ។ល។ លើសពីនេះ តាមរយៈវគ្គបណ្តុះបណ្តាលទាំងនោះ មន្ត្រីរាជការនៅតាមក្រសួង ស្ថាប័នផ្សេងៗ និងនៅតាមអង្គភាពនានាថ្នាក់ខេត្ត ក៏ដូចជាវិស័យឯកជន ក៏ទទួលបានផលប្រយោជន៍ពីការជួយបណ្តុះបណ្តាល និងបំប៉នចំណេះដឹងទាំងនេះផងដែរ ។

-សរុបចំនួនមន្ត្រីដែលបានឆ្លងកាត់ការបណ្តុះបណ្តាលមានចំនួន **១,២៣០** នាក់ ( ស្រី២១២នាក់) ក្នុងនោះ ថ្នាក់កណ្តាល មានចំនួន **៥០៧** នាក់ ( ស្រី ១១៧ នាក់) និងរាជធានី-ខេត្ត មានចំនួន **៧២៣** ( ស្រី ៩៥ នាក់) ។

-ចំពោះកម្រិតសមត្ថភាពមន្ត្រីរាជការពីមួយឆ្នាំទៅមួយឆ្នាំ ក៏មានការប្រែប្រួលកើនឡើងគួរឱ្យកត់សំគាល់ ។ មកដល់ពេលនេះ យើងមានមន្ត្រីថ្នាក់បណ្ឌិតចំនួន ១៦ នាក់ ( ស្រី ២នាក់) ថ្នាក់អនុបណ្ឌិតចំនួន ២១៥ នាក់ ( ស្រី ៣១នាក់) ថ្នាក់បរិញ្ញាប័ត្រចំនួន ៥៣២នាក់ ( ស្រី ១០៣នាក់) ដែលទាំងអស់នេះក្លាយជាជង្រុកនៃពុទ្ធិជួយដល់ការគ្រប់គ្រងដឹកនាំក្រសួង ឱ្យសម្រេចបានលទ្ធផលល្អ ។ យើងនឹងបន្តអនុវត្តកម្មវិធីអភិវឌ្ឍធនធានមនុស្សតាមជំហ៊ានៗទៅមុខជាដរាប ដើម្បីជំរុញឱ្យមន្ត្រីរាជការនៅគ្រប់លំដាប់ថ្នាក់ ក្លាយជាមន្ត្រីមានសមត្ថភាពគ្រប់គ្រាន់អាចទទួលរ៉ាប់រងរាល់ភារកិច្ចដែលក្រសួងប្រគល់ឱ្យ និង តាមទាន់ការវិវត្តន៍នៃសកលភាវូបនីយកម្ម រួមចំណែកសម្រេចជោគជ័យ

កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទី៤។

**២-ការងារហិរញ្ញវត្ថុ**

ស្របតាមកាលៈទេសៈដែលស្ថានភាពហិរញ្ញវត្ថុជាតិ ត្រូវទទួលរងផលប៉ះពាល់ពីវិបត្តិហិរញ្ញវត្ថុសកល ការគ្រប់គ្រងការចំណាយដោយប្រុងប្រយ័ត្ន និងការបន្តកៀងគរចំណូលចូលថវិការដ្ឋ គឺជាវិធានការដែលរាជរដ្ឋាភិបាលបានដាក់ចុះ ហើយដែលត្រូវបានក្រសួងពាណិជ្ជកម្មកំពុងយកចិត្តទុកដាក់អនុវត្តយ៉ាងខ្ជាប់ខ្ជួន។

***ក-ស្ថានភាពចំណូល***

ផែនការចំណូលបង់ចូលថវិការដ្ឋឆ្នាំ២០០៩ មានចំនួន : ១១៦,៤៤៨,៤០០,០០០ រៀល

អនុវត្តចំណូលក្នុងរយៈពេលមួយឆ្នាំមានចំនួន : ១២៩,៩៤៩,១៩៦,៦៩៦ រៀល

ស្មើនឹង ១១១,៥៩%នៃផែនការចំណូលប្រចាំឆ្នាំ និងមានកម្រិតប្រហាក់ប្រហែលគ្នានឹងឆ្នាំមុនដែរ។ នេះជាលទ្ធផលវិជ្ជមានដែលការកៀងគរចំណូល ទទួលបានក្នុងកម្រិតថេរ ទោះស្ថានភាពសេដ្ឋកិច្ចជួបការលំបាកជាងមុនក្តី។

***ខ-ស្ថានភាពឥណទានថវិកា***

សរុបឥណទានថវិកាឆ្នាំ២០០៩ មានចំនួន : ៣០,៥៩២,០០០,០០០ រៀល

ក្រសួងបានធ្វើសំណើសុំចំណាយក្នុងរយៈមួយឆ្នាំមានចំនួន : ៣៥,៨៣៨,២៦៥,៣១២ រៀល ស្មើនឹង១១៧.១៤%

អាណត្តិបោះផ្សាយក្នុងរយៈពេលមួយឆ្នាំមានចំនួន : ៣០,៦៥៥,២៨៨,៣៧៦ រៀល ស្មើនឹង១០០.២០%

ថវិកាដែលបានផ្តល់តាមអាណត្តិក្នុងរយៈពេលមួយឆ្នាំមានចំនួនៈ ២៩,៣៥០,១៣៩,២៣១ រៀល ស្មើនឹង ៩៥.៩៤% នៃផែនការឆ្នាំដែលបានអនុម័ត។

ក្នុងការអនុវត្តគម្រោងឥណទានថវិកា ក្រសួងពាណិជ្ជកម្មតែងបានសហការជាមួយ ប្រតិភូអធិការកិច្ចនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិនិត្យផ្ទៀងផ្ទាត់ឡើងវិញរាល់ឯកសារ សក្ខីប័ត្រចំណូល-ចំណាយ ព្រមទាំងបែបបទអនុវត្តនីតិវិធីចំណាយនៅគ្រប់អង្គភាព (រាប់ទាំងនៅតាមមន្ទីរពាណិជ្ជកម្មផង) ដើម្បីជាបណ្តើរៗកែសម្រួល និងប្រតិបត្តិទៅតាមសំណូមពរនៃការអនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ។

**៣-ការងារសវនកម្ម និងអធិការកិច្ច**

ដើម្បីបង្កើនប្រសិទ្ធភាពការងារ និងកាត់បន្ថយហានិភ័យក្នុងការអនុវត្តភារកិច្ចនៅតាមអង្គភាពនីមួយៗ ការងារសវនកម្មគឺជាកាតព្វកិច្ចដែលក្រសួងបានប្រតិបត្តិជាប្រចាំ ដោយផ្អែកទៅតាមវិធានគតិយុត្តិទាំងឡាយ សំដៅធ្វើវិភាគសកម្មភាព វាយតម្លៃចំណុចខ្លាំង ខ្សោយនៃប្រព័ន្ធការងារ ហើយផ្តល់នូវអនុសាសន៍ដើម្បីធ្វើការកែលម្អ និងតម្រង់ទិសអង្គភាពនានា ឱ្យបានទាន់ពេលវេលា។ តាមកម្មវិធីសវនកម្មឆ្នាំ២០០៩ មន្ត្រីជំនាញសវនកម្ម ត្រូវបានបែងចែកភារកិច្ចឱ្យចុះធ្វើសវនកម្មនៅតាមមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ចំនួន១៦មន្ទីរ (លើគម្រោង១៨មន្ទីរ)។ លើសពីនេះ ក៏មានការធ្វើអធិការកិច្ចដោយអគ្គាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុថែមទៀត ដែលជារបបអធិការកិច្ចប្រចាំឆ្នាំយ៉ាងទៀងទាត់ ដោយមិនទុកឱ្យមានកំហុសឆ្គងធំដុំកើតឡើង ហើយមិនមានការដោះស្រាយនោះទេ។

តាមលទ្ធផលដែលបានអនុវត្តកន្លងមក អាចធ្វើការកត់សំគាល់ឃើញថា នៅតាមមន្ទីរ អង្គភាព មានការបែងចែកភារកិច្ចជូនមន្ត្រីរាជការតាមលំដាប់ថ្នាក់បានល្អប្រសើ ទោះបីនៅមានករណីខ្លះ ខ្វះមន្ត្រីបំពេញការងារ ដោយមូល

ហេតុមានមន្ត្រីចូលនិវត្តន៍ពុំទាន់បានបំពេញជំនួស ខ្លះមានជម្ងឺ ហើយខ្លះទៀតជួបការលំបាកខាងជីវភាពផង ឆ្លៀតទៅរៀនបន្ថែមផង មិនអាចធ្វើការពេញលេញ ប៉ុន្តែម្នាក់ៗមានការទទួលខុសត្រូវក្នុងការងារដែលបានប្រគល់ឱ្យ។ ចំពោះការកត់ត្រាតាមដានវត្តមានមន្ត្រី ក៏នៅមានការខ្វះខាតនៅឡើយក្នុងការអនុវត្ត ដែលតម្រូវឱ្យគ្រប់អង្គភាពចូលរួមអនុវត្តតាមការណែនាំរបស់ក្រសួង ដើម្បីជៀសចេញពីទម្លាប់អសកម្ម ដែលនាំឱ្យជះឥទ្ធិពលដល់ទិន្នផលការងារ។ ក្រៅពីនោះ ការងារសវនកម្មបានសំដៅទៅរកការងារគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិ ដែលជាធនធានចាំបាច់បម្រើដល់ដំណើររដ្ឋបាលទូទៅរបស់អង្គភាព។ តាមការសង្កេតឃើញ នៅគ្រប់អង្គភាព មានកិច្ចបញ្ជីការគណនេយ្យត្រឹមត្រូវចេះកត់ត្រាតាមដានចំណូល ចំណាយ និងទុកដាក់ឯកសារគតិយុត្តិ សម្រាប់បង្ហាញបំភ្លឺតាមសំណូមពរ និងឆ្លើយតបទាន់ពេលដែលបានកំណត់ ប៉ុន្តែបញ្ហាដែលត្រូវបានណែនាំឱ្យកែតម្រូវគឺ ការកត់ត្រាប្រតិបត្តិការហិរញ្ញវត្ថុ នៅមានភាពមិនច្បាស់លាស់ដោយអន្លើ នៅខ្វះខាតក្នុងការបង្កើត និងកាន់កាប់បញ្ជីគណនេយ្យ ឯកសារ សក្ខីប័ត្រ ហើយនិងករណីមានការធ្វើកំណែច្រើនដង។

ចំពោះទ្រព្យសម្បត្តិនៅតាមអង្គភាព ជាពិសេស ដី-អគារ ភាគច្រើន បានធ្វើប័ណ្ណសំគាល់កម្មសិទ្ធិតាមការណែនាំរបស់ក្រសួង លើកលែងតែទីតាំងខ្លះដែលនៅពាក់ព័ន្ធនឹងការគ្រប់គ្រងរបស់រដ្ឋអំណាចមូលដ្ឋាន ឬត្រូវបានបុគ្គលមួយចំនួនកាន់កាប់ខុសច្បាប់ ដែលបញ្ហាទាំងនេះ ត្រូវបានបញ្ចូលជាអនុសាសន៍សម្រាប់មន្ទីរពាណិជ្ជកម្មដែលពាក់ព័ន្ធបន្តដោះស្រាយឱ្យបានឆាប់តាមដែលអាចធ្វើបាន ជាការធានាការពារថែរក្សាទ្រព្យសម្បត្តិរដ្ឋ ក៏ដូចជាទ្រព្យសម្បត្តិក្រសួងឱ្យស្ថិតស្ថេរគង់វង់។ ទន្ទឹមនឹងនេះ ក៏ទាមទារឱ្យគ្រប់អង្គភាពកត់ត្រាតាមដានការប្រែប្រួលកើន-ថយ នូវចលនៈវត្ថុ អចលនៈវត្ថុ ឱ្យបានជាប់លាប់ បញ្ជាក់ច្បាស់ពីមូលហេតុកើន-ថយ និងកសាងឱ្យបានបញ្ជីសារពើភ័ណ្ឌរាល់ថ្ងៃ ០១ ខែមករា នៃឆ្នាំសារពើពន្ធនីមួយៗ។

## II-សកម្មភាពពាណិជ្ជកម្មដើម្បីចូលរួមអនុវត្តយុទ្ធសាស្ត្រចតុកោណ

### ១-ការអនុវត្តន៍យុទ្ធសាស្ត្រអភិក្រមគ្របដណ្តប់ទូទាំងវិស័យពាណិជ្ជកម្ម ( Trade SWAp )

ដោយប្រកាន់ភ្ជាប់នូវភារកិច្ចស្នូលរបស់ខ្លួន ក្នុងនាមក្រសួងពាណិជ្ជកម្ម នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិបានរួមចំណែកសម្រេចបានជាលទ្ធផលការងារចំបងៗ មានដូចខាងក្រោម :

-សហការជាមួយក្រុមការងារដៃគូអភិវឌ្ឍន៍ សម្រេចបានការកសាងឯកសារបទដ្ឋានបច្ចេកទេសទាំងឡាយសម្រាប់ជាមូលដ្ឋានគ្រប់គ្រងការងារអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade SWAp) ដែលក្នុងនោះ មានកិច្ចព្រមព្រៀងអនុវត្តកម្មវិធីគាំទ្រការអភិវឌ្ឍន៍ពាណិជ្ជកម្ម (TDSP) របស់ធនាគារពិភពលោក ការចុះកិច្ចព្រមព្រៀងអនុស្សរណៈយោគយល់ (MOU) កម្មវិធីពង្រឹងសមាហរណ៍កម្មពាណិជ្ជកម្ម (EIF) របស់អង្គការសហប្រជាជាតិ ទទួលបន្ទុកសេវាគម្រោង ព្រមទាំងបទដ្ឋានគតិយុត្តិទាំងឡាយ អំពីនីតិវិធីលទ្ធកម្មហិរញ្ញវត្ថុ លើការគ្រប់គ្រងគម្រោង

-រៀបចំអនុវត្តផែនការការងារគ្រប់គ្រងការកែសម្រួលរចនាសម្ព័ន្ធផ្ទៃក្នុង ការងារលទ្ធកម្មហិរញ្ញវត្ថុ និងការផ្សព្វផ្សាយតាមវេបសាយ ទទួលបានលទ្ធផលល្អ

-សម្រេចបានការជ្រើសរើសទីប្រឹក្សា និងទីប្រឹក្សាបច្ចេកទេស ខ្មែរ-បរទេស តាមកិច្ចព្រមព្រៀងជាមួយធនាគារ ពិភពលោក លើផ្នែកលទ្ធកម្ម ផ្នែកហិរញ្ញវត្ថុ ផ្នែកព័ត៌មានវិទ្យា IT និងការអនុវត្តន៍គម្រោងផ្នែកច្បាប់ គោល

នយោបាយពាណិជ្ជកម្ម

-រចនាសម្ព័ន្ធគ្រប់គ្រងអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម ត្រូវបានអនុម័តពីរាជរដ្ឋាភិបាល តាមរយៈសេចក្តីសម្រេចលេខ ៧៦ ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ហើយបន្ទាប់ពីនេះ សមាសភាពក្រុមការងារសសរស្តម្ភទាំង៣ ក៏ត្រូវបានចាត់តាំងជាយន្តការអនុវត្តយ៉ាងច្បាស់លាស់

-ទទួល និងពិនិត្យគម្រោងចំនួន៤៦ ដែលអង្គភាព ស្ថាប័ននានាបានដាក់ជូនគណៈកម្មការអនុវត្តគម្រោងសម្រេចលើដំណើរគម្រោងនីមួយៗ ភ្ជាប់ជាមួយតម្រូវការថវិកា។

**២-ការងារគ្រប់គ្រងជំនួយបច្ចេកទេស**

***២.១-កម្មវិធីគាំទ្រការអភិវឌ្ឍន៍ពាណិជ្ជកម្ម (TDSP)*** :

គម្រោងគាំទ្រកម្មវិធីអភិវឌ្ឍន៍ពាណិជ្ជកម្ម (TDSP) ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៩ រវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារពិភពលោក ដែលត្រូវបានប្រកាសជាផ្លូវការថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០៩ បានបំពេញកិច្ចការមួយចំនួន ដូចខាងក្រោម :

-រៀបចំបទដ្ឋានគតិយុត្តិ និងឯកសារច្បាប់នានា សម្រាប់គ្រប់គ្រងគម្រោង (TDSP) ដែលក្នុងនោះមានបទដ្ឋានគតិយុត្តិផ្នែកហិរញ្ញវត្ថុ ផ្នែកលទ្ធកម្ម ដំណើរការគម្រោង នីតិវិធីទំនាក់ទំនងរវាងក្រសួងជាមួយធនាគារពិភពលោក និង ស្ថាប័នដទៃទៀត

-រៀបចំកសាងសមត្ថភាពមន្ត្រីតាមតម្រូវការជាក់ស្តែងរបស់គម្រោង TDSP ដែលទាមទារឱ្យមានអ្នកទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ បេឡា ផ្នែកលទ្ធកម្ម ផ្នែកទំនាក់ទំនង ផ្នែកព័ត៌មានវិទ្យា និងទីប្រឹក្សាបរទេសផ្នែកអនុវត្តគម្រោងគោលនយោបាយពាណិជ្ជកម្ម

***២.២- គម្រោងសមាហរណកម្មពាណិជ្ជកម្ម (EIF)***

-គម្រោងសមាហរណកម្មពាណិជ្ជកម្មរបស់កម្ពុជាដែលមានទឹកប្រាក់ ១.៥លានដុល្លារអាមេរិក ត្រូវបានអនុម័ត និងប្រកាសចូលជាធរមានកាលពីថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៩។ គម្រោងនេះនឹងផ្តល់អត្ថប្រយោជន៍ដល់ការរួមវិភាគទានក្នុងកិច្ចអភិវឌ្ឍន៍ពាណិជ្ជកម្ម។

***២.៣- គម្រោងជំនួយបច្ចេកទេសផ្សេងៗទៀត***

-សហការជាមួយគម្រោង TRADE Project លើការអនុវត្តន៍ការងារទាក់ទងដល់សរសរស្តម្ភទី២ ការងារផ្សព្វផ្សាយតាមប្រព័ន្ធបោះពុម្ពផ្សាយ និង IT និងធ្វើជាអ្នកសម្របសម្រួលរវាងក្រសួងពាណិជ្ជកម្ម និងគម្រោង USAID ស្តីពី Economic Growth Program ដែលបានអនុវត្តន៍ដោយអង្គការ DAI និងមានទីស្តីការគណៈរដ្ឋមន្ត្រីក្នុងនាមជាដៃគូការងារ។

**៣-ការបម្រើសេវាសាធារណៈ**

ដោយច្បាមជាប់ពីគោលដៅជាយុទ្ធសាស្ត្រនៃការអនុវត្តន៍ក្នុងការដ្ឋានកំណែទម្រង់រដ្ឋបាល ក្រសួងពាណិជ្ជកម្មបានខិតខំអនុវត្តកែលម្អសេវាសាធារណៈលើគ្រប់វិស័យ សំដៅឆ្លើយតបទៅនឹងសំណូមពររបស់ប្រជា ពលរដ្ឋដែលជាអ្នកទទួលសេវាពីរដ្ឋ ដោយខិតខំធ្វើយ៉ាងណាប្រែក្លាយខ្លួនឱ្យទៅជាអ្នកផ្តល់សេវាដ៏មានប្រសិទ្ធភាព និង ជាដៃគូអភិវឌ្ឍន៍

ដែលអាចទុកចិត្តបានរបស់ប្រជាពលរដ្ឋ ជាមួយនឹងការបន្តធ្វើកំណែទម្រង់លើវិស័យសេវាសាធារណៈ ដែលកំពុងតែអនុវត្តផង និងការបង្កើតប្រភេទសេវាថ្មីថែមទៀតផង ដើម្បីសម្រួលដល់សេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ក៏ដូចជាវិស័យឯកជន ហើយក៏សម្រាប់ធ្វើជាមូលដ្ឋានដល់ការត្រៀមរៀបចំផ្ទេរមុខងារដល់រដ្ឋបាលថ្នាក់ក្រោមជាតិ នៅក្នុងក្របខ័ណ្ឌនៃ**កម្មវិធីជាតិនៃការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** ដែលអន្តរក្រសួងកំពុងតែខិតខំប្រឹងប្រែងបញ្ចប់សេចក្តីព្រាង ត្រៀមដាក់ជូនគណៈរដ្ឋមន្ត្រីអនុម័តក្នុងរយៈពេលខ្លីខាងមុខ ក្នុងគោលដៅបង្វិតសេវាសាធារណៈ ឱ្យកាន់តែកៀកជាមួយប្រជាពលរដ្ឋ។ លទ្ធផលនៃការចូលរួមអនុវត្តកំណែទម្រង់សេវាសាធារណៈ កន្លងទៅនេះ ត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញនៅតាមវិស័យមួយចំនួនដូចតទៅ:

### ***៣.១-ការចុះបញ្ជីពាណិជ្ជសញ្ញា និងការផ្តល់សេវាដែលពាក់ព័ន្ធ***

#### ***ការទទួលពាក្យស្នើសុំថ្មី***

ការទទួលពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងឆ្នាំ ២០០៩ សរុបមានចំនួន ៣,០៧៧ម៉ាកក្នុងនោះ ពាក្យស្នើសុំចុះបញ្ជីការពារម៉ាកក្នុងស្រុកមានចំនួន ៨០៦ម៉ាក និងក្រៅស្រុកមានចំនួន ២.២៧១ម៉ាក។ បើប្រៀបធៀបទៅនឹងការទទួលពាក្យស្នើសុំចុះបញ្ជីការពារម៉ាកក្នុងឆ្នាំ២០០៨ ឃើញថា មានការថយចុះចំនួន ២២ម៉ាកស្មើនឹង -០.៧,%។ ថ្វីត្បិតមានការថយបន្តិច ដោយសារតែឥទ្ធិពលនៃវិបត្តិហិរញ្ញវត្ថុពិភពលោក ដែលអាចធ្វើឱ្យក្រុមហ៊ុន ផលិតករ និងអាជីវករបន្ថយសកម្មភាពអាជីវកម្មខ្លះ ប៉ុន្តែប្រការគួរឱ្យចាប់អារម្មណ៍គឺ ការទទួលពាក្យស្នើសុំចុះបញ្ជី ការពារម៉ាកក្នុងស្រុកមានការកើនឡើងចំនួន ២២៨ម៉ាក។ កត្តានេះ បានឆ្លុះបញ្ចាំងឱ្យឃើញថា កម្ពុជាកំពុងផ្តល់តម្លៃខ្ពស់ចំពោះការចុះបញ្ជីម៉ាក និងកាន់តែយល់ច្បាស់ពីអត្ថប្រយោជន៍នៃកិច្ចការពារម៉ាកផលិតផល ហើយនេះជាកត្តាជំរុញទៅដល់ការប្រកួតប្រជែងមួយដោយស្មោះត្រង់ ស្មើភាពចំពោះមុខច្បាប់នៅលើទីផ្សារ បង្ហាញពីការជឿទុកចិត្តរបស់ អាជីវករ ផលិតករ មកលើសមត្ថកិច្ចជំនាញរបស់ក្រសួងក្នុងការផ្តល់សេវាប្រភេទនេះ និងក្នុងកិច្ចខិតខំអនុវត្តច្បាប់ ដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញា។ មិនតែប៉ុណ្ណោះ ដោយចង់បញ្ជ្រាបចំណេះដឹងពីការងារកម្មសិទ្ធិបញ្ញាឱ្យកាន់តែចូលជ្រៅដល់ស្រទាប់សាធារណៈជន ក្រសួងនៅបានបន្តការចុះផ្សព្វផ្សាយកម្រងអត្ថបទច្បាប់កម្មសិទ្ធិបញ្ញា ជូនដល់មជ្ឈដ្ឋាន សិស្ស និស្សិត និងប្រជាពលរដ្ឋជាច្រើនលើកនៅតាមគ្រឹះស្ថានសិក្សា និងនៅតាមមូលដ្ឋានរាជធានី-ខេត្ត។

#### ***ការឯកភាពចុះបញ្ជីម៉ាកដែលបានស្នើសុំ***

-ការចុះបញ្ជីម៉ាក សរុបមានចំនួន ៣,១១៦ម៉ាក ក្នុងនោះ ម៉ាកក្នុងស្រុកមានចំនួន៦៩៨ម៉ាក ម៉ាកក្រៅស្រុក មានចំនួន ២.៤១៨ម៉ាក។ បើប្រៀបធៀបការចុះបញ្ជីម៉ាកក្នុងឆ្នាំ២០០៨កន្លងមក ឃើញថា មានការកើនឡើងចំនួន៨០៥ម៉ាក ស្មើនឹង ៣៤.៨% ក្នុងនោះ ការចុះបញ្ជីម៉ាកក្នុងស្រុកមានការកើនឡើង ២៦១ម៉ាក ស្មើនឹង ៦០% និងការចុះបញ្ជីម៉ាកក្រៅស្រុកមានការកើនឡើងចំនួន ៥៤៤ម៉ាក ស្មើនឹង ២៩%។ កត្តាដែលនាំឱ្យការឯកភាពលើការចុះបញ្ជីម៉ាកក្នុងឆ្នាំ២០០៩ មានការកើនឡើង ដោយសារ :

ក-ការត្រួតពិនិត្យម៉ាកដោយប្រើប្រព័ន្ធ IPAS កាន់តែមានភាពស្ទាត់ជំនាញ និងបំព្រួញពេលវេលា

ខ-ឯកសារឆ្លើយឆ្លង ការប្រគល់ និងទទួលបានឆាប់រហ័ស

គ-ឯកសារជាគោលការណ៍ចុះបញ្ជីម៉ាកមួយចំនួន បានបន្តអនុវត្តពីឆ្នាំ ២០០៧-២០០៨

***កិច្ចការក្រោយចុះបញ្ជីម៉ាក***

| | | |
|---|---|---|
| -ការប្តូរឈ្មោះអាស័យដ្ឋាន | : | ៣០៩ម៉ាក |
| -ការបញ្ជាក់លើការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាក | : | ១,៩៥៤ម៉ាក |
| -ការកែតម្រូវ | : | ២៨ម៉ាក |
| -ការផ្ទេរសិទ្ធិម្ចាស់ម៉ាក | : | ៣២៧ម៉ាក |
| -ការប្តូរឈ្មោះ ឬបញ្ចូលគ្នានៃម្ចាស់ម៉ាក | : | ៥៩៩ម៉ាក |
| -ការចុះបញ្ជីម៉ាកសារឡើងវិញ | : | ៦៨៩ម៉ាក |
| -ការលុបម៉ាក | : | ១១ម៉ាក |
| -ទទួលពាក្យស្នើសុំចុះបញ្ជីម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញ | : | ០២ម៉ាក |

ចំពោះការចុះបញ្ជីសម្គាល់ភូមិសាស្ត្រផលិតផលទំនិញនៅពេលនេះ ត្រូវបានចាត់ទុកថាជារបត់លេចធ្លោ និងជាប្រភេទសេវាសាធារណៈមួយថ្មីដែលផ្តល់ផលប្រយោជន៍ដល់ការអភិវឌ្ឍន៍ផលិតផលកម្ពុជា ពិសេសផលិតផលកសិកម្ម ដើម្បីទទួលបាននូវសិទ្ធិការពាររឹងមាំខាងផ្លូវច្បាប់នូវភាពល្បីឈ្មោះជាកេរ្តិ៍ដំណែល និងជាប្រពៃណីនៃផលិតផលតាមតំបន់នីមួយៗ តួយ៉ាងដូចជា ម្រេច(កំពត) ស្ករត្នោត(កំពង់ស្ពឺ)ជាដើម ដែលអ្វីៗដែលយើងបានធ្វើនេះ គឺជាការចាប់យកនូវលទ្ធភាពនាំដល់ការលើកស្ទួយតម្លៃ និងប្រៀបប្រកួតប្រជែងរបស់ផលិតផលក្នុងស្រុករបស់យើង។

***ការដោះស្រាយវិវាទរំលោភបំពានកម្មសិទ្ធិបញ្ញា និងការលុបម៉ាកចេញពីបញ្ជី***

កិច្ចការពារម៉ាក ពាណិជ្ជនាម មិនចប់ត្រឹមតែការចុះបញ្ជីម៉ាកនោះទេ ពោលគឺត្រូវតែមានវិធានការឃ្លាំមើល និងទប់ស្កាត់រាល់អំពើក្លែងបន្លំម៉ាកផលិតផល ពាណិជ្ជនាម លើគ្រប់ផលិតផល និងសេវា ដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ហើយនោះ។ ជារឿយៗ យើងតែងជួបនូវបញ្ហាបណ្តឹងតវ៉ាលើករណីរំលោភបំពានម៉ាកផលិតផល និងរកឃើញភស្តុតាងនៃការក្លែងបន្លំម៉ាកមួយចំនួន ដែលត្រូវបានសមត្ថកិច្ចនគរបាល ចុះបង្ក្រាប និងបញ្ជូនសំណុំរឿងទៅតុលាការ។ ក្រសួងពាណិជ្ជកម្មនៅតែបន្តទទួលរាល់បណ្តឹងតវ៉ា និងពង្រីកកិច្ចសហការជាមួយស្ថាប័នមានសមត្ថកិច្ចពិសេស ជាមួយមន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងប្រមូលព័ត៌មានដែលមានប្រយោជន៍ពីផ្នែកឯកជន ដើម្បីរិះរកគ្រប់មធ្យោបាយដោះស្រាយរាល់ការរំលោភបំពានទាំងនោះ ទោះតាមរូបភាពសម្រុះសម្រួលរវាងភាគីពាក់ព័ន្ធ ឬតាមវិធានការផ្លូវច្បាប់ ក្នុងគោលបំណងទាក់ទាញការជឿទុកចិត្តពីសំណាក់ពាណិជ្ជករ វិនិយោគិន មកលើបរិស្ថានទីផ្សាររបស់យើង ដូចដែលបានបង្ហាញឱ្យឃើញនូវលទ្ធផលខាងក្រោម:

***-ការទទួលពាក្យបណ្តឹង***

បានទទួលពាក្យបណ្តឹងសរុបចំនួន ២៧ ករណី ក្នុងនោះរួមមាន ការទទួលពាក្យបណ្តឹងស្នើសុំទប់ស្កាត់ការរំលោភបំពានមានចំនួន ១៣ករណី។ បើធ្វើការប្រៀបធៀបទៅនឹងឆ្នាំមុន ឃើញថាមានការថយចុះចំនួន ១ករណី ស្មើនឹង ៧.៥៧% ហើយការទទួលពាក្យបណ្តឹងស្នើសុំលុបម៉ាកចេញពីបញ្ជី មានចំនួន ១៤ករណី។ បើប្រៀបធៀបទៅនឹងការទទួលពាក្យបណ្តឹងស្នើសុំលុបម៉ាក ក្នុងឆ្នាំ២០០៨ ឃើញមានការថយចុះចំនួន ១ករណី ស្មើនឹង ៦.៦៦%។

***-ការដោះស្រាយការរំលោភបំពាន***

បានពិនិត្យពាក្យបណ្តឹងទប់ស្កាត់ការរំលោភបំពានចំនួន១៨ករណី ( ក្នុងឆ្នាំ២០០៩ ទទួលបាន ១៣ករណី និងសេសសល់ពីឆ្នាំមុនៗ ៥ករណី) ដោយបានដោះស្រាយការរំលោភបំពានបានចំនួន ១២ករណី ក្នុងនោះរួមមាន ការសម្របសម្រួលដោយមានកំណត់ហេតុចំនួន ៧ករណី ធ្វើលិខិតជូនដំណឹងជាសាធារណៈចំនួន ២ករណី បដិសេធ ២ករណី (ព្រោះគ្មានមូលដ្ឋានផ្លូវច្បាប់ និងខ្វះការបង្ហាញចម្លើយត្រឹមត្រូវ) និងដកពាក្យបណ្តឹងដោយដើមបណ្តឹងវិញ ១ករណី ដោយសារម្ចាស់ម៉ាកបានប្តូរជំហរ ហើយនៅសល់ ៦ករណីទៀត កំពុងបន្តពិនិត្យដោះស្រាយ ។

***-ការលុបម៉ាកចេញពីបញ្ជី***

បានពិនិត្យពាក្យបណ្តឹងស្នើសុំលុបម៉ាកចំនួន ២៣ករណី ( ក្នុងឆ្នាំ ២០០៩ ទទួលបាន ១៤ ករណី និងនៅសល់ពីឆ្នាំមុនៗ ៩ករណី) និងបានដោះស្រាយចំនួន ១៦ករណី ក្នុងនោះរួមមាន ការលុបម៉ាកចេញពីបញ្ជីចំនួន ១០ករណី ស្មើនឹង ១១ម៉ាក និងលុបឈ្មោះក្រុមហ៊ុន ១ករណី កែតម្រូវម៉ាកសាជាថ្មីចំនួន ៣ករណី ស្មើនឹង ៤ម៉ាក និងទាត់ចោល ១ករណី ព្រោះគ្មានមូលដ្ឋានផ្លូវច្បាប់គ្រប់គ្រាន់ដើម្បីលុបម៉ាកទាំងនោះបាន។ ចំណែក ៧ករណីដែលនៅសល់ ស្មើនឹង ១១ម៉ាកទៀតនោះ កំពុងបន្តនីតិវិធីពិនិត្យ និងដោះស្រាយ។ បើប្រៀបធៀប លទ្ធផលនៃការលុបម៉ាកក្នុងឆ្នាំ២០០៩ ទៅនឹងឆ្នាំ២០០៨ ឃើញថា មានការថយចុះចំនួន ៤ម៉ាក ស្មើនឹង ២៦.៦៦% ។

***៣.២-ការចុះបញ្ជីពាណិជ្ជកម្ម និងការផ្តល់សេវាដែលពាក់ព័ន្ធ***

ការចុះបញ្ជីពាណិជ្ជកម្ម គឺជាប្រភេទសេវាសាធារណៈដែលបានដំណើរការអស់រយៈពេល១៧ឆ្នាំកន្លងទៅ ហើយ ក្រោមវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ដែលមានសារៈសំខាន់ជួយឱ្យរដ្ឋ គ្រប់គ្រងបានរាល់សកម្មភាពរបស់សហគ្រាស ក្រុមហ៊ុន និងជួយដល់ការពង្រីកវិស័យឯកជន ឱ្យទទួលបានការការពារផលប្រយោជន៍ក្នុងការធ្វើពាណិជ្ជកិច្ចស្របតាមច្បាប់ បង្កភាពកក់ក្តៅដល់ពាណិជ្ជករ វិនិយោគិនជាតិ អន្តរជាតិ ដែលជាផ្នែកមួយនៃការរួមចំណែកអភិវឌ្ឍន៍វិស័យឯកជន។ ពីមួយឆ្នាំទៅមួយឆ្នាំ សេវាចុះបញ្ជីពាណិជ្ជកម្ម ត្រូវបានកែលម្អគុណភាពឱ្យសមស្របទៅតាមកាលៈទេសៈ និងស្ថានភាពសេដ្ឋកិច្ច ក៏ដូចជាតម្រូវការរបស់ម្ចាស់ក្រុមហ៊ុន សហគ្រាស សំខាន់គឺការកាត់បន្ថយបែបបទ ពេលវេលានិងតម្លៃសេវាដែលត្រូវបំពេញ។ ជាក់ស្តែងក្រសួងពាណិជ្ជកម្មបានបង្កើតរួចហើយនូវការិយាល័យ សាខាចុះបញ្ជីពាណិជ្ជកម្មនៅតាមមណ្ឌលឆ្ងាយពីរាជធានីចំនួន ៦មណ្ឌល ដើម្បីបង្កភាពងាយស្រួលដល់ការចុះបញ្ជី ដូចជា មណ្ឌលបាត់ដំបង មណ្ឌលព្រះសីហនុ មណ្ឌលសៀមរាប មណ្ឌលកំពង់ចាម មណ្ឌលក្រចេះ និងមណ្ឌលស្វាយរៀង ដែលបច្ចុប្បន្នមណ្ឌលបាត់ដំបងកំពុងបានដំណើរការយ៉ាងល្អ។ រីឯទម្រង់ស្នើសុំចុះបញ្ជីពាណិជ្ជកម្ម ក៏សាមញ្ញងាយយល់ ខ្លី និងអាចបំពេញបានភ្លាមៗ ដែលទាំងអស់នេះ គឺជាផ្នែកមួយនៃសំណូមពរកែលម្អសេវាសាធារណៈតាមទិសដៅនៃកម្មវិធីកំណែទម្រង់រដ្ឋបាល។ មិនត្រឹមតែការចុះបញ្ជីគ្រាដំបូងនោះទេដែលយើងបានយកចិត្តទុកដាក់ ប៉ុន្តែចំណុចសំខាន់ដែលយើងបានអនុវត្តយ៉ាងហ្មត់ចត់ និងមិនធ្វេសប្រហែសនោះគឺ ការបន្តតាមដានរាល់សកម្មភាពក្រុមហ៊ុន សហគ្រាស ដែលបានចុះបញ្ជីរួចហើយ ដើម្បីគ្រប់គ្រងឱ្យបានទិន្នន័យក្រុមហ៊ុន សហគ្រាសទាំងនោះ តាមរយៈការតម្រូវឱ្យធ្វើប្រតិវេទន៍ប្រចាំឆ្នាំ ការពិនិត្យបញ្ជាក់ជាថ្មីឡើងវិញនូវវិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្ម ក្នុងរយៈកាល៣ឆ្នាំម្តង ការរៀបចំកំណត់លេខកូដក្រុមហ៊ុនថ្មី ការគ្រប់គ្រងថែរក្សាឯកសារតម្កល់ទុកដែលមានតម្លៃដល់៩៩ឆ្នាំ ឱ្យបានគត់មត់ ងាយស្រួលដល់ការស្រាវជ្រាវ ។

***ក-សេវាចុះបញ្ជីពាណិជ្ជកម្ម ត្រូវបានបង្ហាញចេញជាលទ្ធផល តាមរយៈស្ថិតិ ដូចខាងក្រោម ៖***

| លរ | ប្រភេទសហគ្រាសពាណិជ្ជកម្ម | ឆ្នាំ២០០៨ | ឆ្នាំ២០០៩ | អត្រាកំណើន (4-3) % / 3 |
|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 |
| ១ | ក្រុមហ៊ុន | ២ . ៧៤៤ | ២ . ០០៣ (1) | -២៧,០០ % |
| ២ | ការិយាល័យតំណាង | ១៨ | ១១ | -៣៨,៨៩ % |
| ៣ | សាខាក្រុមហ៊ុនបរទេស | ២២ | ៣១ | ៤០,៩០ % |
| | **សរុប** | ២ . ៧៨៤ | ២ . ០៤៥ (2) | -២៦,៥៤ % |
| ៤ | សហគ្រាសឯកបុគ្គល | ៤៥០ | ៤៨៦ | ៨,០០ % |
| ៥ | វិសោធនកម្មក្រុមហ៊ុន | ១ . ៦០០ | ១ . ៧១៧ | ៧,៣១ % |
| ៦ | វិសោធនកម្មសហគ្រាស | ៣៦ | ៧២ | ១០០,០០ % |
| ៧ | រំលាយៈ | | | |
| | - តាមសំណើក្រុមហ៊ុន | ២៩ | ៣៤ | ១៧,២៤ % |
| | - តាមប្រកាស | 0 | 0 | 0 |
| | **សរុប** | ២៩ | ៣៤ | ១៧,២៤ % |

(1) ក្នុងចំនួន ២០០៣ ក្រុមហ៊ុន មានក្រុមហ៊ុនវិនិយោគចំនួន ៥៣ ក្រុមហ៊ុន ។

(2) ក្នុងចំនួន ២០៤៥ ក្រុមហ៊ុន មានក្រុមហ៊ុនសញ្ជាតិខ្មែរចំនួន ១២៣១ ក្រុមហ៊ុន និងសញ្ជាតិបរទេសចំនួន ៨១៤ ក្រុមហ៊ុន ។

ដោយឡែក ការិយាល័យសាខាចុះបញ្ជីពាណិជ្ជកម្មមណ្ឌលខេត្តបាត់ដំបង បានធ្វើការចុះបញ្ជីសហគ្រាសពាណិជ្ជកម្ម ដែលមានទីតាំងអាជីវកម្មនៅខេត្តបាត់ដំបង បន្ទាយមានជ័យ ពោធិ៍សាត់ និង ប៉ៃលិន ទទួលបានលទ្ធផលដូចតទៅ :

| | ឆ្នាំ ២០០៨ | ឆ្នាំ ២០០៩ | អត្រាកំណើន |
|---|---|---|---|
| -ក្រុមហ៊ុនថ្មី | = ៤០ ក្រុមហ៊ុន | ៣៩ ក្រុមហ៊ុន | -២.៥០ % |
| -សហគ្រាសឯកបុគ្គល | = ០៥ សហគ្រាស | ១៨ ក្រុមហ៊ុន | ២៦០ % |
| -វិសោធនកម្មក្រុមហ៊ុន | = ៣២ ក្រុមហ៊ុន | ២១ ក្រុមហ៊ុន | -៣៤.៣៧ % |
| -វិសោធនកម្មសហគ្រាសឯកបុគ្គល | = ០ សហគ្រាស | ០២ សហគ្រាស | |

អាចនិយាយបានថា ដោយសារផលប៉ះពាល់កើតឡើងពីវិបត្តិហិរញ្ញវត្ថុពិភពលោក ធ្វើអោយតួលេខចុះបញ្ជីក្រុមហ៊ុនពាណិជ្ជកម្មក្នុងឆ្នាំ២០០៩ មានការថយចុះ២៦.៥៤% បើប្រៀបធៀបទៅនឹងតួលេខឆ្នាំ២០០៨ កន្លងទៅនេះ ចំណែកឯតួលេខចុះបញ្ជីសហគ្រាសឯកបុគ្គលមានការកើនឡើង ៨% ។

ទោះជាយ៉ាងណាក៏ដោយ (ថ្វីត្បិត) តួលេខចុះបញ្ជីពាណិជ្ជកម្មមានការថយចុះ ប៉ុន្តែចំណុចដែលគួរអោយកត់សំគាល់ គឺវិនិយោគិនបរទេសជាច្រើនដូចជា វៀតណាម កូរ៉េ ចិន ម៉ាឡេស៊ី សឹង្ហបុរី នៅតែមានជំនឿជឿជាក់លើស្ថានភាពសេដ្ឋកិច្ច និងស្ថេរភាពនយោបាយនៅកម្ពុជា បន្តមកធ្វើវិនិយោគនៅកម្ពុជា ជាបន្តបន្ទាប់ ក្នុងនោះ វិនិយោគិនពីវៀតណាមកើនឡើងច្រើនជាមុន ។

### ខ-ការបំពេញប្រតិវេទន៍

ក្រុមហ៊ុនដែលបានបំពេញប្រតិវេទន៍សម្រាប់ឆ្នាំ ២០០៨ និង យកមកតម្កល់ទុកនៅក្រសួងពាណិជ្ជកម្ម ក្នុងឆ្នាំ២០០៩ មានចំនួន **២,០២៩** ក្រុមហ៊ុន។ បើប្រៀបធៀបនឹងការបំពេញប្រតិវេទន៍សម្រាប់ឆ្នាំ ២០០៧ (តម្កល់ទុកក្នុងឆ្នាំ ២០០៨) មានចំនួន **២,២៥៨** ក្រុមហ៊ុន ឃើញថាមានការថយចុះ ១០,១៤%។ ប្រឈមនឹងការថយចុះតួលេខនៃការបំពេញប្រតិវេទន៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុនពាណិជ្ជកម្ម នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម បន្តអនុវត្តវិធានការចេញប្រកាសនិរាករណ៍រាល់ឯកសារបញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ចំពោះក្រុមហ៊ុនទាំងឡាយណា ដែលខកខានមិនបានយកប្រតិវេទន៍មកតម្កល់ទុកក្នុងអំឡុងពេល ៣ឆ្នាំ បន្តបន្ទាប់ ស្របតាមខ្លឹមសារនៃប្រកាសស្តីពីការបំពេញប្រតិវេទន៍ប្រចាំឆ្នាំ លេខ ១៤០ MOC / SM 2008 ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០០៨ ។ ជាក់ស្តែងក្រសួងពាណិជ្ជកម្មបានចេញលិខិតជូនដំណឹងជាលើកចុងក្រោយដល់ក្រុមហ៊ុនចំនួន ៥០ អោយមកធ្វើការបំពេញ និងតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ ហើយបានសហការជាមួយអាជ្ញាធរមូលដ្ឋាន ចុះពិនិត្យផ្ទាល់ដល់ទីស្នាក់ការក្រុមហ៊ុនទាំងនេះ និងត្រៀមចេញប្រកាសនិរាករណ៍រាល់ឯកសារបញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ចំពោះក្រុមហ៊ុនទាំងឡាយណា ដែលនៅតែមិនមកបំពេញ និងតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ។

### គ-ការដោះស្រាយវិវាទពាណិជ្ជកម្ម :

វិវាទពាណិជ្ជកម្មតែងកើតមានឡើងម្តងម្កាល ដោយករណីខ្លះបានដោះស្រាយតាមការអន្តរាគមន៍ និងសម្រុះសម្រួលពីនាយកដ្ឋានចុះបញ្ជី ហើយក៏មានករណីខ្លះ ភាគីបានដោះស្រាយតាមផ្លូវតុលាការ។ ក្នុងឆ្នាំកន្លងទៅ ក្រសួងបានប្រើប្រាស់តួនាទីរបស់ខ្លួន ដោះស្រាយវិវាទក្រុមហ៊ុន លើករណីមួយចំនួនដូចជា:

-ស្រាវជ្រាវនិងចេញលិខិតបញ្ជាក់ពីព័ត៌មានទាក់ទងនឹងក្រុមហ៊ុន H.C.G (Cambodia) Group Co, Ltd ជូនទៅស្ថានតំណាងពាណិជ្ជកម្មអមស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅសាធារណរដ្ឋសង្គមនិយមវៀតណាម។

-បានធ្វើលិខិតឆ្លើយតបទៅមេធាវីនៃការិយាល័យមេធាវីកម្ពុជា ហាំង កាំង លើករណីស្នើសុំបញ្ជាក់ឯកសារសុពលភាពចុងក្រោយ ដើម្បីដោះស្រាយជម្លោះក្នុងក្រុមហ៊ុនបូឌីទ្រីណូលីជ ( Bodhi Tree Knowledge Co, Ltd )

-សហការដោះស្រាយទំនាស់ក្នុងក្រុមហ៊ុន ឌីអិនអេស គ្រុប DNS Group Co, Ltd ។

-បានកោះអញ្ជើញភាគីទំនាស់ក្នុងក្រុមហ៊ុន ណារ៉េត លីមីធីត អភិវឌ្ឍន៍អគ្គិសនី(ទីតាំងខេត្តពោធិសាត់ ) ដើម្បីសម្រុះសម្រួលវិវាទក្នុងក្រុមហ៊ុន ។

-បានអន្តរាគមន៍សម្របសម្រួលវិវាទ រវាងក្រុមហ៊ុន ទេព្យ ជ គ្រុប និងលោកឧកញ៉ា ឈួន គឹមសាន។

### ឃ-ការផ្សព្វផ្សាយច្បាប់ និងនីតិវិធីនៃការចុះបញ្ជីពាណិជ្ជកម្ម :

-បានចូលរួមកម្មវិធីពិគ្រោះយោបល់ជាសាធារណៈលើសេចក្តីព្រាងប្រកាស ស្តីពី " ការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ ( កុងស៊ីបញ្ចាំ ) " ដែលក្នុងនាមតំណាងក្រសួងពាណិជ្ជកម្ម បានចូលរួមបកស្រាយច្បាប់ចុះបញ្ជីពាណិជ្ជកម្មដល់ពាណិជ្ជករដែលបានចូលរួមកម្មវិធី។

-បានចូលរួមក្នុងកម្មវិធីកំណែទម្រង់រដ្ឋបាល លើការអនុវត្តរបបវិមជ្ឈការ និងយន្តការច្រកចេញចូលតែមួយនៅខេត្តតាកែវ និងខេត្តកំពង់ចាម ព្រមទាំងបានធ្វើការផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានទាំងឡាយ ដែលពាក់ពន្ធនឹងការ

ចុះបញ្ជីពាណិជ្ជកម្ម ។

-ជារឿយៗ បានធ្វើការផ្សព្វផ្សាយច្បាប់ និងនីតិវិធីនៃការចុះបញ្ជីពាណិជ្ជកម្ម ដល់កម្មសិក្សាការីមកពីវិទ្យាស្ថានសិក្សា និងមហាវិទ្យាល័យនានា ។

### ៣.៣-ការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម

នេះជាប្រភេទសេវាសាធារណៈមួយ សំដៅផ្តល់លក្ខណៈស្របច្បាប់ជារូបវន្តបុគ្គលដល់ប្រជាពលរដ្ឋដែលប្រកបរបរអាជីវកម្ម សេវាកម្មខ្នាតតូច និងមធ្យមមិនជាប់ពន្ធលើប្រាក់ចំណេញ ដើម្បីក្តាប់បានពីទំហំទីតាំងអាជីវកម្ម សេវាកម្ម កម្មវត្ថុអាជីវកម្មជាក់លាក់ និងទិន្នន័យប្រែប្រួលនៃប្រភេទអាជីវកម្ម សេវាកម្មពីមួយឆ្នាំទៅមួយឆ្នាំ នៅតាមមូលដ្ឋាន រាជធានី-ខេត្ត ស្រុក ក្រុង ខណ្ឌនីមួយៗ បម្រើដល់សំណូមពរនៃការស្រាវជ្រាវពីសក្តានុពលទីផ្សារបច្ចុប្បន្ន។ បន្ថែមលើនេះ អាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការ ដែលត្រូវបានផ្ទេរសមត្ថកិច្ចពីស្ថាប័នធនាគារជាតិ ក៏ត្រូវដាក់បញ្ចូលក្នុងគោលដៅនៃការគ្រប់គ្រងផងដែរ ។

ក្នុងឆ្នាំ២០០៩នេះ មន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត បានចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្មចំនួន ១២,៩២៤ច្បាប់ ។ ក្នុងនាមសមាជិកក្រុមពិគ្រោះយោបល់បច្ចេកទេសអន្តរក្រសួងគាំទ្រថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលបង្កើតឡើងដោយគណៈកម្មាធិការជាតិសម្រាប់អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) តាមរយៈកម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការ ក្រសួងពាណិជ្ជកម្មបានធ្វើប្រតិភូកម្មអំណាចក្នុងការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ដល់ស្រុកគោលដៅចំនួន ២ ដោយដាក់ឱ្យអនុវត្តនៅការិយាល័យច្រកចេញចូលតែមួយ ។ នៅពេលខាងមុខនេះ គម្រោងសាកល្បងនៃការិយាល័យច្រកចេញចូលតែមួយ នឹងអនុវត្តនៅស្រុក ក្រុងគោលដៅ ៧ទៀត ដោយមានការចូលរួមពីក្រសួងពាណិជ្ជកម្ម ស្ថាប័នពាក់ព័ន្ធ សាលាខេត្ត និងក្រសួងមហាផ្ទៃ ។

### ៣.៤-ការចុះបញ្ជីផ្តល់សិទ្ធិនាំចេញក្រោមប្រព័ន្ធអនុគ្រោះពន្ធ

ក្រុមហ៊ុន សហគ្រាស បានចុះបញ្ជីទទួលសិទ្ធិនាំចេញតាមលក្ខខ័ណ្ឌ និងវិធានប្រភពដើមទំនិញ មានដូចជា : **រោងចក្រកាត់ដេរចំនួន : ២៤៣**រោងចក្រ (ក្រុមហ៊ុនកាត់ដេរថ្មីមានចំនួន ៣៦ ក្រុមហ៊ុន, ក្រុមហ៊ុនកាត់ដេរចាស់ចំនួន : ២០៧ក្រុមហ៊ុន) **ក្រុមហ៊ុនស្បែកជើងចំនួន** : ២៦ ក្រុមហ៊ុន។ បច្ចុប្បន្ន ក្នុងវិស័យឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ និងស្បែកជើង រោងចក្រកំពុងដំណើរការមាន ចំនួន : ២៦៩រោងចក្រ ក្នុងនោះមានរោងចក្រកាត់ដេរចំនួន ២៤៣ និងស្បែកជើងចំនួន ២៦ ដែលមានកម្លាំងកម្មករបម្រើការងារសរុបចំនួន **៣២០,៧៣៤នាក់** (កម្មការិនីចំនួន ២៩៣,៦៦៤នាក់) ដែលនេះជាការស្រូបយកកម្លាំងពលកម្មក្នុងសង្គមមួយភាគធំ និងជាលទ្ធភាពដល់ការផ្គត់ផ្គង់សាច់ប្រាក់ជាមធ្យម **២៧លានដុល្លាក្នុងមួយខែ។** ជួយទ្រទ្រង់ដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ពលករពលការិនី និងក្រុមគ្រួសាររបស់គេ។ យើងក៏មានមោទនៈភាពផងដែរ ចំពោះស្ថានភាពរោងចក្រនៅកម្ពុជា ដែលនៅបន្តដំណើរការទៅមុខក្នុងការផលិតនាំចេញទំនិញ នៅពេលដែលឥទ្ធិពលនៃវិបត្តិសេដ្ឋកិច្ចសកលកំពុងញាំញីដល់សេដ្ឋកិច្ចជាតិ អាស្រ័យដោយរាជរដ្ឋាភិបាលបានចាត់វិធានការសមស្របនានា ក្នុងការជួយសម្រួលដល់ម្ចាស់រោងចក្រ សហគ្រាស លើការអនុវត្តកាតព្វកិច្ចពន្ធ សោហ៊ុយចំណាយផ្សេងៗ និងការចាត់ចែងអនុវត្តដោយទន់ភ្លន់ រស់រវើកតាមស្ថានការណ៍សេដ្ឋកិច្ច សង្គមជាក់ស្តែង រួមទាំងការបន្តកិច្ចសម្រួលពាណិជ្ជកម្ម ។

## ៣.៥-ការផ្តល់វិញ្ញាបនប័ត្រប្រភពដើមទំនិញ និងអាជ្ញាប័ណ្ណផ្សេងៗ

អនុវត្តតាមកិច្ចព្រមព្រៀងជាធរមានដែលកម្ពុជាជាប្រទេសហត្ថលេខីមួយនោះ និងអនុលោមតាមវិធានប្រភពដើមទំនិញ ក្រសួងពាណិជ្ជកម្មបានចាត់ចែងអនុវត្តលក្ខខ័ណ្ឌជាកាតព្វកិច្ចទាំងឡាយ ដើម្បីឆ្លើយតបទៅនឹងសំណូមពរនៃប្រទេសផ្តល់ភាពអនុគ្រោះ ដោយស្មារតីទទួលខុសត្រូវខ្ពស់ និងហ្មឹងម៉ាត់ ធានាឱ្យដំណើរការ និងនីតិវិធីចេញឯកសារវិញ្ញាបនប័ត្រប្រភពដើមទំនិញ ធានាបានតាមទម្រង់គតិយុត្តិ។ ធ្វើអធិការកិច្ចតាមបទបញ្ញត្តិ ដោយបង្កើនកិច្ចសហការជាមួយមន្ត្រីគយនៃប្រទេសនាំចូល ជាពិសេស ភ្នាក់ងារគយ សហរដ្ឋអាមេរិក កាណាដា និងគយសហគមន៍អឺរ៉ុប ដើម្បីតាមដានត្រួតពិនិត្យមូលដ្ឋានផលិតកម្មរបស់សហគមន៍ អ្នកនាំចេញកម្ពុជា កំណត់នូវប្រភពដើមទំនិញ ការពារបានតម្លៃ និងឥទ្ធិពលនៃវិញ្ញាបនប័ត្រប្រភពដើមទំនិញ ដែលទាំងអស់នេះ ស្ថិតក្នុងគោលបំណងការពារផលប្រយោជន៍ដល់អ្នកផលិត អ្នកនាំចេញពិតប្រាកដ និងចុងក្រោយគឺ បានជាប្រយោជន៍ធំធេងដល់ការដោះស្រាយការងារជូនប្រជាពលរដ្ឋរាប់ម៉ឺនសែននាក់។

ការផ្តល់សេវាសាធារណៈជូនបណ្តាក្រុមហ៊ុន រោងចក្រ សហគ្រាស សហគមន៍អ្នកនាំចេញកម្ពុជា ឱ្យទទួលបានវិញ្ញាបនប័ត្រប្រភពដើមទំនិញ សម្រាប់នាំចេញទៅកាន់ទីផ្សារក្នុងទ្វីបអាមេរិកទាំងមូល ទីផ្សារទ្វីបអឺរ៉ុប ទ្វីបអាហ្វ្រិក សាធារណៈរដ្ឋសង្គមនិយមវៀតណាម ទ្វីបអាស៊ី និងអូសេអានី សម្រេចជាលទ្ធផលគឺក្នុងឆ្នាំ២០០៩ កម្ពុជាបានធ្វើការនាំចេញទំនិញទៅកាន់ទីផ្សារ សំខាន់ៗ រួមមានទីផ្សារសហដ្ឋអាមេរិក កាណាដា និង ទីផ្សារផ្សេងៗ ក្នុងទ្វីបអាមេរិក (ក្រៅពីសហរដ្ឋអាមេរិក និង កាណាដា) ដែលមានទឹកប្រាក់សរុបប្រមាណ **១,៧៥១,៣៤៦,៩២៩** ដុល្លារអាមេរិក បើប្រៀបធៀបនឹងឆ្នាំ២០០៨ បរិមាណទឹកប្រាក់នាំចេញមានការថយចុះប្រមាណ៤៨៧,២៩៧,១៧០ដុល្លារ ស្មើនឹង ២១,៧៧% ។ ដោយឡែក សំលៀកបំពាក់ និងវាយនភ័ណ្ឌ មានទឹកប្រាក់ប្រមាណ ១,៧៣១,២២១,៥៤០ ដុល្លារ បើប្រៀបធៀបនឹងឆ្នាំ ២០០៨ មានទឹកប្រាក់ថយចុះប្រមាណ ៤៩៨,៨៩៣,១៣៩ ដុល្លារ ស្មើនឹង ២២,៣៧% (សូមពិនិត្យតារាងឧបសម្ព័ន្ធ)។

### ក-ការនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិក

វិញ្ញាបនប័ត្រប្រភពដើមទំនិញ Certificate of Origin (C/O) ជូនអ្នកនាំចេញនូវ C/O FORM N សរុបបាន ចំនួន៤៧,៤៥៥ច្បាប់ ទៅកាន់ទីផ្សារសហរដ្ឋអាមេរិក។ បរិមាណទឹកប្រាក់នាំចេញសរុបប្រមាណ **១,៥១៨,៧៤៨,៨៩០** ដុល្លារអាមេរិក បើធៀបទៅនឹងឆ្នាំ២០០៨ ទឹកប្រាក់នាំចេញមានការថយចុះប្រមាណ ៤៧១,៤៩២,២៤០ដុល្លា ស្មើនឹង ២៣.៦៩%។ ក្នុងនោះ មានមុខទំនិញ :

| | | | |
|---|---|---|---|
| -សំលៀកបំពាក់ (Garment) | : | ១,៤៨៩,០០៨,៧៦៩ | ដុល្លារអាមេរិក |
| -វាយនភ័ណ្ឌ (Textile) | : | ១៨,៥៣៨,៦៩៣ | ដុល្លារអាមេរិក |
| -ស្បែកជើង (Footwear) | : | ៦,៩៣២,២៥៥ | ដុល្លារអាមេរិក |
| -ទោចក្រយាន (Bicycle) | : | ១,៦៩៧,៩៥២ | ដុល្លារអាមេរិក |
| -សិប្បកម្ម (Handicraft) | : | ៩៦០,៦៤៦ | ដុល្លារអាមេរិក |

| | | | |
|---|---|---|---|
| -ចំណីឆ្កែ (Dog Food) | : | ៧៩២,២០៦ | ដុល្លារអាមេរិក |
| -ប្រដាប់ក្មេងលេង (Toy) | : | ៥៨៨,៤៥៧ | ដុល្លារអាមេរិក |
| -ផ្សេងៗ (Other) | : | ២២៩,៩១០ | ដុល្លារអាមេរិក |

***ខ-ការនាំចេញទៅកាន់ទីផ្សារកាណាដា***

វិញ្ញាបនប័ត្រប្រភពដើមទំនិញ (C/O) ទៅកាន់ទីផ្សារកាណាដា សរុបចំនួន ៩,៧២៥ ច្បាប់ ក្នុងនោះ C/O FORM N ចំនួន ១,៦៣៨ ច្បាប់ និង C/O FORM A ចំនួន ៨,០៨៧ ច្បាប់ ។ បរិមាណទឹកប្រាក់នាំចេញសរុបក្នុងឆ្នាំ ២០០៩ នេះ ប្រមាណ ១៩៨,០០៩,០២០ ដុល្លារអាមេរិក បើប្រៀបធៀបនឹង ឆ្នាំ ២០០៨ ទឹកប្រាក់នាំចេញមានការថយចុះប្រមាណ ៤,៩០៧,៧៤៥ ដុល្លារអាមេរិក ស្មើនឹង ២,៤២% ។ មុខទំនិញនាំចេញ រួមមាន :

| | | | |
|---|---|---|---|
| -សំលៀកបំពាក់ (Garment) | : | ១៩២,៦១៦,២៥១ | ដុល្លារអាមេរិក |
| -វាយនភ័ណ្ឌ (Textile) | : | ២,៤៤០,៧៦៣ | ដុល្លារអាមេរិក |
| -ស្បែកជើង (Footwear) | : | ១,២៤៩,១៩១ | ដុល្លារអាមេរិក |
| -ទោចក្រយាន (Bicycle) | : | ១,៦៨៣,៤៧០ | ដុល្លារអាមេរិក |
| -អង្ករ (Rice) | : | ១៩,៣៤៤ | ដុល្លារអាមេរិក |

***គ-ការនាំចេញទៅកាន់ទីផ្សារផ្សេងៗក្នុងទ្វីបអាមេរិក ( ក្រៅពីសហរដ្ឋអាមេរិក និងកាណាដា )***

C/O FORM N ជូនអ្នកនាំចេញ សរុបបានចំនួន ៣,១២៣ច្បាប់ ទៅកាន់ទីផ្សារក្នុងទ្វីបអាមេរិក (ក្រៅពីសហរដ្ឋអាមេរិក និងកាណាដា) ទឹកប្រាក់នាំចេញសរុបប្រមាណ ៣៤,៥៨៩,០១៧ដុល្លារអាមេរិក។ បើប្រៀបធៀបទៅនឹងឆ្នាំ២០០៨ បរិមាណទឹកប្រាក់នាំចេញមានការថយចុះប្រមាណ ១០,៨៩៧,១៨៤ដុល្លារ ស្មើនឹង ២៣,៩៦% មុខទំនិញនាំចេញ រួមមាន :

| | | | |
|---|---|---|---|
| -សំលៀកបំពាក់ (Garment) | : | ២៨,៥៦៩,៨៩៣ | ដុល្លារអាមេរិក |
| -វាយនភ័ណ្ឌ (Textile) | : | ៤៧,១៧១ | ដុល្លារអាមេរិក |
| -ស្បែកជើង (Footwear) | : | ៥,៩៥១,៤៥០ | ដុល្លារអាមេរិក |
| -ទោចក្រយាន (Bicycle) | : | ២០,៤៦៨ | ដុល្លារអាមេរិក |

***ឃ-អាជ្ញាប័ណ្ណនាំចេញ-នាំចូល***

តួលេខនាំចេញតាមរបបអាជ្ញាប័ណ្ណ មានទំហំទឹកប្រាក់សរុបចំនួន **៧,០៥៤,៦៩៦.០៦**ដុល្លារអាមេរិក។ បើ ប្រៀបធៀបទៅនឹង ឆ្នាំ២០០៨កន្លងទៅដែលមានទឹកប្រាក់ចំនួន ៦,៧៤៧,៥៨២.៣៣ដុល្លារអាមេរិក គឺកើនឡើង ៤.៥៦%។ អាជ្ញាប័ណ្ណនាំចូលមានទឹកប្រាក់សរុបចំនួន **៧៧២,១១១.៨៧** ដុល្លារអាមេរិក ដោយឡែកក្នុងឆ្នាំ ២០០៨ នាំចូលបានតែ ៤,៨៩៦.០០ ដុល្លារអាមេរិកប៉ុណ្ណោះ។

***ង-នាំចេញទៅទ្វីបអឺរ៉ុប*** (EU)

វិញ្ញាបនប័ត្រប្រភពដើមទំនិញតាមទម្រង់ អេ និង អិន (Form A & N) ចេញជូនដល់អតិថិជន ក្រុមហ៊ុន

រោងចក្រ សហគ្រាស ធ្វើអាជីវកម្មនាំចេញទំនិញទៅកាន់រដ្ឋជាសមាជិក របស់សហគមន៍ អឺរ៉ុបទាំង ២៧រដ្ឋ រួមមានទឹកប្រាក់សរុបចំនួន **៦៩៥.៤៥៨.៥៩៥,៨៥** ដុល្លារអាមេរិក (បើធៀបឆ្នាំ២០០៨ មានទឹកប្រាក់ ចំនួន ៧៩៧,២៥៦,៦៧៧.៧៥ដុល្លារអាមេរិក គឺថយចុះ ១៧.៧៨ %)។ ក្នុងនោះទំនិញសំខាន់ៗ រួមមាន :

- -ផលិតផលសំលៀកបំពាក់ (Garment) : ៥៦៧.៨១៤.៣៩៧,៤១ ដុល្លារអាមេរិក
- -ផលិតផលស្បែកជើង (Footwear) : ៦៣.៨២៩.៦០២,៥៣ ដុល្លារអាមេរិក
- -ផលិតផលអង្ករ (Rice) : ៩.០៧៥.៧៣៨,៥០ ដុល្លារអាមេរិក
- -ផលិតផលសិប្បកម្ម (Handicraft) : ៦៨០.៧៧៦,៦១ ដុល្លារអាមេរិក
- -ផលិតផលផ្សេងៗ (Other) : ១៤.០៥៨.០៨០,៨០ ដុល្លារអាមេរិក

***ច-នាំចេញទៅក្រៅសហគមន៍អឺរ៉ុប (NON EU)***

វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ ( Form A and N ) មានទឹកប្រាក់សរុប ចំនួន **៣២.៩៩១.៣៨១,០៩** ដុល្លារអាមេរិក បើធៀបនឹងឆ្នាំ២០០៨ មានទឹកប្រាក់ចំនួន ៤២,៧៩០,៤៩៨.៨៦ ដុល្លារអាមេរិក គឺថយចុះ ២២.៩០% ក្នុងនោះទំនិញសំខាន់ៗ រួមមាន :

- -ផលិតផលសំលៀកបំពាក់ (Garment) : ២៨.៦៩៧.៣៨៨,៥០ ដុល្លារអាមេរិក
- -ផលិតផលស្បែកជើង (Footwear) : ១.៧៧៧.៧១០,៦៨ ដុល្លារអាមេរិក
- -ប្រេងដូងប្រេង (Crude Palm Oil) : ២.៤៥១.២១៧,៥៦ ដុល្លារអាមេរិក
- -ផលិតផលសិប្បកម្ម (Handicraft) : ៥៨.៤៩៨,៨៥ ដុល្លារអាមេរិក
- -ស្រាបៀរអង្គរ (Angkor Beer) : ៥.៥៥០,០០ ដុល្លារអាមេរិក
- -ផលិតផលម្រេច (Pepper) : ១.០១៥,៥០ ដុល្លារអាមេរិក

***ឆ-នាំចេញទៅទ្វីបអាហ្វ្រិក***

វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ (Form A & N) ជូនក្រុមហ៊ុន-សហគ្រាស មានទឹកប្រាក់ សរុបចំនួន **៤.០៨៧.៦៧៦,១៩** ដុល្លាររអាមេរិក (បើធៀបនឹងឆ្នាំ ២០០៨ មានទឹកប្រាក់ចំនួន **៤,៤០៩,១០៩.៨៤** ដុល្លារអាមេរិក គឺថយចុះ ៧.២៩%) ក្នុងនោះទំនិញសំខាន់ៗ រួមមាន:

- -ផលិតផលសំលៀកបំពាក់ (Garment) : ៣.០៥១.៩៤៦,០៦ ដុល្លារអាមេរិក
- -ផលិតផលស្បែកជើង (Footwear) : ១.០៣៥.៧៣០,១៣ ដុល្លារអាមេរិក

***ជ-កសិផលនាំចេញទៅកាន់សាធារណៈរដ្ឋសង្គមនិយមវៀតណាម***

យោងទៅលើកិច្ចសម្របសម្រួល ដែលបានចុះហត្ថលេខានៅថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ២០០៧ រវាងក្រសួង ពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម នៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម ក្នុងការអនុវត្តកន្លងមក កម្ពុជាទទួលបានភាពអនុគ្រោះពន្ធសូន្យភាគរយ(០%)នូវទំនិញកសិផលចំនួន២៥មុខ អនុញ្ញាត ឱ្យធ្វើការនាំចូលទៅកាន់សាធារណៈរដ្ឋសង្គមនិយមវៀតណាមលើកលែងតែ : សន្លឹកថ្នាំជក់ ស្រូវ-អង្ករ ស្ថិតនៅក្នុងការ កំណត់កូតាប្រចាំឆ្នាំ និងស្ថិតនៅក្រោមការចេញវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញតាមទម្រង់ អេស (C/O Form S) ។

ផ្តើមចេញពីនេះ ក្នុងឆ្នាំ២០០៩ វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ ទម្រង់អេស ( C/O Form S) ត្រូវបានផ្តល់ជូនក្រុមហ៊ុន មានទឹកប្រាក់សរុបចំនួន **២៣.០២៣.២៥០,០០**ដុល្លារអាមេរិក (បើធៀបនឹងឆ្នាំ ២០០៨ មានទឹកប្រាក់សរុប ចំនួន **១៤,៤៥០.១៥៩.០០**ដុល្លារអាមេរិក គឺកើនឡើង ៥៩.៣៣ % ) ដែលមានមុខទំនិញសំខាន់គឺៈ សន្លឹកថ្នាំជក់ គ្រាប់ស្វាយចន្ទីជាដើម ។

***ឈ-ការនាំចេញទៅ ទ្វីបអាស៊ី និងអូសេអានី***

វិញ្ញាបនប័ត្រប្រភពដើមទំនិញ នាំចេញទៅកាន់ទ្វីបអាស៊ី និងអូសេអានី មានទឹកប្រាក់សរុប : **១៣១,៧៣១,៩៣៣.១០ ដុល្លា** ក្នុងនោះមាន : ទម្រង់ **A** មានទឹកប្រាក់ចំនួន ៤៣,៨៥៧,៩៣៦.៦៨ដុល្លា, ទម្រង់ **N** មានទឹកប្រាក់ចំនួន ៤៥,០២៩,៥៦៦.៥៣ដុល្លា, ទម្រង់ SPT មានទឹកប្រាក់ចំនួន ៤៧៥,៩៨១.៨១ដុល្លា, ទម្រង់ AK មានទឹកប្រាក់ចំនួន ៣,០៤០,៦៥៨.០៩ដុល្លា, ទម្រង់ D មានទឹកប្រាក់ចំនួន ៣៩,០៨៥,៧២៩.៦៣ដុល្លា, ទម្រង់ AJ មានទឹកប្រាក់ចំនួន ៩៣៦.០០ដុល្លា, ទម្រង់ E មានទឹកប្រាក់ចំនួន ២៤១,១២៤.៣៦ដុល្លា ។

***ញ-ការងារធ្វើអធិការកិច្ចពាក់ព័ន្ធនឹងការនាំចេញ***

បានចុះធ្វើអធិការកិច្ចនៅតាមបណ្តារោងចក្រកាត់ដេរសំលៀកបំពាក់ និងស្បែកជើង ដើម្បីធ្វើការប្រៀបធៀបវត្ថុធាតុដើមដែលបាននាំចូល និងផលិតផលសម្រេចដែលបាននាំចេញ។ ការចុះត្រួតពិនិត្យទំនិញ បានអនុវត្តក្រោយពេលទំនិញត្រូវបានធ្វើការនាំចេញរួចហើយ ហើយការត្រួតពិនិត្យនេះ គឺគ្រាន់តែពិនិត្យទៅលើសង្វាក់ផលិតកម្ម លទ្ធភាពផលិតកម្ម កម្លាំងផលិតកម្ម របស់ក្រុមហ៊ុនដែលកំពុងប្រតិបត្តិការតែប៉ុណ្ណោះ ក្នុងគោលដៅផ្ទៀងផ្ទាត់ជាមួយបរិមាណផលិតផលដែលបាននាំចេញរួចហើយ ជាមួយនឹងវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញដែលក្រុមហ៊ុនបានស្នើសុំ។ ការចុះធ្វើអធិការកិច្ចសំដៅទៅលើក្រុមហ៊ុន រោងចក្រ សហគ្រាស ដែលបាននាំចេញផលិតផលស្បែកជើង ផលិតផលសំលៀកបំពាក់ និងវាយនភ័ណ្ឌ ស្រោមដៃ និងស្រោមជើង ផលិតផលសិប្បកម្ម អង្ករ ស្ករ ដែកកេះ ដូងប្រេង ផលិតផល Ethanol ផលិតផលកសិកម្ម ព្រមទាំងផលិតផល ផ្សេងៗទៀតដែលស្ថិតក្នុងគោលដៅអធិការកិច្ច ដើម្បីធ្វើឱ្យប្រាកដថា ទំនិញនាំចេញមានភាពស៊ីសង្វាក់ទៅនឹងការកំណត់លក្ខខ័ណ្ឌប្រភពដើមទំនិញ រាំងខ្ទប់ទង្វើប៉ុនប៉ងក្លែងបន្លំឯកសារ ដែលនាំឱ្យខូចប្រយោជន៍អ្នកគោរពច្បាប់។

***៣.៦-សេវាពង្រឹងសុវត្ថិភាព គុណភាពទំនិញ និងការការពារអ្នកប្រើប្រាស់***

ការគ្រប់គ្រងគុណភាព សុវត្ថិភាពផលិតផលទំនិញ និងសេវា ជារបៀបវារៈសំខាន់នៅក្នុងគោលដៅនៃការពង្រាយសេវាសាធារណៈ និងពង្រឹងគុណភាពសេវាបម្រើសំណូមពរដ៏ទទូចរបស់ប្រជាពលរដ្ឋដែលជាអ្នកប្រើប្រាស់។ ប្រភេទសេវានេះ ត្រូវបានអនុវត្តដោយអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ ( កាំកុងត្រូល) ផ្អែកទៅតាមច្បាប់ជាធរមាន ដែលអាចរំលេចចេញតាមចង្កោមបេសកកម្មចម្បងៗ ដូចខាងក្រោមៈ

***៣.៦.១-ការត្រួតពិនិត្យទំនិញនាំចូល***

*<u>មុខទំនិញនាំចូលសំខាន់ៗ ដែលឆ្លងកាត់ការត្រួតពិនិត្យឆ្នាំ ២០០៩ :</u>*

| ល.រ | ប្រភេទទំនិញ | ឯកតា | បរិមាណ | ថ្លៃដើម (USD) |
|---|---|---|---|---|
| ១ | ម្ហូបអាហារ | តោន | ១៩៨,២៧៧.០៩ | ១០៦,៦៦១,៤៣៧ |
| ២ | ភេសជ្ជៈ | លីត្រ | ៥,១៨៥,២៨៥.០០ | ១,៨៥៥,០៨៧ |
| ៣ | សារធាតុគីមី | តោន | ៥៨,៧៧៣.៣២ | ៣៦,៧៦១,៩៧៦ |
| ៤ | ប្រេងឥន្ធនៈ | តោន | ៨៨២,៧២៤.៩៥ | ៤៤៩,១៥៤,៧៦៥ |
| ៥ | ឱសថ និងបរិក្ខាពេទ្យ | តោន | ១២,២៥៦.៥១ | ១០៦,៩៧០,០២៦ |

| | | | | |
|---|---|---|---|---|
| ៦ | គ្រឿងសំអាង | តោន | ៩,៣៥៨.៤២ | ១៩,០៨១,០៤០ |
| ៧ | វត្ថុធាតុដើមកាត់ដេរ | តោន | ៤១៥,៦២០.៦០ | ១,៥០៧,៣២២,៨១៧ |
| ៨ | សំភារៈសំណង់ | តោន | ៩៥៣,៤២៧.៥៣ | ១៩៩,៧៥៣,៥៨៣ |
| ៩ | យានជំនិះគ្រប់ប្រភេទ | គ្រឿង | ៣៦១,១៤៦.២០ | ១៨៥,៦៣៧,៧០៦ |
| ១០ | ផ្សេងៗ | | | ១,១២៦,៦៦៥,៧៨១ |
| **សរុប** | | | | **៣,៧៣៩,៨៦៣,៨១៨** |

គួរកត់សំគាល់ថា ក្នុងការត្រួតពិនិត្យ យើងបានរកឃើញនូវផលិតផលនាំចូលមួយចំនួន ដែលពុំមានលក្ខណៈត្រឹមត្រូវតាមបញ្ញត្តិបច្ចេកទេស ឬគោលការណ៍ច្បាប់ ហើយត្រូវដាក់ចេញជាវិធានការតាមករណីនីមួយៗគឺ : ស៊ុតមាន់-ទា-គ្រួចចំនួន ៥៤,០៤០គ្រាប់ សាច់មាន់-ឆ្អឹងមាន់ជាប់សាច់ចំនួន ២២,៥៦៩គ.ក្រ សាច់ជ្រូកចំនួន ១៨៥គ.ក្រ ប្រហិតសាច់មាន់ចំនួន ៧៥០គ.ក្រ កំទេចនំ-កំទេចមី ស្ករគ្រាប់ ចំនួន ១,៩៣៣គ.ក្រ គ្រាប់សណ្តែកចំនួន ៤០គ.ក្រ ចាហួយ ចំនួន ១០គ.ក្រ កំទេចម៉ឹកក្រៀម ចំនួន ៨០គ.ក្រ ដំណាប់ផ្លែឈើចំនួន ៣៧០គ.ក្រ ប្រេងសណ្តែក-ខ្លាញ់ ចំនួន ៨៩៩គ.ក្រ ត្រីខកំប៉ុងចំនួន ២,៦៣២កំប៉ុង កាពិចំនួន ១៥០ គ.ក្រ ទឹកដោះគោខាប់ចំនួន ១០កំប៉ុង ទឹកខ្មេះចំនួន ១៩២ដប ភេសជ្ជៈ អាហារបំប៉នចំនួន ២,៥០០គ.ក្រ ផ្លែឈើត្រាំទឹកអំបិលចំនួន ៣២៥គ.ក្រ ភេសជ្ជៈចំរុះចំនួន ៥៤២ដប/កំប៉ុង = ៤៣១.៥០លីត្រ អំបិលគ្មានអ៊ីយ៉ូដចំនួន ១៥,៦៨០គ.ក្រ ទឹកអាស៊ីតចំនួន ១៨លីត្រ និង ទំនិញស្តុកទុកយូរខូចគុណភាពចំនួន ១០,០២២.៩០គ.ក្រ។ ក្នុងនោះ មន្ត្រីកាំកុងត្រូលបានឃាត់ទុក និងចាត់ចែងតាមនីតិវិធីចំពោះករណីនីមួយៗដូចជា បំផ្លាញចោល ឬរុញឱ្យត្រឡប់ទៅប្រទេសដើមវិញ ក្នុងនោះមាន ០៤ករណីត្រូវបានកសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីចាត់ការតាមផ្លូវច្បាប់ផងដែរ។

### ***៣.៦.២-ការត្រួតពិនិត្យទំនិញនាំចេញ***

កម្លាំងសមត្ថកិច្ចអគ្គនាយកដ្ឋានកាំកុងត្រូល បានចូលរួមសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ឃាត់ខ្លួនជនសង្ស័យដែលប៉ុនប៉ងនាំយកម្សៅគ្រឿងញៀនប្រភេទហេរ៉ូអ៊ីនបានចំនួន ០៥ករណី មានទម្ងន់សរុប **៣.១០២,៣** ក្រាម ដែលមានបំណងនាំចេញទៅបរទេស តាមច្រកព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ លទ្ធផលនេះ បង្ហាញពីការទទួលខុសត្រូវខ្ពស់ និងសមត្ថភាពរបស់មន្ត្រីយើង ព្រមទាំងកិច្ចសហការល្អពីស្ថាប័នអនុវត្តច្បាប់ ហើយក៏មានន័យថា យើងបាន រួមចំណែកក្នុងការការពារ មុខមាត់របស់ជាតិយើងលើឆាកអន្តរជាតិ។

***<u>ស្ថិតិមុខទំនិញនាំចេញសំខាន់ៗ ដែលឆ្លងកាត់ការត្រួតពិនិត្យរបស់អគ្គនាយកដ្ឋានកាំកុងត្រូលឆ្នាំ២០០៩:</u>***

| **ល.រ** | **ប្រភេទទំនិញ** | **ឯកតា** | **បរិមាណ/ទំងន់** | **តម្លៃដើម (USD)** |
|---|---|---|---|---|
| ១ | សត្វរស់ | ក្បាល | ១២,៩៤៧.០០ | ១៥០,២៥៤ |
| ២ | ផលនេសាទ | តោន | ៣,២៣៧.០៩ | ៣,៩៨៤,០៦១ |
| ៣ | ស្រូវ | តោន | ១,១៩៥.០០ | ២៧០,៦៦០ |
| ៤ | អង្ករ | តោន | ៦,៩០០.២៣ | ៣,៦៧៥,៣៩៧ |

| | | | | |
|---|---|---|---|---|
| ៥ | គ្រាប់ធញ្ញជាតិផ្សេងទៀត | តោន | ១៩៣,១៣៦.៧០ | ១២,៨៩១,៤៥២ |
| ៦ | កៅស៊ូក្រែប | តោន | ៣៥,៤៨២.៧២ | ៥៤,៧០១,៦២៨ |
| ៧ | ឈើកែច្នៃ | ម៣ | ៦៩,៥៥៥.៧៦ | ៣,៤២២,៥៦៧ |
| ៨ | គ្រឿងសង្ហារឹម | វាយ | ១១,៣១៧.០០ | ៣,៤២២,៥៦៧ |
| ៩ | ផលិតផលកសិកម្មផ្សេងទៀត | តោន | ២២២,៩៤២.៤២ | ១៩,០៦៥,៧៩១ |
| ១០ | ផលិតផលវាយនភ័ណ្ឌ និងសំលៀកបំពាក់ | | | ២,៥៣៨,០៦៣,០៣២ |
| ១១ | ទំនិញផ្សេងៗ | | | ១៤៨,៨៤២,៣៤០ |
| | **សរុប** | | | **២,៧៩០,៧៤៧,៩៨០** |

*តារាងប្រៀបធៀបទឹកប្រាក់នាំចេញសំលៀកបំពាក់ និងទំនិញវាយនភ័ណ្ឌឆ្នាំ២០០៩ ទៅនឹងឆ្នាំ ២០០៨*

*( គិតជា USD )*

| បរិយាយ | ឆ្នាំ ២០០៨ | ឆ្នាំ ២០០៩ | ប្រៀបធៀប | |
|---|---|---|---|---|
| | | | ប្រាក់លំអៀង | គិតជាភាគរយ |
| ទំនិញនាំចូល | ៤,៤២១,៧៥៣,៦៥៦ | ៣,៧៣៩,៨៦៣,៨១៨ | -៦៨១,៨៨៩,៨៣៨ | ១៥.៤២ % |
| ទំនិញនាំចេញ | ៣,៣៥៦,២១៩,៨១៣ | ២,៧៩០,៧៤៧,៩៨០ | -៥៦៥,៤៧១,៨៣៣ | ១៦.៨៤ % |
| **សរុប** | **៧,៧៧៧,៩៧៣,៤៦៩** | **៦,៥៣០,៦១១,៧៩៨** | **-១,២៤៧,៣៦១,៦៧១** | **-១៦.០៤ %** |

-សង្កេតលើទំហំទឹកប្រាក់នាំចូលខាងលើនេះ ឃើញថាមានការថយចុះចំនួន **៦៨១,៨៨៩,៨៣៨**ដុល្លា ស្មើនឹង -១៥.៤២% ប្រៀបជាមួយការនាំចូលឆ្នាំ២០០៨ ។ មូលហេតុនៃការថយចុះ គឺដោយសារការនាំចូលប្រេងឥន្ធនៈ យានយន្តគ្រប់ប្រភេទ សំភារៈ សំណង់ និងវត្ថុធាតុដើមកាត់ដេរ មានការថយចុះគួរឱ្យកត់សំគាល់ ។

-ការនាំចេញមានការថយចុះចំនួន **៥៦៥,៤៧១,៨៣៣**ដុល្លា ស្មើនឹង១៦.៨៤% បើប្រៀបធៀបជាមួយការនាំចេញឆ្នាំ២០០៨។ ការថយចុះទំនិញវាយនភ័ណ្ឌ និងសំលៀកបំពាក់ គឺជាមូលហេតុចម្បងនៃការថយចុះនេះគឺមានប្រហែល ៦១១,៦៧៥,៥៦៤ដុល្លា ស្មើនឹង -១៩.៤២% បើប្រៀបធៀបជាមួយការនាំចេញសំលៀកបំពាក់ឆ្នាំ ២០០៨។

### ***៣.៦.៣-ការត្រួតពិនិត្យទំនិញតាមទីផ្សារ និងសិប្បកម្ម***

ច្បាស់ណាស់ថា ការត្រួតពិនិត្យទំនិញនៅតាមមាត់ច្រកព្រំដែនដែលមានវិសាលភាពទូលំទូលាយនោះ ពិតជាមិនគ្រប់គ្រាន់តាមការចង់បានរបស់យើងឡើយ។ បញ្ហាគុណភាព សុវត្ថិភាពផលិតផលទំនិញ កំពុងតែត្រូវបានពលរដ្ឋទូទៅចាប់អារម្មណ៍ តម្រូវឱ្យសមត្ថកិច្ចជំនាញរបស់ក្រសួងឈ្មួញឈ្មួល អនុវត្តកិច្ចប្រតិបត្តិការមានលក្ខណៈជាភ្លៀងរលឹម គ្របដណ្តប់លើទីផ្សារលក់ដុំ-រាយនៅតាមមូលដ្ឋានរាជធានី-ខេត្ត ស្រុក ក្រុង ខណ្ឌ ដើម្បីទប់ស្កាត់ភាពពុំសមស្របតាមបញ្ញត្តិលើផលិតផល និងសកម្មភាពពាណិជ្ជកម្មផ្សេងៗ។ ដោយយល់ឃើញពីសារៈខាន់នេះ អគ្គនាយកដ្ឋានកាំកុងត្រូល បានដាក់ចេញនូវកម្មវិធីចុះធ្វើការត្រួតពិនិត្យនៅតាមបណ្តាទីផ្សារ និងសិប្បកម្មផលិតកែច្នៃ

ម្ហូបអាហារ នៅទូទាំងប្រទេស និងតាមដានស្រាវជ្រាវរាល់ប្រភពនៃការនាំចូល ការចែកចាយ ការផលិតខុសច្បាប់ ហើយចាត់វិធានការអនុវត្តតាមច្បាប់យ៉ាងសកម្ម។

***ក-ពាក់ព័ន្ធនឹងសុវត្ថិភាពម្ហូបអាហារ សកម្មភាពលើទីផ្សារ***

ចំពោះផលិតផលម្ហូបអាហារ ការត្រួតពិនិត្យគឺដើម្បីធានាថា ផលិតផលម្ហូបអាហារដែលកំពុងចរាចរនៅលើទីផ្សារមានគុណភាព សុវត្ថិភាព ចំពោះអ្នកប្រើប្រាស់ និងធានាបាននូវការធ្វើពាណិជ្ជកម្មម្ហូបអាហារ ប្រកបដោយសុច្ចរិត គ្មានការក្លែងបន្លំ។ ការត្រួតពិនិត្យបានតម្រង់ឆ្ពោះទៅលើគោលដៅ ៣ សំខាន់ គឺ :

***ក.១-ការត្រួតពិនិត្យអំពីគ្រោះថ្នាក់ផ្នែកគីមី***

-Borax លើសរសៃមី, គុយទាវ,សាច់ប៉ាត់តេ, ប្រហិតសាច់គោ

-Formalin លើផលិតផលសាច់ស្រស់ និងផលិតផលនេសាទស្រស់

-ម្សៅស Sodium Hydrosulfite លើស្ករត្នោត,សណ្តែកបណ្តុះ,ទំពាំងឫស្សី និងបន្លែហាន់ស្រាប់គ្រប់មុខ។

-សារធាតុគីមី Sodium Nitrate and Sodium Nitrite លើផលិតផលសាច់ក្រក សាច់ងៀត ត្រីងៀត (សម្រាប់ទុកឱ្យបានយូរ-មិនដុះផ្សិត....)

-សំណល់ថ្នាំសម្លាប់សត្វល្អិត (Pesticide Residues) លើបន្លែ ផ្លែឈើស្រស់ ព្រមទាំងការប្រើនៅលើត្រីប្រឡាក់ ប្រហុក ផ្អក.... ដោយចង់បង្កាសត្វរុយ និងសត្វល្អិតនានា។

-ទឹកខ្មេះបន្លំប្រើអាស៊ីតរ៉ែ ឬអាស៊ីតស៊ុលផួរិច។

***ក.២-ការត្រួតពិនិត្យផ្នែកអនាម័យ (អតិសុខុមជីវសាស្ត្រ)***

ធ្វើការវាយតម្លៃអំពីកម្រិតវត្តមាននៃពពួកមេរោគ បង្កជម្ងឺបណ្តាលពីការផលិតខ្វះអនាម័យ ការចម្លងពីបរិស្ថានជុំវិញ តាមការទុកដាក់នៅកន្លែងមិនស្អាតលើផលិតផល : ទឹកកក ការ៉េម សាន់វិច សាច់ប៉ាត់តេ ។ល។

***ក.៣-ការត្រួតពិនិត្យលើការបន្លំ***

នោះគឺការត្រួតពិពិត្យទៅលើស្លាកសញ្ញាមានដូចជា ឈ្មោះផលិតផល អាស័យដ្ឋានផលិត ប្រទេសផលិត អាស័យដ្ឋានអ្នកនាំចូល សារធាតុផ្សំ របៀបប្រើ ការប្រុងប្រយ័ត្ន បរិមាណឬទំងន់ ថ្ងៃ-ខែ-ឆ្នាំផលិត ឬថ្ងៃ-ខែ-ឆ្នាំផុតកំណត់ប្រើប្រាស់ ។ល។ ជារួម ស្លាកសញ្ញាត្រូវធានាឱ្យប្រាកដថា អ្នកប្រើប្រាស់អាចទទួលបាននូវព័ត៌មានគ្រប់គ្រាន់ និងច្បាស់លាស់តាមដែលគេចង់បានសម្រាប់ធ្វើការជ្រើសរើស។ ក្នុងដំណើរការនៃការត្រួតពិនិត្យខាងលើក្រៅពីការប្រើប្រាស់ TEST KITS ដែលអាចធ្វើការវិភាគបឋមនៅនឹងកន្លែង មន្ត្រីកាំកុងត្រូលបាននាំយកគំរូផលិតផលទាំងនោះ មកធ្វើការវិភាគនៅមន្ទីរពិសោធន៍កាំកុងត្រូលផងដែរ។ កើតចេញពីលទ្ធផលវិភាគ អគ្គនាយកដ្ឋានកាំកុងត្រូល បានចង្អុលបង្ហាញពីអ្នកធ្វើអាជីវកម្មទំនិញមិនសមស្របទាំងនេះ និងបានបញ្ជូនឈ្មោះឱ្យអាជ្ញាធរដែនដី គណៈកម្មការគ្រប់គ្រងផ្សារ ដើម្បីណែនាំឱ្យកែតម្រូវ និងព្រមានពីការផ្អាកការធ្វើអាជីវកម្ម ឬអនុវត្តតាមទោសបញ្ញត្តិ។

***លទ្ធផលដែលទទួលបានជាក់ស្តែងពីការចុះត្រួតពិនិត្យតាមទីផ្សារ :***

-ការចុះត្រួតពិនិត្យទៅលើផ្សារចំនួន **៥៨២** បានរកឃើញករណីមិនប្រក្រតី លើមុខទំនិញម្ហូបអាហារមួយចំនួន ដូចខាងក្រោម :

ស្លាបមាន់-ឆ្អឹងមាន់ចំនួន២៨.៨០គ.ក្រ សរសៃគុយទាវ-មីចំនួន ៦៦១.៤២គ.ក្រ មីកញ្ចប់ចំនួន ២១៦កញ្ចប់ សាច់ប៉ាតេ-ប្រហិត ចំនួន ៧២.៨០ គ.ក្រ ត្រីខកំប៉ុង ចំនួន ៥០៦កំប៉ុង ទឹកដោះគោឆៅ-ជូរចំនួន ១៦៥កំប៉ុង/ដប=១៣.៦៣លីត្រ ទឹកដោះគោខាប់ចំនួន ៣២៥កំប៉ុង ម្សៅកាហ្វេ-ទឹកដោះគោ-អូវ៉ាន់ទីន ចំនួន ១៧.៤៨គ.ក្រ ដំណាប់ផ្លែឈើចំនួន ៧៥.៤០គ.ក្រ ចាហួយចំនួន ១៤៥ កំប៉ុង នំ-ស្ករគ្រាប់ចំនួន ៣៦៩.៩២គ.ក្រ ប៉័រ-តៅហ៊ូចំនួន ៣៦ប្រអប់ ទឹកជ្រលក់-ទឹកខ្មេះចំនួន ៤៤០ដប បន្លែកំប៉ុងចំនួន ២៦១កំប៉ុង ប្រេងឆា-ប្រេងខ្យងចំនួន ២៧ ដប = ២៤.៧៤ លីត្រ សៀងប្រៃចំនួន ៨.៥គ.ក្រ អំបិលគ្មានអ៊ីយ៉ូដចំនួន ១៨គ.ក្រ កំទេចនំ-កំទេចមីចំនួន ១៤៥គ.ក្រ និងភេសជ្ជៈមានគ្មានសុរា ចំនួន ៣,៩៥៨ដប/ កំប៉ុង = ២,០០៤.៨២ លីត្រ ។

### *ខ-ការត្រួតពិនិត្យសិប្បកម្មកែច្នៃម្ហូបអាហារ*

ក្រៅពីការត្រួតពិនិត្យលើទីផ្សារ មន្ត្រីជំនាញបានចុះពិនិត្យដល់គ្រឹះស្ថានផលិត - កែច្នៃម្ហូបអាហារ និង បណ្តាឃ្លាំងស្តុកទំនិញ ដើម្បីពិនិត្យវាយតម្លៃស្ថានភាព និងកម្រិតនៃការអនុវត្តនីកិច្ចអនុវត្តផលិតកម្មល្អ (Good Manufacturing Practice - GMP ) កិច្ចអនុវត្តអនាម័យល្អ (Good Hygiene Practice - GHP) សម្រាប់ជាមូលដ្ឋានកសាង និងអនុវត្តកម្មវិធីឃ្លាំពិនិត្យទីផ្សារផងដែរ ។ ទីតាំងផលិតកែច្នៃម្ហូបអាហារចំនួន ១៩២កន្លែង ត្រូវបានរកឃើញថា មានការប្រើប្រាស់បានប្រើប្រាស់សារធាតុគីមីហាមឃាត់ក្នុងផលិតផលរបស់ខ្លួន ហើយផលិតផល ដែលចាត់ទុកថាគ្មានគុណភាព សុវត្ថិភាពសមស្របតាមបទបញ្ញត្តិ ត្រូវបានរឹបអូសយកទៅកំទេចចោលដោយបង្គាប់ ឱ្យម្ចាស់សិប្បកម្ម ធ្វើកិច្ចសន្យាបញ្ឈប់ការប្រើប្រាស់សារធាតុគីមីក្នុងផលិតផលរបស់ខ្លួនជាបន្តទៀត ។ មិនតែប៉ុណ្ណោះ សមត្ថកិច្ចកាំកុងត្រូល ក្នុងនាមជាមន្ត្រីនគរបាលយុត្តិធមិកំពុងតែងាកទៅរកចំណាត់ការតាមផ្លូវតុលាការ ចំពោះករណី ប្រើប្រាស់សារធាតុគីមីខុសច្បាប់ក្នុងមុខទំនិញម្ហូបអាហារ ដែលកើតមានឡើងចំពោះទីតាំងដដែល១ទាំងនោះ ។

### *គ-ការវិភាគគុណភាពទំនិញ*

ក្រៅពីការវិភាគនៅនឹងកន្លែងដោយប្រើប្រាស់ឧបករណ៍ TEST KITS មន្ទីរពិសោធន៍របស់អគ្គនាយក ដ្ឋានកាំកុងត្រូល បានដំណើរការការងាររបស់ខ្លួន ដើម្បីបញ្ជាក់អំពីភាពស្របតាមស្តង់ដារជាតិ ឬអន្តរជាតិ ការកំណត់រក កម្រិតនៃការចម្លងមេរោគ សំណល់ថ្នាំសម្លាប់សត្វល្អិត ឬស្វែងរកសារធាតុគីមីហាមឃាត់ក្នុងម្ហូបអាហារ ។ ក្នុងឆ្នាំ ២០០៩នេះ នាយកដ្ឋានមន្ទីរពិសោធន៍នៃក្រសួងពាណិជ្ជកម្ម បានធ្វើការវិភាគទំនិញចំនួន ២,២៧៨គំរូ ក្នុងនោះមាន ផលិតផលម្ហូបអាហារចំនួន ១,១៧០គំរូ ផលិតផលមិនមែនម្ហូបអាហារចំនួន ៥គំរូ និងប្រេងឥន្ធនៈចំនួន ១,១០៣គំរូ ហើយរកឃើញផលិតផលខុសគោលការណ៍បច្ចេកទេសចំនួន ២២០គំរូ ។

### *ឃ-ការត្រួតពិនិត្យប្រេងឥន្ធនៈ*

បន្ថែមទៅលើការត្រួតពិត្យ និងយកគំរូមកវិភាគលក្ខណៈវិនិច្ឆ័យសំខាន់១នៃគុណភាពប្រេងឥន្ធនៈពេល នាំចូល មន្ត្រីអគ្គនាយកដ្ឋានកាំកុងត្រូល បានអនុវត្តកម្មវិធីត្រួតពិនិត្យចំនួនអុកតានប្រេងសាំង នៅតាមស្ថានីយ៍ចែក ចាយទាំងអស់ ដោយប្រៀបធៀបទៅនឹងការប្រកាសរបស់ស្ថានីយ៍ ។ សកម្មភាពនេះ ធ្វើឡើងដើម្បីធានាភាពស្មោះត្រង់ នៃអាជីវកម្មប្រេងឥន្ធនៈ ការពារផលប្រយោជន៍សេដ្ឋកិច្ចរបស់អ្នកទិញ និងបង្កបរិយាកាសដល់ការប្រកួតប្រជែង ត្រឹមត្រូវក្នុងរង្វង់នៃការធ្វើអាជីវកម្មប្រេងឥន្ធនៈ ។ មានស្ថានីយ៍ប្រេងឥន្ធនៈចំនួន ២៩កន្លែងដែលត្រូវបានចុះត្រួតពិនិត្យ

កម្រិតអុកតានប្រេងសាំង និងទទួលនូវការណែនាំឱ្យអនុវត្តការថែរក្សាគុណភាពប្រេងជូនអតិថិជន។ ប៉ុន្តែ យើងក៏នៅជួបផលលំបាកដែរចំពោះទីតាំងលក់ប្រេងឥន្ធនៈដែលមិនស្របច្បាប់តាមចិញ្ចើមថ្នល់ ដោយសារជាទីតាំងបែបចល័ត ហើយគ្មានប្រភពនាំចូលច្បាស់លាស់។

### ង-ពាក់ព័ន្ធនឹងផលិតផលគីមីកសិកម្ម

ពាក់ព័ន្ធនឹងផលិតផលគីមីកសិកម្ម អគ្គនាយកដ្ឋានកាំកុងត្រូល បានធ្វើការត្រួតពិនិត្យទៅលើផលិតផលជីកសិកម្ម និងថ្នាំសម្លាប់សត្វល្អិត ដែលចរាចរលក់ដូរនៅលើទីផ្សារ ដើម្បីរកឱ្យឃើញថា តើផលិតផលទាំងនោះសមស្របទៅនឹងបញ្ជីឈ្មោះផលិតផលដែលអនុញ្ញាតឱ្យធ្វើចរាចរនៅលើទីផ្សារឬទេ? ការត្រួតពិនិត្យ ក៏ត្រូវបានយកចិត្តទុកដាក់ផងដែរចំពោះការក្លែងបន្លំផលិតផល និងការដាក់តាំងលក់(ថ្នាំសម្លាប់សត្វល្អិត) លាយឡំជាមួយផលិតផលម្ហូបអាហារដទៃទៀត។

### ច-ការត្រួតពិនិត្យពាណិជ្ជកម្ម លក្ខណៈជាភាគីទី៣

ក្នុងតួនាទីជាភាគីទី ៣ បានទទួលអនុវត្តសេវាតាមការស្នើសុំរបស់អតិថិជន ដែលមានជាអាទិ៍ អង្គការស្បៀងអាហារពិភពលោក (World Food Programme -WFP-) ចំនួន ២៥ ករណី (អង្ករ អំបិល ស្ករស ត្រីខកំប៉ុង ម្សៅពោត ម្សៅសណ្តែក ប្រេងឆា .....ក្រុមហ៊ុន SGS THAILAND បានចំនួន ៥១ករណី (សំឡីកប្បាស សំលៀកបំពាក់ បារី) ក្រុមហ៊ុន GREEN TRADE ចំនួន ៣ករណី (អង្ករក្នុងស្រុក) និងការត្រួតពិនិត្យដែលស្នើដោយពាណិជ្ជករ និងអង្គការនានាមានចំនួន ១១ករណី (អង្ករ អំបិល ទឹកត្រី បារី) ក្នុងគោលបំណងពិនិត្យ និងវាយតម្លៃទំនិញនាំចូល-នាំចេញពេលប្រគល់-ទទួល សំដៅបញ្ជាក់អំពីបរិមាណ និងសភាពនៃទំនិញដែលត្រូវប្រគល់-ទទួល និងវាយតម្លៃអំពីការខូចខាត បាត់បង់ ដើម្បីមានមូលដ្ឋានក្នុងការតវ៉ាតាមផ្លូវច្បាប់ បម្រើគោលដៅចាំបាច់ក្នុងកិច្ចការពាណិជ្ជកម្មអន្តរជាតិ។

ពាក់ព័ន្ធនឹងវិស័យកាត់ដេរ ក្រៅអំពីការពិនិត្យផលិតផលសម្រេច សេវាត្រួតពិនិត្យពាណិជ្ជកម្មមានវិសាលភាពទៅលើការវាយតម្លៃអត្ថិភាព សមត្ថភាពផលិតជាក់ស្តែងរបស់រោងចក្រ ទាក់ទងទៅនឹងការបញ្ជាទិញផងដែរ។

### ឆ-កិច្ចការគោលនយោបាយ ពាក់ព័ន្ធនឹងផលិតផល

-កំពុងដំណើរការសម្រួលសេចក្តីព្រាងអនុក្រឹត្យ (ឬប្រកាសអន្តរក្រសួង) អនុម័តនូវបទដ្ឋាននានារបស់ Codex (ស្តង់ដារគោលណែនាំ និងក្រមអនុវត្ត ) ធ្វើជាបញ្ញត្តិបច្ចេកទេសគ្រប់គ្រងគុណភាព សុវត្ថិភាពផលិតផលម្ហូបអាហារ។

-ក្នុងមុខនាទីជាចំណុចទំនាក់ទំនងកិច្ចការអនាម័យ និងភូតគាមអនាម័យ ក្នុងក្របខ័ណ្ឌ WTO (WTO/SPS Inquiry Point) បានតាមដាននូវបច្ចុប្បន្នភាពសេចក្តីជូនដំណឹងវិធានការអនាម័យ និងភូតគាមអនាម័យ របស់បណ្តាប្រទេសជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក និងជាប្រទេសដែលមានសក្តានុពលពាណិជ្ជកម្មជាមួយកម្ពុជា ឬប្រទេសឧស្សាហកម្មជឿនលឿន ឬពីអង្គការ អន្តរជាតិពាក់ព័ន្ធ : CODEX, IPPC OIE ដោយពិនិត្យ និងសិក្សាខ្លឹមសារនៃសេចក្តីជូនដំណឹងទាំងនោះ ដោយជ្រើសរើសអត្ថបទណាដែលអាចមានផលប៉ះពាល់វិជ្ជមាន ឬ

អវិជ្ជមានដល់សេដ្ឋកិច្ចកម្ពុជា ដើម្បីរៀបចំផ្ញើជូនអង្គភាព ស្ថាប័នពាក់ព័ន្ធតាមភារៈកិច្ចរៀង១ខ្លួន ។ កិច្ចការខាងលើត្រូវបានបំពេញឱ្យខាងតែបាននូវការចេញសេចក្តីជូនដំណឹងដែលរៀបចំដោយបណ្តាប្រទេសអាស៊ាន ប្រទេសជប៉ុន កូរ៉េខាងត្បូង ស្រីលង្កា សហរដ្ឋ អាមេរិក សហគមន៍អឺរ៉ុប ណូវែលហ្សេឡង់ អូស្ត្រាលី សឹង្ហបូរី និងកាណាដា ដែលមានការពាក់ព័ន្ធទៅនឹងការងារ សុវត្ថិភាពផលិតផលម្ហូបអាហារ សុខភាពសត្វ និងរុក្ខជាតិ និងត្រូវបានផ្ញើជូនអង្គភាពពាក់ព័ន្ធ ដូចជា ក្រសួងកសិកម្ម ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងសុខាភិបាល។ល។ លើសពីនេះនឹងបានជាមូលដ្ឋានរៀបចំវិធានការត្រៀមលក្ខណៈទប់ស្កាត់ជាមុន ការនាំចូលដាយថាហេតុចំពោះផលិតផលម្ហូបអាហារដែលពុំស្របនឹងល័ក្ខខ័ណ្ឌតម្រូវកំណត់ក្នុងច្បាប់ បទបញ្ញត្តិនៃបណ្តាប្រទេសទាំងនោះ និងជាមូលដ្ឋាននៃការកសាងកម្មវិធីអង្កេតឃ្លាំពិនិត្យទីផ្សារ ។ ជាលទ្ធផល គឺការស្រាវជ្រាវប្រមូលព័ត៌មានស្តីពីការរីកសាយភាយនៃជំងឺ "ផ្តាសាយជ្រូក" (SWINE FLU) និងវិធានការសំរាប់ការពារ ។

ពាក់ព័ន្ធនឹងការអនុវត្តន៍គោលការណ៍គ្រប់គ្រងហានិភ័យ ក្នុងការត្រួតពិនិត្យគុណភាព សុវត្ថិភាព ក្រសួងបានបង្កើតឡើងនូវក្រុមគ្រប់គ្រងហានិភ័យសម្រាប់អគ្គនាយកដ្ឋានកាំកុងត្រូល ដែលមានមន្ត្រីបង្គោលជាសមាជិក ។

### ៣.៧-សកម្មភាពជំរុញពាណិជ្ជកម្ម

#### *៣.៧.១-ការរៀបចំ និងចូលរួមពិព័ណ៌ក្នុង និងក្រៅប្រទេស*

ចូលរួមពិព័ណ៌នៅក្រៅប្រទេសបានចំនួន៣១លើក រៀបចំពិព័ណ៌កម្រិតជាតិក្នុងប្រទេសចំនួន ០២លើក និង រួមសហការជាមួយបរទេស រៀបចំពិព័ណ៌ពាណិជ្ជកម្មបរទេស នៅក្នុងប្រទេសកម្ពុជាមានចំនួន ១៨លើក ។

តាមរយៈនៃការចូលរួម និងរៀបចំពិព័ណ៌ក្នុង និងក្រៅប្រទេស មុខមាត់ និងកិត្យានុភាពជាតិត្រូវបានលើកកំពស់ ដោយសារនេះជាឱកាសដែលញ៉ាំងឱ្យសាធារណៈជន បានស្គាល់អំពីទិដ្ឋភាពទូទៅនៃប្រទេសកម្ពុជា យល់ដឹងពីសិល្បៈវប្បធម៌ អរិយធម៌ខ្មែរ ជាពិសេសជីវភាពពិតនៃប្រជាជនកម្ពុជា ព្រមទាំងជាការបើកផ្លូវនាំទៅដល់ការការចរចាជាលក្ខណៈទ្វេភាគី និងពហុភាគី រវាងដៃគូពាណិជ្ជកម្ម ដោយឈានទៅសម្រេចការចុះហត្ថលេខាលើអនុស្សរណៈ និងគម្រោងវិនិយោគផ្សេងៗ ការចុះកិច្ចសន្យាសេដ្ឋកិច្ច និងបង្កើនចំណងទាក់ទងពាណិជ្ជកម្មទៅវិញទៅមក ធ្វើឱ្យផលិតផលរបស់កម្ពុជាដែលយកទៅតាំងពិព័ណ៌ត្រូវបានផ្សព្វផ្សាយ ទទួលស្គាល់ដោយអតិថិជនជាតិអន្តរជាតិ ទទួលបានការបញ្ជាទិញច្រើនជាងមុន ។ ទន្ទឹមនឹងនេះ ក្រសួងតែងតែបង្កលក្ខណៈងាយស្រួលឱ្យបណ្តាក្រុមហ៊ុនឯកជន និងបរទេស មករៀបចំតាំងពិព័ណ៌ក្នុងស្រុកជាច្រើនលើក ជាការធ្វើឱ្យចំណងទាក់ទងរវាងប្រទេសជាដៃគូក្នុងវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម កាន់តែមានសកម្មភាពប្រសើរឡើង។ លំហូរព័ត៌មានទីផ្សាររវាងខេត្ត ទីប្រជុំជន និងទីក្រុងនានានៅក្នុងប្រទេសត្រូវបានផ្លាស់ប្តូរ និងកែលម្អ ធ្វើឱ្យផលិតផលប្រើប្រាស់ក្នុងស្រុក ត្រូវបានអតិថិជនទទួលស្គាល់ ជំរុញឱ្យមានការកែលម្អគុណភាព និងម៉ូដផលិតផល ដែលអ្វីៗទាំងអស់នេះពិតជាបាន រុញច្រានផលិតផលខ្មែរជ្រៀតចូលទៅក្នុងទីផ្សារបរទេស ដូចដែលយើងបានឃើញនូវតួលេខនាំចេញផលិតផលខ្មែរនៅផ្នែកខាងដើម ដែលក្នុងនោះ មុខទំនិញជាកសិផល បាននាំចេញទៅកាន់ទីផ្សារអន្តរជាតិជាបន្តបន្ទាប់ ។

ព្រឹត្តការណ៍សំខាន់ក្នុងវិស័យនេះមួយទៀតគឺ ការតាំងពិព័ណ៌នាំចេញ នាំចូលកម្រិតជាតិ និងខេត្តមួយផលិតផលមួយប្រចាំឆ្នាំ (ឆ្នាំ២០០៩នេះ ជាឆ្នាំលើកទី៤) ដើរទន្ទឹមគ្នានឹងវេទិកាពាណិជ្ជកម្ម ជំនួបពាណិជ្ជកម្ម

ធ្វើឱ្យទស្សនៈស្ដីពីខេត្តមួយផលិតផលមួយ ត្រូវបានទទួលការគាំទ្រ និងកាន់តែមានលក្ខណៈសកម្មថែមទៀត ជាប្រភព នាំមកនូវការងារធ្វើសម្រាប់ពលរដ្ឋខ្មែរ និងផ្ដល់នូវផលចំណូលដោយប្រយោលដល់ថវិកាជាតិ។

### ៣.៧.២-ការតាមដានទីផ្សារ និងស្ថេរភាពថ្លៃ

បានចាត់ចែងឱ្យចុះណែនាំការបិទស្លាកថ្លៃលើមុខទំនិញ និងសេវាកម្មគ្រប់ប្រភេទ ដោយតាមដានជាប្រចាំថ្លៃទំនិញសំខាន់ៗ នៅលើទីផ្សារអន្តរជាតិដូចជា អង្ករ សណ្ដែក កៅស៊ូ កាហ្វេ ដែក ប្រេងឥន្ធនៈ មាស និងអត្រាប្ដូរប្រាក់នៃរូបិយវត្ថុអន្តរជាតិមានតម្លៃនានា រួមមានៈ ប្រាក់ដុល្លា ប្រាក់ផោន ប្រាក់អឺរ៉ូ ប្រាក់យ៉េនជប៉ុន និងលុយបាតជាដើម ដើម្បីចងក្រងការវិវត្តន៍ និងវិភាគតម្លៃទំនិញទាំងនេះ ជាគុណប្រយោជន៍ដល់អ្នកនាំចេញកម្ពុជាស្វែងយល់ និងតម្រែតម្រង់ទិសអាជីវកម្មរបស់គេឱ្យសមស្របនឹងនិន្នាការក្នុង និងក្រៅស្រុក។

### ៣.៧.៣-ការងារអភិវឌ្ឍន៍ផលិតផល និងស្វែងរកទីផ្សារជូនពាណិជ្ជករ និងកសិករ

ជាទិសដៅយុទ្ធសាស្ត្រ ក្នុងការអភិវឌ្ឍន៍ផលិតផលក្នុងស្រុក សំដៅនាំយកផលិតផលទាំងនោះ ឱ្យដល់ទីផ្សារគោលដៅ ក្រសួងពាណិជ្ជកម្មបានជួយរៀបចំជួយដល់អ្នកផលិតឱ្យបង្កើតជាសមាគមផលិត សមាគមអាជីវកម្ម ចូលរួមដោយពេញលេញក្នុងសកម្មភាពនាំចេញមុខទំនិញរបស់ពួកគេដោយផ្ទាល់ ឬតាមរយៈដៃគូពាណិជ្ជករនាំចេញធំៗ នៅក្នុងប្រទេស។ សមាគមទាំងនោះ បានទទួលការបណ្ដុះបណ្ដាលអំពីបច្ចេកវិទ្យាថ្មីៗ អំពីនីតិវិធីនៃការស្វែងរកកម្ចីឥណទាន អំពីព័ត៌មានទីផ្សារទាំងក្នុង និងក្រៅប្រទេស តួយ៉ាងដូចជា ការអភិវឌ្ឍន៍ផលិតផលដំឡូងមី ដែលបានស្វែងរកដៃគូពាណិជ្ជកម្មដំឡូងមីនៅតំបន់ស្វ័យត ខេត្តក្វាងស៊ី ប្រទេសចិន ព្រមទាំងទទួលបានការសម្របសម្រួលក្នុងការនាំចេញដំឡូងមី តាមកំពង់ផែឡាមឆាបាំងនៃប្រទេសថៃ ទៅកាន់ប្រទេសទី៣ទៀតផង។

ផលិតផលស្វាយចន្ទី ត្រូវបានអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាពខ្ពស់។ យើងបានដឹកនាំប្រតិភូសមាគមស្វាយចន្ទីចំនួន ១៧នាក់ ទៅទស្សនៈកិច្ចសិក្សាលើការងារអភិវឌ្ឍន៍ផលិតផលស្វាយចន្ទីនៅប្រទេសវៀតណាម។ នៅអំឡុងឆ្នាំ ២០០៩នេះ មានការផ្លាស់ប្ដូរគណៈប្រតិភូស្វាយចន្ទីកម្ពុជា-វៀតណាម ចំនួន ៤ដង រហូតដល់ចុងឆ្នាំ ២០០៩ មានការចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា ស្ដីពីការពង្រឹងសមត្ថភាពផ្គត់ផ្គង់គ្រាប់ស្វាយចន្ទី រវាងខេត្តដុងណាយ ជាមួយខេត្តកំពង់ចាម និងខេត្តកំពង់ធំ ក្នុងនោះ មានកិច្ចសហប្រតិបត្តិការគ្នាតាំងពីការរៀបចំពូជស្វាយចន្ទីដែលមានគុណភាព និងបរិមាណច្រើន ការត្រួតពិនិត្យតំបន់ដាំដុះសមស្របជាមួយដំណាំស្វាយចន្ទី ការបង្កើតមជ្ឈមណ្ឌលប្រមូលទិញគ្រាប់ស្វាយចន្ទី និងត្រៀមបង្កើតរោងចក្រកែច្នៃស្វាយចន្ទី។

### ៣.៧.៤-ការងារអភិវឌ្ឍន៍ពាណិជ្ជកម្ម និងសកម្មភាពពង្រឹងដៃគូពាណិជ្ជកម្ម :

### ការងារអភិវឌ្ឍន៍ពាណិជ្ជកម្ម

បាន និងកំពុងតែធ្វើការសិក្សាស្រាវជ្រាវបន្ថែមទៀតទៅលើ **Value Chain Unit** ដែលជាជំហ៊ានដំបូង គឺធ្វើការស្វែងយល់អំពី Trade Map & Market Access ព្រមទាំងបានចុះធ្វើការសិក្សាស្រាវជ្រាវដោយផ្ទាល់ជាមួយ កសិករ ពាណិជ្ជករ និងអ្នកកែច្នៃ ដើម្បីស្វែងយល់អំពីសង្វាក់ផលិតកម្មនៃផលិតផលសក្ដានុពល ក្នុងគោលបំណង ចងក្រង និងផ្សព្វផ្សាយព័ត៌មានដល់បណ្ដាអាជីវករ ពាណិជ្ជករ និងអ្នកវិនិយោគទាំងក្នុង និងក្រៅប្រទេស ដើម្បី ជំរុញការអភិវឌ្ឍន៍ផលិតផលកម្ពុជា ជាជំហ៊ានៗឆ្ពោះទៅកាន់ទីផ្សារពិភពលោក ។

*Trade Map*:

-ជ្រើសរើសផលិតផល (លេខកូដផលិតផល)

-វិភាគអំពីទីផ្សារនាំចូល និងវាយតម្លៃការប្រកួតប្រជែងជាមួយនិងសូចនាករពាណិជ្ជកម្ម

-តើបរិមាណនាំចូលផលិតផលរបស់ទីផ្សារពិភពលោកមានចំនួនប៉ុន្មាន ?

-តើប្រទេសណាដែលនាំផលិតផលចូលច្រើនជាងគេ ? (បរិមាណផលិតផលសរុប និងតម្លៃ)

-តើសូចនាករនៃតម្រូវការទីផ្សារពិភពលោក គឺជាការប្រមូលផ្ដុំនៃផលិតផលដែរឬទេ?

-តម្លៃមធ្យមភាគនៃផលិតផល

-ទិន្នន័យ និងការកើនឡើងខ្ពស់នៃទីផ្សារនាំចូល

-សក្ដានុពលទីផ្សារ

*Market Access*:

-ពន្ធអាករលើផលិតផលនាំចូល

-ចុះធ្វើការសិក្សាស្រាវជ្រាវដោយផ្ទាល់ជាមួយកសិករ អ្នកប្រមូលទិញ និងរោងចក្រកែច្នៃ (ឧទាហរណ៍ដូចជា ការធ្វើការវិភាគទៅលើសង្វាក់ផលិតកម្មរបស់ដំណាំដំឡូងមីជាដើម)

### សកម្មភាពពង្រឹងដៃគូពាណិជ្ជកម្ម

បានរួមសហការជាមួយដៃគូពាណិជ្ជកម្ម ក្នុងតំបន់អាស៊ីអាគ្នេយ៍ ដើម្បីជំរុញពាណិជ្ជកម្ម និងវិនិយោគពីបរទេសមកកម្ពុជា និងជំរុញការនាំចេញផលិតផល និងសេវាកម្ម មានដូចជា :

-មជ្ឈមណ្ឌលអាស៊ាន-ជប៉ុន ASEAN-Japan Centre

-មជ្ឈមណ្ឌលអាស៊ាន-កូរ៉េ ASEAN-Korea Centre

-មជ្ឈមណ្ឌលអាស៊ាន-ចិន ASEAN-China Centre

-វេទិកាជំរុញពាណិជ្ជកម្មអាស៊ីអាគ្នេយ៍ Asia Trade Promotion Forum-ATPF

-អង្គការ JETRO (Japan External Trade Organization )

-សមាគមអាហារូបករណ៍ The Association for Oversea Technical Scholarship -AOTS

### ៤-សមិទ្ធកម្មសេដ្ឋកិច្ច និងទំហំពាណិជ្ជកម្មនាំចេញ-នាំចូល

យោងតាមស្ថិតិរបស់ធនាគារជាតិនៃកម្ពុជា ពាណិជ្ជកម្មនាំចេញ-នាំចូលនៅឆ្នាំ២០០៨ បានកើនឡើងចំនួន ១៦,៧ % គឺពី ៩,៦ ពាន់លានដុល្លារ នៅឆ្នាំ២០០៧ ទៅ ១១,២ពាន់លានដុល្លារនៅឆ្នាំ២០០៨។ ក៏ប៉ុន្តែ នៅឆ្នាំ ២០០៩ ដោយសារផលប៉ះពាល់ដែលមិនអាចប៉ាន់ប្រមាណជាមុនពីវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសកលលោក ក៏ដូចជាប្រទេសជាច្រើនក្នុងពិភពលោកដែរ ពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជាបានធ្លាក់ចុះចំនួន ១០,៤% គឺពីមកនៅត្រឹម ១០ ពាន់លានដុល្លា។ ក្នុងនេះ ការនាំចេញតាមប្រពន្ធ័អនុគ្រោះពាណិជ្ជកម្ម បានធ្លាក់ចុះចំនួន ១៩,៤៦% គឺពី ៣,២ ពាន់លានដុល្លារ មកនៅត្រឹម ២,៧ ពាន់លានដុល្លារនៅឆ្នាំ២០០៩ នៅពេលដែលការនាំចេញនៅឆ្នាំ ២០០៨ មានកំណើន ២% ។

ទោះបីយ៉ាងណា សមិទ្ធកម្មសេដ្ឋកិច្ចជាទូទៅមិនអាក្រក់ពេកនោះទេ ដែលក្នុងនោះ តាមការបូកសរុបជាបឋមនាពេលថ្មីៗនេះ ផលិតផលក្នុងស្រុកសរុប សម្រាប់ឆ្នាំ២០០៩ ត្រូវបានប៉ាន់ស្មានថានឹងមានកំណើនវិជ្ជមាន ទោះបី

ក្នុងទំហំតូចក៏ដោយ ដោយសារវិស័យកសិកម្ម និងសេវា រក្សាបានកំណើនល្អប្រសើរ និងសមរម្យក្នុងកម្រិត ៥,៤% និង ២,៣% ដែលទប់ទល់បាននឹងការធ្លាក់ចុះក្នុងវិស័យឧស្សាហកម្ម (ដែលមានកំណើនអវិជ្ជមានក្នុងទំហំប្រមាណ -៩,៥%) ពិសេសគឺវិស័យកាត់ដេរ (ដែលមានកំណើនអវិជ្ជមានក្នុងទំហំប្រមាណ -៩%)។ គួរកត់សម្គាល់ថា ផ្នែកផ្សេងៗនៃវិស័យសេវា សុទ្ធតែមានកំណើនវិជ្ជមាន លើកលែងតែវិស័យអចលនវត្ថុ ដែលមានកំណើនអវិជ្ជមានប្រមាណ -២,៥%។ វិស័យទេសចរណ៍ក៏បានទទួលរងគ្រោះដោយសារវិបត្តិ ជាហេតុធ្វើឱ្យកំណើនវិស័យសណ្ឋាគារ និងភោជនីយដ្ឋានមានកម្រិតត្រឹមតែប្រមាណ ១,៨%។ វិនិយោគផ្ទាល់ពីបរទេសបានធ្លាក់ចុះមួយចំនួន មកនៅត្រឹមជាង ៥០០លានដុល្លារ ក្នុងឆ្នាំ២០០៩ ប៉ុន្តែ នៅតែជាចំនួនដ៏ច្រើនសម្រាប់ជួយទ្រទ្រង់សេដ្ឋកិច្ចកម្ពុជា។ ដូច្នេះ សេដ្ឋកិច្ចមិនទទួលរងផលប៉ះពាល់ខ្លាំងពេកទេពីវិបត្តិ តាមរយៈវិស័យហិរញ្ញវត្ថុ (ដោយសារវិស័យនេះ មិនទាន់អភិវឌ្ឍដល់កម្រិតខ្ពស់នៅឡើយ) ប៉ុន្តែ រងគ្រោះតាមរយៈពាណិជ្ជកម្ម និងការវិនិយោគ ហើយដែលត្រូវបានរាជរដ្ឋាភិបាលដាក់វិធានការជួយកាត់បន្ថយសម្រាលផលប៉ះពាល់ទាំងនេះ បានយ៉ាងទាន់ពេលវេលា។

## កសាងភាពជាដៃគូក្នុងការអភិវឌ្ឍន៍តាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិ

### *កសាងភាពជាដៃគូ*

-សហការជាមួយមន្ត្រីគយសហគមអឺរ៉ុប ក្នុងការឆ្លើយបំភ្លឺនូវរាល់បញ្ហា ឬចម្ងល់នានារបស់គយនៃប្រទេសនាំចូល ចំពោះវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញរបស់ក្រសួងពាណិជ្ជកម្មបានចំនួន ៧០៥ករណី។

-សហប្រតិបត្តិការល្អជាមួយអង្គការ ILO ក្នុងការជួយជំរុញលិខិតស្នាមទៅជូនស្ថាប័នពាក់ព័ន្ធ ក្នុងការរកប្រភពហិរញ្ញប្បទាន ដើម្បីទ្រទ្រង់គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា ។

-សហការជាមួយអង្គការខាងលើ ក្នុងការចុះអនុស្សរណៈនៃការយោគយល់ ដើម្បីបន្តអាណត្តិរបស់អង្គការ ILO ដល់ឆ្នាំ ២០១០។

-កសាងទំនាក់ទំនងល្អជាមួយស្ថានទូតសហរដ្ឋអាមេរិក កាណាដា និងតំណាងប្រតិភូពាណិជ្ជកម្មសហគមន៍អឺរ៉ុប ជាពិសេសផ្នែកសេដ្ឋកិច្ច និងពាណិជ្ជកម្ម។

### *កិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម*

អនុវត្តតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២របស់រាជរដ្ឋាភិបាល និងផែនការសកម្មភាពអនុវត្តគោលនយោបាយពាណិជ្ជកម្មជាយុទ្ធសាស្ត្ររបស់ក្រសួងពាណិជ្ជកម្ម បានចរចា និងចុះហត្ថលេខាលើកិច្ចព្រមព្រៀង អនុស្សរណៈ និងកំណត់ហេតុការងារជាលក្ខណៈទ្វេភាគី រួមមាន :

<u>ជាមួយសាធារណៈរដ្ឋសង្គមនិយមវៀតណាម</u>

-រៀបចំកិច្ចប្រជុំស្ដីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្មលើកទី១ ថ្នាក់រដ្ឋមន្ត្រី រវាងក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្មនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម។ ជាលទ្ធផលភាគីទាំងពីរបានចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នា នៅរាជធានីភ្នំពេញថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៩ ដែលក្នុងខណៈនោះ ក៏មានចុះហត្ថលេខាលើអនុស្សរណៈស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ពាណិជ្ជកម្មព្រំដែនលើកទី២ រវាងក្រសួងពាណិជ្ជកម្មនៃប្រទេសទាំងពីរ។

-ចុះពិនិត្យ និងសិក្សាទីតាំងភូមិសាស្ត្រនៅតំបន់សេដ្ឋកិច្ចពិសេសថារីកំពង់ចាម សម្រាប់គម្រោងសាងសង់ផ្សារគំរូព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម។

-ទំនាក់ទំនងជាមួយស្ថានតំណាងពាណិជ្ជកម្មវៀតណាម ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដើម្បីជំរុញ និងអនុវត្តនីការផ្តល់ព័តិមាន និងកិច្ចសហប្រតិបត្តិការកម្ពុជា-វៀតណាម ។

<u>កិច្ចសហប្រតិបត្តិការជាមួយសហគមន៍អឺរ៉ុប</u>

-បញ្ជូនទិន្នន័យនៃការចេញវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញទម្រង់**អេ**(C/O Form A) នៃផលិតផលសំលៀកបំពាក់ ស្បែកជើង និងផលិតផលផ្សេងៗទៀតរបស់កម្ពុជាទៅកាន់ SIGL ដែលមានទីស្នាក់ការនៅទីក្រុងប្រ៊ុយសែល ប្រទេសប៊ែលហ្សិក។

-ចូលរួមប្រជុំសិក្សាស្រាវជ្រាវ លើការទប់ស្កាត់ការនាំចូលផលិតផលដែលមានសារធាតុគីមី Dimethyl Fumarate (DMF) ក្នុងការផលិតស្បែកជើង និងការផលិតនូវផលិតផលធ្វើអំពីស្បែកផ្សេងៗទៀត ដែលនាំចេញទៅកាន់ទីផ្សារសហគមន៍អឺរ៉ុប។

-ទទួលរៀបចំ និងអមដំណើរការចុះធ្វើអធិការកិច្ចរបស់គណៈប្រតិភូអធិការកិច្ចពាណិជ្ជកម្ម នៃគណៈកម្មការសហគមន៍អឺរ៉ុប (European Anti - Fraud Office-OLAF) លើផលិតផលទោចក្រយាន នាំចេញទៅសហគមន៍អឺរ៉ុប នៅតំបន់សេដ្ឋកិច្ចពិសេសមេនហាតធេន និងតាយសេង ខេត្តស្វាយរៀង និងចុះធ្វើអធិការកិច្ចលើផលិតផលស្បែកជើង នាំចេញទៅសហគមន៍អឺរ៉ុប។

-ធ្វើការស្រាវជ្រាវបញ្ហាទាក់ទិនទៅនឹងវិធានប្រភពដើមទំនិញ សម្រាប់ធ្វើការនាំចេញផលិតផលស្ករស និងអង្ករ ទៅកាន់ទីផ្សារសហគមន៍អឺរ៉ុប ក្រោយពេលដែលសហគមន៍អឺរ៉ុបលុបកូតា។

-ទំនាក់ទំនងជាមួយតំណាងសហគមន៍អឺរ៉ុបប្រចាំនៅភ្នំពេញ ដើម្បីបញ្ជូននូវព័តិមាននៃការចេញវិញ្ញាបនប័ត្រប្រភពដើមទំនិញ C/O និងការប្រើប្រាស់ Derogation ទៅសហគមន៍អឺរ៉ុប ជាប្រចាំខែ និងរៀបចំពង្រីកប្រព័ន្ធ data ថ្មី ក្នុងការបញ្ជូនទិន្នន័យនៃ C/O Form A ដែលមានលក្ខណៈទំនើបជាងមុន។

<u>កិច្ចប្រជុំអន្តររដ្ឋាភិបាល ( JC )</u>

បានរៀបចំខ្លឹមសារសម្រាប់ថ្នាក់ដឹកនាំក្រសួងនិងចូលរួមកិច្ចប្រជុំអន្តររដ្ឋាភិបាលចំនួន៣លើក ដូចជា:

-កិច្ចប្រជុំស្តីពីកិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍រវាងបណ្តាខេត្តជាប់ព្រំដែនកម្ពុជាវៀតណាម លើកទី៥ នៅទីក្រុងហូជីមិញ នៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម។

-កិច្ចប្រជុំលើកទី៥ របស់គណៈកម្មការអន្តររដ្ឋាភិបាលរវាងកម្ពុជា-រុស្ស៊ី ស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម សេដ្ឋកិច្ច វិទ្យាសាស្ត្រ និងបច្ចេកទេស នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ ជាលទ្ធផលទទួលបានគឺ: ភាគីកម្ពុជាស្នើឱ្យភាគីរុស្ស៊ីពិចារណាពីលទ្ធភាពរួមបញ្ចូលផលិតផលកម្ពុជាមួយចំនួន ទៅក្នុងប្រព័ន្ធអនុគ្រោះពន្ធទូទៅរបស់សហព័ន្ធរុស្ស៊ីដល់ផលិផលកម្ពុជាមួយចំនួន ដែលបញ្ជីនៃផលិតផលទាំងនោះ ភាគីកម្ពុជាកំពុងរៀបចំដើម្បីផ្ញើជូនភាគីរុស្ស៊ី។

-ចូលរួមប្រជុំគណៈកម្មការចំរុះកម្ពុជា-វៀតណាម លើកទី១១ ស្តីពីកិច្ចសហប្រតិបត្តិការ សេដ្ឋកិច្ច វិទ្យាសាស្ត្រ និងបច្ចេកទេស នៅខេត្តព្រះសីហនុ ។

## ៥-សកម្មភាពបម្រើឱ្យសមាហរណកម្មកម្ពុជាក្នុងតំបន់ និងពិភពលោក

### *៥.១-សមាហរណកម្មតំបន់ និងអនុតំបន់*

### *ក-សមាហរណកម្មពាណិជ្ជកម្មផ្នែកទំនិញ*

បានចូលរួមចរចា និងតាមដានការងារពាណិជ្ជកម្មផ្នែកទំនិញ ទាំងនៅក្នុងកិច្ចប្រជុំក្រុមគណៈកម្មាធិការ កិច្ចប្រជុំឧត្តមមន្ត្រីសេដ្ឋកិច្ចអាស៊ាន និងកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន។ លទ្ធផលដែលទទួលបានពីកិច្ចប្រជុំរួមមាន :

-កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន (ATIGA) ត្រូវបានរដ្ឋសភាផ្តល់សច្ចាប័ន ប្រកាសឱ្យប្រើប្រាស់តាមព្រះរាជក្រមលេខ នស/រកម/០៩០៨ /០១៧ ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៩។ អនុលោមតាមព្រះរាជក្រមនេះ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានផ្ញើសេចក្តីជូនដំណឹងទៅលេខាធិការដ្ឋានអាស៊ាន ស្តីពីការប្រកាសឱ្យប្រើប្រាស់កិច្ចព្រមព្រៀងនេះរួចហើយដែរ ។

-ការអនុវត្តន៍ការសន្យាគម្រោង CEPT 2009 របស់ប្រទេសសមាជិក : ផលិតផលចំនួន ៩៩.០៩% នៃបន្ទាត់ពន្ធគយ ត្រូវផ្ទេរចូលទៅបញ្ជីកាត់បន្ថយពន្ធគយរួម (IL) ហើយ ៩៧.១៤% នៃផលិតផល មានអត្រាពន្ធគយទាប គឺពី 0-៥% ។ អត្រាពន្ធគយរវាងប្រទេសសមាជិកត្រូវបានលុបបំបាត់បានចំនួន ៦៩.៩៥% នៃផលិផលក្នុង IL ។

-បានកត់សំគាល់ពីវឌ្ឍនភាពនៃការរៀបចំតារាងពិន្ទុ សម្រាប់សហគមន៍សេដ្ឋកិច្ចអាស៊ាននៅក្នុងការអនុវត្តន៍វិធានការទាំងឡាយដែលមានក្នុងផែនការលម្អិតរបស់សហគមន៍ ដើម្បីធ្វើឱ្យប្រាកដថា ការធ្វើសមាហរណកម្មសេដ្ឋកិច្ច នឹងទទួលបានលទ្ធផលល្អប្រសើរ ។

-បានឯកភាពអនុម័តតាមសំណើរបស់កម្ពុជា ស្តីពីការផ្តល់វិញ្ញាបនប័ត្រប្រភពដើមទំនិញទម្រង់ A ដោយប្រទេសសមាជិកអាស៊ាន សម្រាប់ផលិតផលដែលត្រូវនាំចេញបន្តទៅកាន់ទីផ្សារសហភាពអឺរ៉ុប ក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ។

### *ខ-សមាហរណកម្មពាណិជ្ជកម្មផ្នែកសេវាកម្ម*

ក្នុងនាមជាអ្នកសម្របសម្រួលការងារសេវាកម្មអាស៊ាន សម្រាប់កម្ពុជា ក្នុងនាមជាលេខាធិការដ្ឋានចំណុះឱ្យឧត្តមមន្ត្រីសេដ្ឋកិច្ចអាស៊ាន និងរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន មន្ត្រីក្រសួងពាណិជ្ជកម្មបានចូលរួមយ៉ាងសកម្ម និងតាមដានការងារសេវាកម្មអាស៊ាននេះ។ លទ្ធផលមួយចំនួន ដែលទទួលបានមានដូចខាងក្រោម :

-កត់សំគាល់ពីភាពចាំបាច់ ក្នុងការបើកច្រកទីផ្សារសេវាកម្មបន្ថែមទៀត ក្នុងជុំចរចាបន្តបន្ទាប់ដើម្បីជួយជំរុញពាណិជ្ជកម្មផ្នែកទំនិញ និងវិនិយោគក្នុងតំបន់។

-ដោយសេវាកម្មជាវិស័យដែលមានលក្ខណៈស្មុគស្មាញ ប្រទេសសមាជិកបានទទួលស្គាល់ភាពចាំបាច់នៃការអនុវត្តន៍ភាពទន់ភ្លន់រហូតដល់ ១៥% លើរបៀបផ្គត់ផ្គង់សេវាសរុប នៅគ្រប់កញ្ចប់សន្យាផ្តល់ ហើយប្រើសម្រាប់តែក្នុងពេលចាំបាច់ប៉ុណ្ណោះ។ ក្រៅពីនេះ ក៏កំពុងពិចារណាលើផ្នែកសេវាដែលនៅសេសសល់ ដើម្បីលើកគំនិតដាក់ចេញជាអនុសាសន៍សម្រាប់ការអនុវត្តទិសដៅបន្ត។

## ៥.២-ការចរចាបង្កើតតំបន់ពាណិជ្ជកម្មសេរីជាមួយប្រទេសដៃគូអាស៊ាន

### ក-កិច្ចប្រជុំពិគ្រោះយោបល់រវាងអាស៊ាន-ចិន

បន្ទាប់ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ ត្រូវបានអនុវត្តការកាត់បន្ថយពន្ធគយ និងលុបចោលនូវពន្ធគយ កាលពីឆ្នាំ ២០០៥ ការធ្វើពាណិជ្ជកម្មរវាងភាគីទាំងពីរបានកើនដល់ ១៩២.៥ពាន់លានដុល្លា ក្នុងឆ្នាំ២០០៨ ធ្វើឱ្យប្រទេសចិនក្លាយជាប្រទេសដៃគូពាណិជ្ជកម្មធំទី៣របស់អាស៊ាន ដែលមានអត្រាស្មើនឹង ១១.៣% នៃពាណិជ្ជកម្មសរុបរបស់អាស៊ាន។

-ភាគីទាំងពីរ បានស្វាគមន៍ចំពោះការបង្កើតមូលនិធិសហប្រតិបត្តិការវិនិយោគអាស៊ាន-ចិន ក្នុងរង្វង់ទឹកប្រាក់ចំនួន ១០ពាន់លានដុល្លា សម្រាប់ទ្រទ្រង់គម្រោងកិច្ចសហប្រតិបត្តិការវិនិយោគសំខាន់ៗ ដូចជា វិស័យហេដ្ឋារចនាសម្ព័ន្ធធនធាន និងថាមពលបច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មាន ព្រមទាំងវិស័យដទៃទៀត ហើយទឹកប្រាក់ចំនួន ១៥ពាន់លានដុល្លាទៀត ជាឥណទានសម្រាប់សម្របសម្រួលការធ្វើសមាហរណកម្មអាស៊ាន និងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ាន-ចិន លើវិស័យហេដ្ឋារចនាសម្ព័ន្ធ ក្នុងរយៈពេលពី ៣ ទៅ ៥ឆ្នាំខាងមុខ។

### ខ-ការពិភាក្សាលើបញ្ហាចរចាអាស៊ាន-សហភាពអឺរ៉ុប

នៅឯកិច្ចប្រជុំគណៈកម្មាធិការចំរុះ អាស៊ាន-សហភាពអឺរ៉ុប ក្នុងខែ មីនា ឆ្នាំ ២០០៩ ភាគីទាំងពីរបានសម្រេចផ្អាកការចរចា ដោយសារជួបប្រទះនូវបញ្ហាលំបាកជាក់ស្តែង និងបញ្ហារសើបជាច្រើន។ សហភាពអឺរ៉ុប បានបង្ហាញពីបំណងចង់ចរចាតាមរបៀបទ្វេភាគី ឬតាមក្រុមប្រទេសដែលអាចធ្វើបាន ហើយជាពិសេស សហភាពអឺរ៉ុបនឹងមិនធ្វើការចុះហត្ថលេខាណាមួយជាមួយប្រទេសមីយ៉ាន់ម៉ាឡើយ។ ប្រទេសសមាជិកអាស៊ានបានផ្លាស់ប្តូរយោបល់ទៅលើបញ្ហាទាំងនេះ និងបានលើកឡើងថា សហភាពអឺរ៉ុបកំពុងតែធ្លាក់ជ្រៅក្នុងវិបត្តិសេដ្ឋកិច្ចពិភពលោក ដែលទំនងមិនអំណោយផលឱ្យសហភាពអឺរ៉ុបធ្វើការចរចាពាណិជ្ជកម្មសេរីនាដំណាក់កាលនេះទេ។ ម្យ៉ាងទៀត ការចរចាតាមបែបទ្វេភាគី រួចដាក់បញ្ចូលជាតំបន់ ដូចជាការចរចាពាណិជ្ជកម្មសេរីអាស៊ាន-ជប៉ុន ឬការចរចាតាមក្រុមប្រទេស ក៏មិនអាចទៅរួចដែរ ពីព្រោះទីបំផុត ត្រូវមានប្រទេសមីយ៉ាន់ម៉ាចូលរួមដដែល។ ដូច្នេះសហភាពអឺរ៉ុប គួរដោះស្រាយរឿងផ្ទាល់ខ្លួនជាមួយមីយ៉ាន់ម៉ាសិន ទើបអាចបន្តការចរចាបាន។

### គ-កិច្ចប្រជុំពិគ្រោះយោបល់រវាងអាស៊ាន-កូរ៉េ

-កិច្ចព្រមព្រៀងពាណិជ្ជកម្ម រវាងអាស៊ាន-កូរ៉េ ត្រូវបានទទួលការយល់ព្រមដាក់ឱ្យប្រើប្រាស់ពីព្រះមហាក្សត្រ និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា កាលពីពេលកន្លងទៅនេះ។

-ពាណិជ្ជកម្មសរុបរវាងអាស៊ាន-កូរ៉េ បានកើនក្នុងអត្រា ២៣.៤% ពោលគឺកើនដល់ ៧៥.៥ពាន់លានដុល្លា ក្នុងឆ្នាំ ២០០៩ បើប្រៀបធៀបទៅនឹងឆ្នាំ ២០០៨ កើនបានតែ ៩.៥% ស្មើនឹង ៦១ពាន់លានដុល្លាប៉ុណ្ណោះ។

-ភាគីទាំងពីរ បានទទួលស្គាល់នូវការបង្កើតនូវបណ្តាញ អាស៊ាន-កូរ៉េ ស្តីពីការគ្រប់គ្រងសុវត្ថិភាពផលិតផលបសុសត្វ និងការផ្លាស់ប្តូរព័ត៌មានស្តីពីបទបញ្ញត្តិ និងស្តង់ដារបច្ចេកទេស នៅក្នុងវិស័យអគ្គិសនីអេឡិចត្រូនិកបច្ចេកវិទ្យា។ល។

-ប្រទេសសមាជិកអាស៊ាន បានសំដែងការស្វាគមន៍ចំពោះប្រទេសកូរ៉េ លើការជួយឧបត្ថម្ភលើកទី២ នូវចំនួនទឹកប្រាក់ ៥០០,០០០ដុល្លា ដល់មូលនិធិសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ាន-កូរ៉េ ដែលមកទល់នឹងពេលនេះ ទឹកប្រាក់ជំនួយឧបត្ថម្ភមានចំនួនសរុបរហូតដល់ ១លានដុល្លា ហើយក៏បានស្វាគមន៍ព័ត៌មានស្តីពីការផ្តល់ជំនួយឧបត្ថម្ភលើកទី៣ ក្នុងទឹកប្រាក់ប្រហែល ៥០០,០០០ដុល្លាទៀត ដល់មូលនិធិសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ាន-កូរ៉េ សម្រាប់ឆ្នាំ ២០១០ ដែលពិតណាស់ ជំនួយនេះនឹងបានដល់ការបង្កើនលទ្ធភាពនៃការពង្រឹងកិច្ចសហប្រតិបត្តិការរវាងភាគីទាំងពីរ ។

### ឃ-កិច្ចពិគ្រោះយោបល់រវាងអាស៊ាន-ឥណ្ឌា

ប្រទេសសមាជិកអាស៊ាន និងប្រទេសឥណ្ឌា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពី ពាណិជ្ជកម្មទំនិញ យន្តការដោះស្រាយវិវាទ ពិធីសារស្តីពីវិសោធនកម្មកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយអាស៊ាន-ឥណ្ឌា និងអនុស្សរណៈនៃការយោគយល់គ្នាលើមាត្រា៤ (ការកាត់បន្ថយ និងការលុបពន្ធនាំចូល) ។ កិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញ ដែលជាឯកសារស្ថិតក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងអាស៊ាន-ឥណ្ឌា។ ភាគីទាំងពីរ ឯកភាពខិតខំបំពេញនីតិវិធីក្នុងស្រុកឱ្យបានឆាប់ ដើម្បីឱ្យកិច្ចព្រមព្រៀង តំបន់ពាណិជ្ជកម្មសេរីអាស៊ានផ្នែកទំនិញនេះ បានចូលជាធរមានតាមពេលកំណត់ គឺនៅថ្ងៃទី ០១ ខែ មករា ឆ្នាំ២០១០ ។

### ង-កិច្ចពិគ្រោះយោបល់រវាងអាស៊ាន-អូស្ត្រាលី និងណូវែលហ្សេឡង់

-កិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរី អាស៊ាន-អូស្ត្រាលី និង ណូវែលហ្សេឡង់ ត្រូវបានចុះហត្ថលេខាកាលពីថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ ដោយប្រទេសសមាជិកអាស៊ាន ជាមួយនឹងអូស្ត្រាលី និងណូវែលហ្សេឡង់។ កិច្ចព្រមព្រៀងនេះ ចាប់ផ្តើមអនុវត្តនៅថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៩ សម្រាប់ប្រទេសសមាជិកណាមួយដែលបានបំពេញបែបបទក្នុងស្រុករួចរាល់ ។

-ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ភាគីទាំងពីរបានឯកភាពអនុម័តលើថវិកាបណ្តោះអាសន្នចំនួន ២៨៧ពាន់ដុល្លារអាមេរិក សម្រាប់អង្គភាពគាំទ្រតំបន់ពាណិជ្ជកម្មសេរី។ អនុគណៈកម្មាធិការថវិកាមួយនឹងត្រូវបង្កើតឡើង ដើម្បីគាំទ្រដល់ការពិនិត្យ និងពិចារណាលើថវិកាប្រចាំឆ្នាំនេះ ។

## ៥.៣-កិច្ចការសហប្រតិបត្តិការអនុតំបន់

### ក-កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អាងទន្លេមេគង្គអាស៊ាន (AMBDC)

ប្រទេសដៃគូបានកត់សំគាល់ពីវឌ្ឍនភាពក្នុងការអនុវត្តន៍គម្រោង AMBDC នាពេលកន្លងទៅ។ មកដល់ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០០៩ មានគម្រោងចំនួន ៤៦ ស្ថិតនៅក្នុងដំណាក់កាលអនុវត្តផ្សេងៗគ្នា ក្នុងនោះគម្រោងចំនួន ១៤ កំពុងត្រូវការថវិកាចំនួន ៤៤.៥០លានដុល្លា។ នៅក្នុងគម្រោងកិច្ចសហប្រតិបត្តិដ៏សំខាន់នេះ ភាគីទាំងអស់នៅតែកំណត់ថា គម្រោងតភ្ជាប់ផ្លូវដែកសឹង្ហបុរី-គុនមីង (ដែលមានកំណាត់ផ្លូវឆ្លងកាត់កម្ពុជាដ៏សំខាន់) គឺជាគម្រោងអាទិភាពក្រោមកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អាងទន្លេមេគង្គអាស៊ាន។ ជាមួយគ្នានេះ ការកត់សំគាល់លើការសិក្សាតម្រង់ទិសស្របជាមួយសហគមន៍សេដ្ឋកិច្ចអាស៊ាន និងបានឯកភាពជាគោលការណ៍ផ្តល់អាទិភាពទៅលើវិស័យចំនួន៣ គឺ : (១)វិស័យពាណិជ្ជកម្ម និងវិនិយោគ (២)ការ អភិវឌ្ឍន៍ធនធានមនុស្ស និង(៣)ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ។

### ខ-កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-ឡាវ-វៀតណាម

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ក្រសួងពាណិជ្ជកម្មបានប្រឹងប្រែងយកអស់ពីលទ្ធភាព ទាញយកអត្ថប្រយោជន៍ពីគម្រោងកិច្ចសហប្រតិបត្តិការតំបន់ត្រីកោណ កម្ពុជា ឡាវ វៀតណាម (CLV) យកមកជួយដល់ការអភិវឌ្ឍន៍ខេត្តចំនួន៤ នៅភូមិភាគឦសាន (រតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ក្រចេះ) ដែលធ្លាប់ជាតំបន់ជនបទដាច់ស្រយាល មានការអភិវឌ្ឍន៍ទាប ឱ្យមានការប្រែប្រួលមុខមាត់ថ្មី និងមានជីវភាពរស់នៅល្អប្រសើរឡើង ស្របតាមគោលនយោបាយដ៏ត្រឹមត្រូវរបស់ប្រមុខរាជរដ្ឋាភិបាលក្នុងការកាត់បន្ថយអតុល្យភាពរវាងទីក្រុង និងជនបទ។

វឌ្ឍនភាពថ្មីៗនៃការអនុវត្តន៍គម្រោងកិច្ចសហប្រតិបត្តិការកម្ពុជា-ឡាវ-វៀតណាម និងជប៉ុន សម្រាប់អភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម ដែលគាំទ្រដោយរាជរដ្ឋាភិបាលជប៉ុន តាមរយៈមូលនិធិសមាហរណកម្មអាស៊ាន-ជប៉ុន (JAIF) ដែលមានទឹកប្រាក់ចំនួន ២០លានដុល្លា ភាគីកម្ពុជាមាន ១០គម្រោងទទួលបានទឹប្រាក់សរុប ៧.៥លានដុល្លា *(គម្រោងកំពុងត្រូវបានដំណើរការអនុវត្ត)*។ ក្រៅពីនេះ CLV បានទទួលទឹកប្រាក់ចំនួន ១.៥លានដុល្លា សិក្សាផ្លូវតភ្ជាប់នៃបណ្តាប្រទេសទាំងបី (ផ្លូវលេខ ៧៨A របស់កម្ពុជា តភ្ជាប់ទៅផ្លូវលេខ ១J របស់ឡាវ ផ្លូវលេខ ១៦ របស់ឡាវភ្ជាប់ទៅព្រំដែនវៀតណាម និងផ្លូវលេខ ៧៦ ពីបានលុងនៃខេត្តរតនគិរី ទៅខេត្តមណ្ឌលគិរី បន្តទៅព្រំដែនវៀតណាម ត្រង់ចំណុចដាក់ដាំ )។ អង្គការ JICS (Japan International Cooperation System) បានសិក្សាចប់សព្វគ្រប់រួចហើយ។ លើសពីនេះ កម្ពុជានៅបានលើកសំណើស្នើសុំគម្រោងតូចៗថ្មីចំនួន៨ ទៀតដាក់ជូនទៅភាគីជប៉ុន ដើម្បីសុំការគាំទ្រ ដើម្បីអាចជួយបង្កើនល្បឿនអភិវឌ្ឍន៍នៅខេត្តជាប់ព្រំដែនទាំង៤។

### គ-កិច្ចសហប្រតិបត្តិការមេគង្គ-ជប៉ុន

ក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសមេគង្គ-ជប៉ុន កាលពីថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៨ នៅទីក្រុងតូក្យូ ភាគីជប៉ុនបានផ្តល់ជំនួយចំនួន ២០លានដុល្លារអាមេរិក សម្រាប់ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម។ បន្ទាប់ពីនោះ ក្រុមមន្ត្រីជំនាញនៃប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា វៀតណាម និងជប៉ុន បានជួបប្រជុំគ្នារៀបចំគម្រោងនានា ដើម្បីប្រើប្រាស់ជំនួយ ២០លានដុល្លានោះ ឱ្យសម្រេចបានជារូបរាងពិតប្រាកដ។

អ្នកតំណាងអង្គការ JETRO បានធ្វើការបង្ហាញពីលទ្ធផលពីប្រធានបទនៃការស្រាវជ្រាវ គឺសិក្សាអំពីយុទ្ធសាស្ត្រ និងតម្រូវការរបស់ក្រុមហ៊ុនជប៉ុន ក៏ដូចជាក្រុមហ៊ុននៃបណ្តាប្រទេសក្នុងអនុតំបន់ទន្លេមេគង្គ ដើម្បីជំរុញនិងអភិវឌ្ឍលើវិស័យវិនិយោគ។ មានក្រុមហ៊ុនចំនួន ១២៥ ដែល JETRO បានធ្វើការសំភាសន៍ ដូចជា: ប្រទេសថៃ ចំនួន ៤២ ប្រទេសវៀតណាម ចំនួន ២៥ ប្រទេសកម្ពុជា ចំនួន ១៧ ប្រទេសឡាវ ចំនួន ១៥ ប្រទេសមីយ៉ាន់ម៉ា ចំនួន ១៣ និងប្រទេសសឹង្ហបូរី ចំនួន ១៣ ។

### ឃ-កិច្ចសហប្រតិបត្តិការរបៀងសេដ្ឋកិច្ចខាងត្បូងក្នុងក្របខ័ណ្ឌមេគង្គ-ឥណ្ឌា

***ផ្នែកទី ១*** : Integrated Corridor Concept of Mekong-India Economic Corridor (MIEC )

ទស្សនៈវិស័យសំខាន់នៃគម្រោងការអភិវឌ្ឍន៍របៀងសេដ្ឋកិច្ចនេះគឺ (១) ដើម្បីលើកកំពស់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងពាណិជ្ជកម្មរវាងប្រទេសឥណ្ឌា និងប្រទេសក្នុងអនុតំបន់ទន្លេមេគង្គ រួមមាន ប្រទេសកម្ពុជា មីយ៉ាន់ម៉ា វៀតណាម និងថៃឡង់ដ៍ (២)ជំរុញវិនិយោគតាមច្រករបៀង (៣)បង្កើតការងារ និងឱកាសអភិវឌ្ឍន៍សង្គម និង

(៤)ធ្វើឱ្យឃើញនូវការប្រៀបធៀប ផលចំណេញ និងការបំពេញបន្ថែមនូវរាល់ចំណុចវិជ្ជមាន ដែលអាចមាននៅតាមតំបន់ទីក្រុង តំបន់ជុំវិញទីក្រុង និងតាមរបៀងច្រកព្រំដែនទាំងនោះ ។

***ផ្នែកទី ២ :*** Possible Program Implementation Framework and Financing Mechanism ក្រុមការងារបានស្នើ (១)ឱ្យមានរចនាសម្ព័ន្ធត្រឹមត្រូវ សម្រាប់អនុវត្តគម្រោងដែលទាមទារឱ្យមានភ្នាក់ងារច្រើនចូលរួម ហើយដែលអ្នកទាំងនោះត្រូវមានភាពទទួលខុសត្រូវស្គាល់បណ្តាញទាក់ទង និងមានសមត្ថភាព (២)ឱ្យមានវិធាននៃការអភិវឌ្ឍន៍ "Project Development Approach" ដើម្បីអនុវត្តគម្រោងរបៀងនេះឡើង និង (៣)បង្កើតយន្តការអភិវឌ្ឍន៍មូលនិធិគម្រោង។

***ផ្នែកទី ៣ :*** ផែនការសកម្មភាពគន្លឹះដ៏ល្អៗ និងជំហ៊ានបន្ទាប់ "Action Plans, Key Outstanding Issues, and Next Step"

ជាដំបូងវិទ្យាស្ថានស្រាវជ្រាវសម្រាប់អាស៊ាន និងអាស៊ីបូព៌ា ERIA ត្រូវអនុវត្តជាបន្ទាន់នូវគម្រោងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងជំរុញលើកទឹកចិត្តដល់ការអភិវឌ្ឍន៍របៀង តាមរយៈដៃគូសាធារណៈឯកជន " Public Private Partnership " ។

### *ង-កិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌ ( AMEICC-WEC-WG )*

កម្ពុជាមានគម្រោងចំនួនពីរគឺ ការអភិវឌ្ឍន៍វិស័យអាជីវកម្មខ្នាតតូចនិងមធ្យម និងការអភិវឌ្ឍន៍វិស័យកៅស៊ូ។ ដោយឡែក នាកិច្ចប្រជុំលើកទី២១ដែលបានប្រព្រឹត្តធ្វើឡើងនៅថ្ងៃទី ៣០-៣១ ខែ កក្កដា ឆ្នាំ២០០៩ (នៅទីក្រុងបាងកក) ក្រសួងពាណិជ្ជកម្មបានស្នើគម្រោងថ្មីមួយឈ្មោះ "Training Workshop on Trade Facilitation along the Corridor: Bangkok-Phnom Penh-Ho Chi Ming city" ដើម្បីបញ្ចូលទៅក្នុងតារាងមេនៃក្រុមការងារ។ គម្រោងនេះ មានផលប្រយោជន៍សម្រាប់មន្ត្រីនៃប្រទេសចំនួន៤ គឺ កម្ពុជា វៀតណាម ឡាវ និងថៃ យល់បានពីសកម្មភាព ក៏ដូចជាអត្ថប្រយោជន៍ទាំងផ្នែកសេដ្ឋកិច្ច និងនយោបាយនៃកិច្ចសម្រួលពាណិជ្ជកម្មតាមច្រករបៀង និងព្រំដែន។

### *ច- កិច្ចសហប្រតិបត្តិការឈូងសមុទ្រ Pan-Beibu Gulf (PBG)*

នេះជាកិច្ចសហប្រតិបត្តិការដែលមានភាពទន់ភ្លន់ និងដើរតួនាទីវិជ្ជមាននៅក្នុងការធ្វើឱ្យប្រសើរដល់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មអាស៊ាន-ចិន។ កិច្ចសហប្រតិបត្តិការនេះនឹងបង្កើតបានជាប៉ូលកំណើនថ្មីមួយនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ ប្រទេសជាសមាជិក ក៏ដូចជាលេខាធិការដ្ឋានអាស៊ាន និងធនាគារអភិវឌ្ឍអាស៊ីបានកំណត់យកវិស័យអាទិភាពចំនួន៥ ធ្វើជាមូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍន៍កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច PBG ដូចជាៈ ការកសាងហេដ្ឋារចនាសម្ព័ន្ធកំពង់ផែ និងការដឹកជញ្ជូន ការសម្រួលវិស័យវិនិយោគ និងពាណិជ្ជកម្ម កសិកម្ម ទេសចរណ៍ និងវិស័យហិរញ្ញវត្ថុ។

ភាគីចិននឹងបង្កើតមូលនិធិវិនិយោគ ដែលមានទឹកប្រាក់ចំនួន ១០ពាន់លានដុល្លារអាមេរិក ហើយនៅពេលឆាប់ៗខាងមុខនេះ ភាគីចិននឹងផ្តល់ការសម្រួលឥណទានចំនួន ១៥ពាន់លានដុល្លារអាមេរិកបន្ថែមទៀត ដោយបាន

បញ្ជាក់ថា បណ្តាលក្ខខ័ណ្ឌនៃការសម្រួលទាំងនេះកំពុងតែធ្វើការអភិវឌ្ឍន៍ ហើយរាល់ព័ត៌មាននានា នឹងត្រូវផ្តល់ទៅឱ្យអាស៊ាន នៅពេលសមស្របណាមួយ ។

### ***៥.៤-សមាហរណកម្មពិភពលោក***

ការធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងសេដ្ឋកិច្ចសកលលោក គឺជាមុំមួយនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលតាំងពីអាណត្តិទី៣ រហូតមកដល់ពេលនេះ ក្រសួងពាណិជ្ជកម្មតែងតែបំពេញបេសកកម្មនេះជូនរាជរដ្ឋាភិបាល ទទួលបានជោគជ័យជាបន្តបន្ទាប់ ធ្វើឱ្យកម្ពុជាអាចបោះជំហ៊ានចូលទៅកាន់ទីផ្សារពិភពលោកយ៉ាងស្វាហាប់ និងបង្កើនទំនាក់ទំនងទ្វេភាគី ពហុភាគីដ៏ទូលំទូលាយជាមួយបណ្តាប្រទេសនានា ផ្តល់ឱកាសមាសសម្រាប់ការធ្វើពាណិជ្ជកម្ម និងវិនិយោគលើគ្រប់វិស័យនៅកម្ពុជា និងលើកតម្កើងមុខមាត់កម្ពុជាលើឆាកអន្តរជាតិ ជាពិសេសចាប់តាំងពីដំណាក់កាលដែលកម្ពុជាក្លាយជាសមាជិកពេញសិទ្ធិនៃអង្គការពាណិជ្ជកម្មពិភពលោក ។

កិច្ចប្រឹងប្រែងចរចាបើកច្រកទីផ្សារទៅកាន់ប្រទេសនានា ដែលក្រសួងពាណិជ្ជកម្មបានឈានមុខអនុវត្តក្នុងឆ្នាំកន្លងទៅ បាននាំមកជូនប្រទេសជាតិនូវគុណប្រយោជន៍ធំធេងក្នុងការទ្រទ្រង់ដល់ជីវភាពសេដ្ឋកិច្ច សង្គម ដោយកម្ពុជាទទួលបានភាពអនុគ្រោះពន្ធ (GSP) ជាបន្តបន្ទាប់ លើមុខទំនិញថ្មីបន្ថែមទៀតពីបណ្តាប្រទេសអភិវឌ្ឍន៍។ ក្នុងក្របខ័ណ្ឌ TIFA (Trade and Investment Framework Agreement) ដែលដឹកនាំដោយ ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ទទួលបានជាគោលការណ៍នូវការអនុគ្រោះពន្ធកម្រិតសូន្យលើមុខទំនិញចំនួន ១៧៧មុខ ថែមទៀត ជាពិសេសសិប្បកម្មសូត្រ អង្ករ ត្រី ទឹកឃ្មុំ ចម្លាក់ថ្ម និងឈើ ជាដើម ទៅកាន់ទីផ្សារសហរដ្ឋអាមេរិក។ បែបបទនីតិវិធីទាំងបួនដំណាក់កាលដើម្បីទទួលបានភាពអនុគ្រោះពន្ធនេះ ក្រសួងបានយកចិត្តទុកដាក់បំពេញរួចរាល់អស់ហើយ រួមទាំងគំរូត្រា និងគំរូហត្ថលេខាថ្នាក់ដឹកនាំ។ បច្ចុប្បន្នកំពុងរង់ចាំ ភាគីគយសហរដ្ឋអាមេរិក ធ្វើសិក្ខាសាលាពន្យល់ពីនីតិវិធី និងបែបបទពាក់ព័ន្ធក្នុងការនាំចូលទំនិញទៅកាន់ទីផ្សារសហរដ្ឋអាមេរិក ព្រមទាំងពន្យល់ពីវិធានប្រភពដើមដល់មន្ត្រីក្រសួង ក៏ដូចជាសហគមន៍អ្នកនាំចេញកម្ពុជាជាមុនសិន ហើយដែលបន្ទាប់ពីនេះ នឹងធ្វើការផ្សព្វផ្សាយទូលាយ ។

នៅចុងឆ្នាំ ២០០៩ នេះ ប្រតិភូក្រសួងពាណិជ្ជកម្មដែលដឹកនាំដោយឯកឧត្តមទេសរដ្ឋមន្ត្រី បានបំពេញបេសកកម្មទៅទីក្រុងវ៉ាស៊ីនតោន ដើម្បីរិះរកលទ្ធភាពស្នើសុំការអនុគ្រោះពន្ធលើមុខទំនិញសំលៀកបំពាក់ពីសភាអាមេរិក ដែលនេះសបញ្ជាក់ឱ្យឃើញពីពលិកម្មដោយមិនខ្លាចនឿយហត់ ជំនះរាល់ការប្រឈមនិងឧបសគ្គផ្សេងៗ សំដៅទ្រទ្រង់ឱ្យខាងតែបានអត្ថិភាពនៃឧស្សាហកម្មកាត់ដេរកម្ពុជា ដែលជាទីពំនាក់នៃវាសនាពលករខ្មែររាប់សែននាក់ ។

### ***ការងារផ្តល់ព័ត៌មាន***

លើកសំណើសុំការសម្រេចពីរាជរដ្ឋាភិបាល ក្នុងការរៀបចំលិខិតបទដ្ឋានច្បាប់ទាក់ទងនឹងពាណិជ្ជកម្មសម្រាប់ជាការផ្តល់ព័ត៌មាន (Notification) ជូនទៅអង្គការពាណិជ្ជកម្មពិភពលោក និងរៀបចំធ្វើសេចក្តីជូនដំណឹងដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីត្រៀមធ្វើការផ្តល់ព័ត៌មានផ្លូវការទៅអង្គការពាណិជ្ជកម្មពិភពលោក ដែលរួមមាន ច្បាប់គយ និងការវាយតម្លៃពន្ធគយ អនុក្រឹត្យស្តីពីអនុវត្តច្បាប់គយ អធិការកិច្ចមុនពេលផ្ទុក ការឧបត្ថម្ភលើវិស័យ

កសិកម្ម វិធានការវិនិយោគទាក់ទិននឹងពាណិជ្ជកម្ម វិធានការប្រឆាំងការលក់បង្ខូចថ្លៃ វិធានការតបត និង វិធានការការពារ ។

***ការងារចរចាសេវាកម្ម***

-បានបកប្រែអត្ថបទនៃកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មសេវាកម្មរវាងអាស៊ាន និងសាធារណរដ្ឋកូរ៉េ និង បានចូលរួមពិភាក្សា និងការពារកិច្ចព្រមព្រៀងនេះនៅក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី ។

-បានការពារសេចក្តីព្រាងច្បាប់ស្តីពីការអនុម័ត និងដាក់ឱ្យប្រើប្រាស់កិច្ចព្រមព្រៀងស្តីពី ពាណិជ្ជកម្ម សេវាកម្មរវាងអាស៊ាន និងសាធារណរដ្ឋកូរ៉េ នៅរដ្ឋសភា ដើម្បីជាមូលដ្ឋានសម្រាប់**សម្តេចនាយករដ្ឋមន្ត្រី** អាចជូនដំណឹង ទៅកិច្ចប្រជុំកំពូលអាស៊ាន អំពីការអនុម័តច្បាប់នោះរបស់ភាគីកម្ពុជា ហើយនេះ ក៏ជាចំណែកនៃការជួយលើកស្ទួយ កិត្តិយសប្រទេសជាតិយើង ។

-បានចូលរួមជាទៀងទាត់ ទៅចរចាពាណិជ្ជកម្មសេវាកម្មក្នុងក្របខ័ណ្ឌអាស៊ាន (CCS) ដោយបានឈាន ដល់ការត្រៀមរៀបចំបញ្ជីសន្យាតាមវិស័យសម្រាប់កញ្ចប់ទី៨នៃការសន្យា ដើម្បីត្រៀមឈានដល់ការធ្វើសេរីភាវូប នីយកម្មវិស័យសេវាកម្មទាំងស្រុងក្នុងអាស៊ាន នាឆ្នាំ ២០១៥ ។

-ផ្តល់ការពិគ្រោះយោបល់ជូនទៅថ្នាក់ដឹកនាំ និងមន្ត្រីនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងជម្រើស និងទិដ្ឋភាពផ្នែកច្បាប់ នៃការសុំពន្យាពេលអនុវត្តកាតព្វកិច្ចរបស់កម្ពុជា លើ វិស័យធានារ៉ាប់រងបន្ត ជាមូលដ្ឋានសម្រាប់ពិចារណាថា តើគួរសុំពន្យាពេលអនុវត្ត ឬដកចេញជាអចិន្ត្រៃយ៍នូវការ សន្យាលើវិស័យធានារ៉ាប់រងបន្តនោះ ។

-សិក្សាស្រាវជ្រាវ និងប្រមូលផ្តុំព័ត៌មាន ទាក់ទងនឹងការចរចាបើកច្រកចូលទីផ្សារសេវាកម្ម ក្នុង ក្របខ័ណ្ឌតំបន់ និងពិភពលោក ជាពិសេសតាមដានការវិវត្តន៍ការងារចរចាសេវាកម្ម នៅក្នុងក្របខ័ណ្ឌអង្គការ ពាណិជ្ជកម្មពិភពលោក ។

-ត្រៀមរៀបចំសម្របសម្រួលជាមួយអន្តរក្រសួង រាល់កិច្ចការដែលទាក់ទងនឹងការផ្តល់ព័ត៌មានទៅ អង្គការពាណិជ្ជកម្មពិភពលោក អំពីច្បាប់បទបញ្ញត្តិ ឬលិខិតបទដ្ឋានច្បាប់ ពាក់ព័ន្ធនឹងវិស័យសេវាកម្ម នៅពេលដែល អនុក្រឹត្យស្តីពីការបែងចែកតួនាទីភារកិច្ច រវាងអន្តរក្រសួងពាក់ព័ន្ធជាមួយនិងការងារអង្គការពាណិជ្ជកម្មពិភពលោក ត្រូវបានចុះហត្ថលេខារួចហើយ ។

***ការងារពាក់ព័ន្ធនឹងអង្គការពាណិជ្ជកម្មពិភពលោក***

-បានរៀបចំ និងសម្របសម្រួលកិច្ចប្រជុំតុមូលនៃប្រទេសអភិវឌ្ឍន៍តិចតួច ស្តីអំពីការចូលជាសមាជិក អង្គការពាណិជ្ជកម្មពិភពលោក ចាប់ពីថ្ងៃទី ២៨-៣០ ខែ កញ្ញា ឆ្នាំ ២០០៩ ។

-បានធ្វើបច្ចុប្បន្នភាពកម្មវិធីការងារដែលព្រះរាជាណាចក្រកម្ពុជា បានសន្យាជាមួយអង្គការពាណិជ្ជកម្ម ពិភពលោក ដោយមានការចូលរួមពីក្រសួងពាក់ព័ន្ធ ។

-ផ្តល់ការណែនាំ និងសម្របសម្រួលជាមួយស្ថានបេសកកម្មអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំ អង្គការពាណិជ្ជកម្មពិភពលោក ពាក់ព័ន្ធនឹងកិច្ចប្រជុំនានាធ្វើឡើងក្នុងក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក ។

-ចូលរួមកិច្ចប្រជុំពិភាក្សាលើការតាក់តែងសេចក្តីព្រាងច្បាប់ឧបាស្រ័យពាណិជ្ជកម្ម ។

## ៦-សកម្មភាពកសាង និងផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ

ការកសាងនីតិរដ្ឋនៅកម្ពុជាគឺជាឆន្ទៈដ៏មោះមុត និងជាទិសដៅយុទ្ធសាស្ត្រក្នុងកម្មវិធីកំណែទម្រង់រដ្ឋ របស់រាជរដ្ឋាភិបាល ដែលក្នុងនោះមានវិស័យកំណែទម្រង់រដ្ឋបាល កំណែទម្រង់ប្រព័ន្ធយុត្តិធម៌ និងតុលាការ ហើយដែលត្រូវបានក្រសួងពាណិជ្ជកម្មចាត់ទុកថា ជាកិច្ចការអាទិភាពមួយដែលកំណត់ជោគជ័យរាល់សកម្មភាពដ៏ទៃទៀត ។ ឈរលើទស្សនៈវិស័យនេះ ក្រសួងពាណិជ្ជកម្មបានចំណាយពេលវេលា ធនធានជាស្មារតី ថវិកាជាច្រើន ដោយជំនះរាល់ការលំបាកផ្សេងៗ ក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្តិជាច្រើន ដែលជាតម្រូវការសម្រាប់បង្កើតប្រព័ន្ធច្បាប់មួយ ឱ្យមានលក្ខណៈទំនើប មានតម្លាភាព និងប្រសិទ្ធភាព ដើម្បីបំពេញបំណងដល់ធុរៈជន និងសម្រួលដល់ការងារវិនិយោគ ក៏ដូចជាការធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងតំបន់ និងពិភពលោក ដែលអនុញ្ញាតឱ្យកម្ពុជាទទួលបាននូវអត្ថប្រយោជន៍យ៉ាងពេញលេញពីការធ្វើសមាហរណកម្មសេដ្ឋកិច្ច ។ លទ្ធផលនៃការអនុវត្តជាក់ស្តែង ត្រូវបានបង្ហាញឱ្យឃើញនៅផ្នែកខាងក្រោម :

### *៦.១-ការកសាងច្បាប់ និងបញ្ញត្តិផ្សេងៗ*

ដោយពិនិត្យពិច័យទាំងក្នុងទិដ្ឋភាពបច្ចេកទេស និងទិដ្ឋភាពនយោបាយ ខិតខំជំរុញការរៀបចំសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ តាមកម្មវិធីការងារដូចដែលបានកំណត់ក្នុងទិសដៅឆ្នាំ២០០៩ សម្រេចបានជាអត្ថបទគតិយុត្តិទាំងឡាយ រួមមាន :

-កិច្ចព្រមព្រៀងស្តីពី ពាណិជ្ជកម្ម សេវាកម្មនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមន៍ប្រជាជាតិអាស៊ីអគ្នេយ៍ និង**សាធារណៈរដ្ឋប្រជាមានិតចិន** ត្រូវបានដាក់ឱ្យប្រើប្រាស់តាមព្រះរាជក្រមលេខ នស/រកម/១០០៩/០១៨ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០០៩ ។ ដំណាលគ្នានោះ កិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្ម សេវាកម្មនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមន៍ប្រជាជាតិអាស៊ីអគ្នេយ៍ និង**សាធារណៈរដ្ឋកូរ៉េ** ត្រូវបានដាក់ឱ្យប្រើប្រាស់តាមព្រះរាជក្រមលេខ នស/រកម/១០០៩/០២១ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០០៩

-រៀបចំសេចក្តីព្រាង**អនុក្រឹត្យ ស្តីពីការបង្កើត និងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលជាតិផ្នែកពាណិជ្ជកម្ម** រហូតទទួលបានការអនុម័តដោយគណៈរដ្ឋមន្ត្រីកាលពីថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៩ ដែលនេះ ជាការងារថ្មីមួយត្រូវបានមជ្ឈដ្ឋានពាណិជ្ជករស្វាគមន៍ និងសំដែងនូវការពេញចិត្តចំពោះកិច្ចប្រឹងប្រែងរបស់ក្រសួងពាណិជ្ជកម្ម ហើយរំពឹងថា នេះជាច្រកដោះស្រាយទំនាស់ពាណិជ្ជកម្មដែលនឹងជួយបំព្រួញពេលវេលា បន្ថយការចំណាយ ថវិកា សម្រួលដល់អ្នកធ្វើជំនួញទូទៅ ហើយនេះក៏ជាប្រភេទសេវាដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ និងជាវេទិកាមួយសម្រាប់ពង្រឹងនីតិរដ្ឋ រួមចំណែកយ៉ាងសំខាន់ក្នុងការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ។

-រៀបចំសេចក្តីព្រាង**ច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម** ដោយឆ្លងកាត់ការតាក់តែងយ៉ាងសម្រិតសម្រាំង មានការផ្តល់មតិយោបល់ពីក្រសួងពាក់ព័ន្ធ ដើម្បីធានាភាពស្របគ្នានៃច្បាប់ និងលិខិតបទដ្ឋានដែលកំពុងមានសុពលភាពជាធរមាន ។ ក្រោយពីបានធ្វើការកែសម្រួលបន្ថែមជាមួយអ្នកជំនាញរបស់ ADB រួចមក ក្រសួងពាណិជ្ជកម្ម

បានបញ្ជូនសេចក្តីព្រាងច្បាប់នេះ ទៅទីស្តីការគណៈរដ្ឋមន្ត្រីកាលពីពាក់កណ្តាលខែតុលាឆ្នាំ២០០៩រួចហើយ។ សេចក្តីព្រាងច្បាប់នេះ ចែកចេញជា ១៩ជំពូក និង២២៩មាត្រា មានគោលដៅបង្កើតវិធានពិសេសនៃកិច្ចសន្យាពាណិជ្ជកម្ម ដែលអាចជួយពាណិជ្ជករកម្ពុជាក្នុងការអភិវឌ្ឍន៍ និងពង្រីកទំនាក់ទំនងពាណិជ្ជកម្ម និងជំរុញសកម្មភាពសេដ្ឋកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា។ លើសពីនេះទៀត សេចក្តីព្រាងច្បាប់នេះ ផ្តោតលើកិច្ចសន្យាពិសេស១ដែលប្រើប្រាស់ក្នុងទំនាក់ទំនងអន្តរជាតិ និងបំពេញបន្ថែមលើក្រមរដ្ឋប្បវេណីដែលមិនមានចែងលម្អិតអំពីកិច្ចសន្យា ដែលបម្រើដល់វិស័យហិរញ្ញវត្ថុ និងពាណិជ្ជកម្ម ដែលកំពុងអភិវឌ្ឍន៍យ៉ាងលឿននាពេលបច្ចុប្បន្ន។

-កសាងសេចក្តីព្រាង**ច្បាប់អ៊ី-ពាណិជ្ជកម្ម** សេចក្តីព្រាង**ច្បាប់ស្តីពីការប្រកួតប្រជែង** និង សេចក្តីព្រាង**ច្បាប់ស្តីពីតុលាការពាណិជ្ជកម្ម**។ សេចក្តីព្រាងច្បាប់ទាំងនេះ កំពុងត្រូវបានពិនិត្យកែសម្រួល ក្រោយពីមានការផ្តល់យោបល់ពីក្រសួងពាក់ព័ន្ធ និងវិស័យឯកជន។ ទន្ទឹមនឹងនេះ ក្រសួងបានលើកជាគម្រោង និងដាក់សំណើសុំជំនួយបច្ចេកទេសពីកម្មវិធី TDSP សម្រាប់អនុវត្តក្នុងឆ្នាំ២០១០ ដើម្បីបង្កើនការយល់ដឹង និងធ្វើការសិក្សាស្រាវជ្រាវឱ្យបានស៊ីជម្រៅលើសេចក្តីព្រាងច្បាប់នេះ ធានាធ្វើយ៉ាងណាឱ្យសេចក្តីព្រាងច្បាប់ដែលនឹងត្រូវអនុម័តនាពេលខាងមុខ ជាច្បាប់ដែលមានលក្ខណៈល្អប្រសើរស្របតាមច្បាប់ដែលកំពុងអនុវត្ត និងអាចអនុវត្តបានដោយប្រសិទ្ធភាពខ្ពស់។ នេះជាសេចក្តីព្រាងច្បាប់ដែលមានលក្ខណៈបច្ចេកទេសខ្ពស់ ស្មុគស្មាញ និងជាទស្សនៈថ្មីសម្រាប់ប្រទេសយើង។ ដោយសារច្បាប់នេះមានការពាក់ព័ន្ធជាមួយក្រសួងផ្សេង១ជាច្រើន ជាហេតុធ្វើឱ្យមានការយឺតយ៉ាវក្នុងការបញ្ជូនទៅគណៈរដ្ឋមន្ត្រី។ ទោះជាយ៉ាងនេះក្តី សេចក្តីព្រាងច្បាប់ទាំងនេះ ត្រូវបានរៀបចំឱ្យទៅជាទម្រង់ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា រង់ចាំការកែសម្រួលចុងក្រោយនាពេលដ៏ឆាប់ខាងមុខ បន្ទាប់ពីមានការសិក្សាស្រាវជ្រាវបានច្បាស់លាស់។

-សេចក្តីព្រាង**ច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ** ត្រូវបានរៀបចំរួចរាល់ហើយ ក្រោមការផ្តល់ជំនួយបច្ចេកទេសពីទីភ្នាក់ងារអភិវឌ្ឍន៍បារាំង “AFD”។ បច្ចុប្បន្ន ច្បាប់នេះកំពុងដាក់ឱ្យពិភាក្សា និងកែតម្រូវក្នុងក្របខ័ណ្ឌលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា ហើយសង្ឃឹមថា ច្បាប់នេះអាចនឹងបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី នៅអំឡុងត្រីមាសទី១ ឆ្នាំ២០១០។

-កំពុងតាក់តែងសេចក្តីព្រាង**ច្បាប់ស្តីពីអាជ្ញាប័ណ្ណបញ្ជាសម្រាប់សុខភាពសាធារណៈ** ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពចំពោះវាក្យខណ្ឌទី៦ នៃសេចក្តីប្រកាសកិច្ចព្រមព្រៀង TRIPS និងសុខភាពសាធារណៈ ដែលបានធ្វើរួចរាល់តាំងពីថ្ងៃទី ១២ ខែ មករា ឆ្នាំ២០០៧ ដោយជំនាញការកាណាដា ហើយបានបញ្ជូនទៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងសុខាភិបាល រួចរាល់ហើយដែរ។

-បានសិក្សា និងផ្តល់យោបល់ជូនក្រសួងសុខាភិបាល ទៅលើសេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យថ្នាំជក់ ចូលរួមពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលអាមេរិក និងរាជរដ្ឋាភិបាលកម្ពុជា ស្តីពីការស្រាវជ្រាវជំងឺឆ្លង។

-រៀបចំជាគម្រោងលម្អិតអនុវត្តកម្មសិទ្ធិបញ្ញា ដែលមាននៅក្នុង Pillar-1 ដើម្បីស្នើសុំធនាគារពិភពលោក ជួយឧបត្ថម្ភក្នុងការអនុវត្តន៍គម្រោងនេះ។

-បានចូលរួមពិនិត្យ និងពិភាក្សា ស្តីពីសេចក្តីព្រាងអនុស្សរណៈយោគយល់ រវាងក្រុមហ៊ុន Microsoft និង រាជរដ្ឋាភិបាលកម្ពុជា។

-ក្រៅពីនេះ បានធ្វើការបកប្រែសេចក្តីប្រកាសស្តីពី ភ្នាក់ងារកម្មសិទ្ធិបញ្ញា សៀវភៅណែនាំពាណិជ្ជសញ្ញា និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងអាស៊ាន-អូស្ត្រាលី-ណូវែហ្សេឡង់ ហើយកំពុងរង់ចាំការពិនិត្យ និងកែសម្រួលជាចុងក្រោយ ដើម្បីដំណើរការអនុវត្ត។

### ៦.២-ការងារតម្កល់លិខិតជូនដំណឹងប្រតិបត្តិការដែលមានកិច្ចធានា

ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាព ក្នុងការពង្រីកឥណទានអាជីវកម្ម ជាពិសេសឥណទានសម្រាប់សហគ្រាសខ្នាតតូច និងខ្នាតមធ្យម ដែលគ្មានធនធានគ្រប់គ្រាន់ និងកិច្ចធានាពីតតិយជន ដោយប្រើចលនទ្រព្យជាទ្រព្យធានា។ ទ្រព្យធានាអាចជាចលនទ្រព្យគ្រប់ប្រភេទរាប់ទាំងទ្រព្យរូបិយ និងទ្រព្យអរូបិយ។ វិធានទំនើបស្តីពីប្រតិបត្តិការដែលមានកិច្ចធានាមានលក្ខណៈជានិរន្តន៍ និងអាចបត់បែនតាមសកម្មភាពពាណិជ្ជកម្ម និងសេដ្ឋកិច្ចជាតិដែលពីមួយថ្ងៃទៅមួយថ្ងៃកាន់តែកើនឡើងយ៉ាងឆាប់រហ័ស។ ការិយាល័យតម្កល់លិខិតជូនដំណឹងមានតួនាទីបម្រើគោលបំណងនៃការធានាដល់ម្ចាស់បំណុល និងកូនបំណុល តាមមធ្យោបាយនៃការធ្វើប្រាតិភោគលើទ្រព្យធានា។ ការិយាល័យតម្កល់លិខិតជូនដំណឹងមិនមែនជាការិយាល័យចុះបញ្ជីតាមបែបសាមញ្ញ ដែលអាចធ្វើឱ្យការងារចុះបញ្ជី អាចត្រូវបានពន្យាពេល ហើយធ្វើឱ្យមានការលំបាកនោះឡើយ។ មិនតែប៉ុណ្ណោះ ការិយាល័យនេះ បានផ្តល់សេវាកម្មតាមរយៈប្រព័ន្ធអ៊ីនធឺណែត ដោយគេហទំព័រ www.setfo.gov.kh ។

ក្នុងរយៈពេលមួយឆ្នាំ ២០០៩ នេះ នាយកដ្ឋានបានទទួលចុះបញ្ជីតម្កល់លិខិត ជូនដំណឹង ចំនួន ៣៤៥ ដែលក្នុងនោះមានទ្រព្យអរូបីយ៍មួយចំនួន និងចលនទ្រព្យរូបីយ៍មួយចំនួន ជាភាគហ៊ុន។ សរុបយោងមកដល់ចុងឆ្នាំ ២០០៩ បានទទួលចុះបញ្ជីតម្កល់លិខិតជូនដំណឹងតាមអេឡិចត្រូនិកសរុបចំនួន **១,៣៤៥**។

| Notice | Initial | Amended | Termination | Continuation | Correction | Total |
|---|---|---|---|---|---|---|
| By Client | 1177 | 57 | 91 | 1 | 1 | 1327 |
| By Non-Client | 17 | 0 | 1 | 0 | 0 | 18 |
| Total: | 1194 | 57 | 92 | 1 | 1 | 1345 |

### ៦.៣-ការងារបង្កើតមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

ដោយអនុលោមតាមអនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម គណៈកម្មការរៀបចំជ្រើសរើសមជ្ឈត្តករដំបូង ត្រូវបានបង្កើតឡើងដោយប្រកាសរបស់ក្រសួងពាណិជ្ជកម្មលេខ 223 MOC/SM 2009 ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៩ ដែលមានតំណាងមកពីទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងយុត្តិធម៌ សភាពាណិជ្ជកម្មកម្ពុជា គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា សភាពាណិជ្ជកម្មអន្តរជាតិ

សមាគមរោងចក្រកាត់ដេរកម្ពុជា និងតំណាងសហព័ន្ធនិយោជក។ គណៈកម្មការមានភារកិច្ចសំខាន់ក្នុងការពិនិត្យជ្រើសរើសបេក្ខជនមិនតិចជាងពី ៥០-៦០នាក់ សម្រាប់ធ្វើមជ្ឈត្តករដំបូងនៃមជ្ឈមណ្ឌលជាតិ និងជួយរៀបចំបទបញ្ញាផ្ទៃក្នុងនីតិវិធី និងវិធានការរដ្ឋបាល សម្រាប់ការអនុវត្តន៏ការងាររបស់មជ្ឈមណ្ឌលជាតិ ព្រមទាំងរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាប្រតិបត្តិនៃមជ្ឈមណ្ឌលជាតិតាមការកំណត់នៃអនុក្រឹត្យ ។

ក្នុងនាមជាលេខាធិការដ្ឋាន និងយោងតាមការសម្រេចពីគណៈកម្មការ នាយកដ្ឋាននីតិកម្ម បានធ្វើការផ្សព្វផ្សាយជ្រើសរើសបេក្ខជនចំនួន ៦០រូប តាមសារព័ត៌មាន ទូរទស្សន៍ ហើយថែមទាំងបានធ្វើការផ្សព្វផ្សាយដល់មជ្ឈមណ្ឌលនៃមជ្ឈត្តករអន្តរជាតិធំៗមួយចំនួនដូចជា នៅ Singapore, Hong Kong, Malaysia ជាដើម ។ គិតត្រឹមថ្ងៃកំណត់បញ្ចប់ការទទួលពាក្យក្នុងខែតុលា ឆ្នាំ២០០៩ ក្រសួងបានទទួលពាក្យស្នើសុំពីបេក្ខជនចំនួន ៦០នាក់ (ជនជាតិខ្មែរចំនួន ៥៦នាក់ និងជនបរទេសចំនួន ៤នាក់)។ បច្ចុប្បន្ននេះ គណៈកម្មការកំពុងពិនិត្យលើពាក្យស្នើសុំរបស់បេក្ខជនទាំង ៦០រូប និងចេញសេចក្តីប្រកាសពីលទ្ធផលនៃការជ្រើសរើសនៅដើមឆ្នាំ២០១០ នេះ។

គណៈកម្មការ នឹងធ្វើការងាររបស់ខ្លួនតាមអនុក្រឹត្យជាបន្តទៀត ដើម្បីរៀបចំបង្កើតមជ្ឈមណ្ឌលជាតិដែលមានឯករាជ្យភាពពេញលេញ និងបម្រើឱ្យសេចក្តីត្រូវការក្នុងការដោះស្រាយវិវាទផ្នែកពាណិជ្ជកម្ម ជូនអ្នកវិនិយោគទុនជាតិ និងអន្តរជាតិ ចាប់ពីឆ្នាំ ២០១០ នេះតទៅ។

### ៦.៤-ការងារផ្សព្វផ្សាយច្បាប់

ដើម្បីបញ្ជ្រាបចំណេះដឹងដល់សាធារណៈជនអំពីវិស័យច្បាប់ពាណិជ្ជកម្ម ជាបន្តបន្ទាប់ អត្ថបទច្បាប់នានាត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់ក្រសួងពាណិជ្ជកម្ម ( www.moc.gov.kh ) និងគេហទំព័រដោយឡែករបស់នាយកដ្ឋាននីតិកម្ម (www.camcl.org ) និងតាមរយៈកិច្ចប្រជុំ ឬសិក្ខាសាលាផ្សព្វផ្សាយច្បាប់ដែលមានរយៈពេល ២ថ្ងៃ/លើក នៅតាមបណ្តាខេត្តនានាទូទាំងប្រទេស ដោយមានការឧបត្ថម្ភពីគម្រោងអភិវឌ្ឍន៏វិស័យហិរញ្ញវត្ថុរបស់ADB។ លទ្ធផលលេចធ្លោនៃការងារផ្សព្វផ្សាយច្បាប់ ស្តែងចេញតាមរយៈកិច្ចខិតខំប្រឹងប្រែងអនុវត្តការងារមួយចំនួន ដូចខាងក្រោម:

#### ក-ការផ្សព្វផ្សាយច្បាប់ទូទៅ

-ដោយមានកិច្ចសហការគាំទ្រពីADB នាយកដ្ឋាននីតិកម្មសហការជាមួយមន្ទីរពាណិជ្ជកម្មខេត្ត រៀបចំសិក្ខាសាលាផ្សព្វផ្សាយច្បាប់ពាណិជ្ជកម្មជាច្រើនវគ្គ រួមមានច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និងច្បាប់ស្តីពីមជ្ឈត្តករផ្នែកពាណិជ្ជកម្ម ក្នុងនោះអនុវត្តបាន ១៥លើក/១៥ខេត្ត ដែលមានសិក្ខាកាមចូលរួមពី ប្រមាណពី១០០នាក់ទៅ ១៣០នាក់/មួយវគ្គ ។

-បានចូលរួមកម្មវិធីពិគ្រោះយោបល់ជាសាធារណៈ លើសេចក្តីព្រាងប្រកាសស្តីពី "ការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ ( កុងស៊ីបញ្ចាំ)" ។

-បានចូលរួមក្នុងកម្មវិធីកំណែទម្រង់វិមជ្ឈការ ច្រកចេញ-ចូលតែមួយ នៅខេត្តតាកែវ និងខេត្តកំពង់ចាម ព្រមទាំងបានធ្វើការផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានទាំងឡាយ ដែលពាក់ព័ន្ធនឹងការចុះបញ្ជីពាណិជ្ជកម្ម។

#### ខ-ការផ្សព្វផ្សាយអំពីច្បាប់ បទបញ្ញត្តិបច្ចេកទេស និងការអប់រំបញ្ហាសុវត្ថិភាពផលិតផល

***ពិសេសម្ហូបអាហារ***

បានធ្វើការផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផលទំនិញ និងសេវា ព្រមទាំងបទបញ្ញត្តិបច្ចេកទេសនានា ក្នុងគោលបំណងពង្រីកការយល់ដឹងដល់ស្ថាប័នពាក់ព័ន្ធ ផលិតករ អាជីវករ និងប្រជាពលរដ្ឋ ឱ្យយល់កាតព្វកិច្ច និងសិទ្ធិរបស់ខ្លួន ពីលក្ខណៈវិនិច្ឆ័យផ្នែកសុវត្ថិភាពម្ហូបអាហារ សម្រាប់ជាវិធានការរួម ធានានូវសុវត្ថិភាពម្ហូបអាហារដល់ប្រជាពលរដ្ឋ ដែលក្នុងនោះមានការចូលរួមពីសំណាក់មន្ត្រីរាជការ លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្ស ចូលរួមស្តាប់ចំនួន ៦៩២ រូប ។ ខ្លឹមសារនៃការផ្សព្វផ្សាយអប់រំ នេះរួមមាន :

-ផលប៉ះពាល់ដល់សុខភាព ដែលបណ្តាលមកពីការប្រើប្រាស់ម្ហូបអាហារ ដែលមានសំបកវេចខ្ចប់ពុំត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសកំពិត ប៉ោង ច្រែះ..) គ្មានថ្ងៃ ខែ ឆ្នាំកំណត់រយៈពេលប្រើប្រាស់ និងទំនិញហួសរយៈពេលប្រើប្រាស់ ។

-ផលប៉ះពាល់ដែលបណ្តាលមកពីការប្រើប្រាស់ម្ហូបអាហារ មានផ្ទុកសារធាតុគីមីហាមឃាត់ ។

-ផលប្រយោជន៍នៃការប្រើប្រាស់អំបិលមានជាតិអ៊ីយ៉ូដ ។

-ផលប៉ះពាល់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន ។

-មាត្រាពាក់ព័ន្ធនឹងការក្លែងបន្លំ ការហាមឃាត់ការធ្វើពាណិជ្ជកម្មផលិតផលម្ហូបអាហារ ដែលមានលក្ខណៈប្រែប្រួលគុណភាព និងទោសបញ្ញត្តិដែលមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផលទំនិញ និងសេវា ។

ខាងលើនេះជាលទ្ធផលមួយដ៏ល្អ ដែលធ្វើឱ្យសាធារណៈជនកាន់តែយល់បានពីខ្លឹមសារច្បាប់ បទបញ្ញត្តិជាសារវន្ត ដើម្បីចូលរួមពង្រឹងនីត្យានុកូលភាព និងប្រសិទ្ធភាពនៃការអនុវត្តច្បាប់នៅប្រទេសយើង ។

**៧-ការងារក្របខ័ណ្ឌលេខាធិការដ្ឋាននៃគណៈកម្មការគ្រប់គ្រងផ្នែកទាំង៣ នៃកម្មសិទ្ធិបញ្ញា**

-គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា បានរៀបចំកិច្ចប្រជុំលើទី ១ របស់ខ្លួនកាលពីថ្ងៃ ២០ ខែ មករា ឆ្នាំ២០០៩ ដែលធ្វើការពិភាក្សាទៅលើគម្រោងអភិវឌ្ឍន៍ប្រព័ន្ធកម្មសិទ្ធិបញ្ញាកម្ពុជាចំនួន ៣៩ សកម្មភាពនៃការបណ្តុះបណ្តាលធនធានមនុស្ស និងបានប្រគល់ភារកិច្ចឱ្យលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ ពិនិត្យទៅលើ :

-សេចក្តីពន្យល់នៃវិធាន សម្រាប់អនុវត្តមាត្រា ១១ និងមាត្រា ១៣ នៃអនុសញ្ញាស្តីពីការត្រួតពិនិត្យថ្នាំជក់ក្របខ័ណ្ឌអង្គការសុខភាពពិភពលោក ( WHO Framework Convention on Tobacco Control ) និងកិច្ចព្រមព្រៀងទិដ្ឋភាពកម្មសិទ្ធិបញ្ញា ទាក់ទងនឹងពាណិជ្ជកម្ម (TRIPS Agreement) និងច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ។

-គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា បានរៀបចំកិច្ចប្រជុំលើកទី២ កាលពីថ្ងៃ ២០ ខែ សីហា ឆ្នាំ ២០០៩ ដែលពិភាក្សាស៊ីជម្រៅទៅលើ : កិច្ចសហប្រតិបត្តិការរបស់អជ្ញាធរមានសមត្ថកិច្ច ទាក់ទងនឹងការដោះស្រាយវិវាទ និងការអនុវត្តកម្មសិទ្ធិបញ្ញា សេចក្តីព្រាងច្បាប់អាជ្ញាប័ណ្ណបញ្ជាសម្រាប់សុខភាពសាធារណៈ ការធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុន Microsoft រួមទាំងអង្គភាពគ្រប់គ្រងសិទ្ធិរួម (Collective Management Organization) ។

-គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា បានធ្វើសេចក្តីជូនដំណឹងដល់គ្រប់ស្ថានីយ៍ទូរទស្សន៍ស្តីពីការហាមចាក់ផ្សាយបទចម្រៀងខារ៉ាអូខេ ខ្សែភាពយន្ត និងវីដេអូ ដែលគ្មានការអនុញ្ញាតពីម្ចាស់សិទ្ធិ។

-លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា បានជួបប្រជុំកាលពីថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៩ ដោយបានពិនិត្យឃើញថា មានមាត្រាមួយចំនួននៃសេចក្តីព្រាងច្បាប់ថ្នាំជក់ មិនទាន់ស៊ីសង្វាក់ទៅនឹងច្បាប់ម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់នៃព្រះរាជាណាចក្រកម្ពុជា ដែលគួរកែសម្រួលឡើងវិញក្នុងរង្វង់អន្តរក្រសួងសម្រាប់កិច្ចប្រជុំនៅទីស្តីការគណៈរដ្ឋមន្ត្រី។

### ៧.១-ការងារផ្សព្វផ្សាយ និង សហប្រតិបត្តិការអន្តរជាតិ ផ្នែកកម្មសិទ្ធិបញ្ញា

ក្រសួងបានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការផ្សព្វផ្សាយ និង ការពង្រឹងការការពារកម្មសិទ្ធិបញ្ញា នៅតាមស្រទាប់សិស្ស និស្សិត ប្រជាជន ក៏ដូចជាអាជីវករទាំងអស់ ដើម្បីឱ្យពួកគេកាន់តែមានការយល់ដឹងស៊ីជម្រៅពីកម្មសិទ្ធិបញ្ញា និងចូលរួមលើកស្ទួយការការពារកម្មសិទ្ធិបញ្ញា។ នៅឆ្នាំ២០០៩នេះ បានបណ្តុះបណ្តាលអំពីមុខជំនាញកម្មសិទ្ធិបញ្ញាក្នុងនិងក្រៅប្រទេស ជូនដល់មន្ត្រីក្រសួងពាណិជ្ជកម្ម និងក្រសួងពាក់ព័ន្ធ អាជីវករ សាធារណៈជន ដោយមានការជួយឧបត្ថម្ភពីបណ្តាប្រទេសជាមិត្ត និងអង្គការអន្តរជាតិនានា រួមមានៈ

-រៀបចំសិក្ខាសាលាបំប៉នជំនាញកម្មសិទ្ធិបញ្ញា ក្នុងប្រទេស ៥លើក និងថ្នាក់តំបន់ ៣លើក សរុបសិក្ខាកាម ៤០៤នាក់ ក្នុងនោះ ជនជាតិកម្ពុជា ៣៤៦នាក់ និងជនបរទេស ៥៨នាក់។

-បញ្ជូនមន្ត្រីជំនាញទៅចូលរួមសិក្ខាសាលាក្រៅប្រទេស ៤០លើក សិក្ខាកាមសរុប ៩៤នាក់ ក្នុងនោះ មន្ត្រីក្រសួងពាណិជ្ជកម្ម ៤៥នាក់ និងអង្គភាពពាក់ព័ន្ធ ៤៩នាក់។

-ការបណ្តុះបណ្តាល ក៏ត្រូវបានតម្រង់ទិសទៅដល់ការបណ្តុះបណ្តាលចៅក្រម ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង និងក្រឡាបញ្ជី ដែលកំពុងបម្រើការនៅតាមតុលាការរាជធានី-ខេត្ត ផងដែរ។

### ៧.២-ការងារសហប្រតិបត្តិការអន្តរជាតិខាងវិស័យកម្មសិទ្ធិកម្មសិទ្ធិបញ្ញា

-ក្រសួងបានយកចិត្តទុកដាក់យ៉ាងខ្លាំង លើការងារសហប្រតិបត្តិការអន្តរជាតិ ដោយពង្រឹងកិច្ចសហប្រតិបត្តិការជាមួយការិយាល័យកម្មសិទ្ធិបញ្ញាបរទេស និងអង្គការអន្តរជាតិនានា ស្វែងរកការឧបត្ថម្ភទាំងសម្ភារៈបច្ចេកទេស និងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពមន្ត្រីនាយកដ្ឋានកម្មសិទ្ធិបញ្ញា និងមន្ត្រីអនុវត្តកម្មសិទ្ធិបញ្ញា។

-បានធ្វើសំណើផ្លូវការនូវការបង្កើតកម្មវិធីថ្នាក់តំបន់ Regional Program on Geographical Indications Project សម្រាប់៤ប្រទេស ដោយបានស្នើសុំឱ្យបង្កើតការិយាល័យនេះនៅក្នុងប្រទេសកម្ពុជា ទៅទីភ្នាក់ងារបារាំងដើម្បីការអភិវឌ្ឍន៍ (AFD) ដើម្បីពិចារណា និងសម្រេចលើបេក្ខភាពរបស់ប្រទេសកម្ពុជា។

-បានរៀបចំធ្វើសំណើសុំជំនួយបច្ចេកទេស ពីអង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO) ដើម្បីដាក់ក្នុងគម្រោងអភិវឌ្ឍន៍វិស័យកម្មសិទ្ធិបញ្ញា ក្នុងរយៈពេលវែងសម្រាប់នាយកដ្ឋានកម្មសិទ្ធិបញ្ញា។

### ៧.៣-សហប្រតិបត្តិការគម្រោងរៀបចំច្បាប់ ស្តីពីការសំគាល់ភូមិសាស្ត្រទំនិញ

-បានសហការរៀបចំជាមួយ **លោក ហ្សង់ ម៉ែរីប្រេង** អ្នកគ្រប់គ្រងគម្រោងនៃអង្គការហ្គ្រេត( GRET ) ស្តីពីការផ្សព្វផ្សាយផលិតផលម្រេចកំពត នៅសហគមអឺរ៉ុប ក្នុងតំបន់ Aquitaine ប្រទេសបារាំង។

-ទទួលបានការបណ្តុះបណ្តាលពីជំនាញការបារាំងគឺលោក Charles Perraud និង Jean-Claude Pons ដើម្បីធ្វើការតាមដាន និងត្រួតពិនិត្យលើការអនុវត្តន៍ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់សមាគមលើកកំពស់ស្ករត្នោតកំពង់ស្ពឺ និងសមាគមលើកកំពស់ម្រេចកំពត និងបានទទួលការបណ្តុះបណ្តាលពីលោកស្រី **ហោឡែន ពីណូ** ជំនាញការបារាំង មកពីមជ្ឈមណ្ឌលនៃវិទ្យាស្ថានជាតិនៃការហៅតាមប្រភពដើមផលិតផលនៅតំបន់ប៉ូ ( INAO center of PAU ) ក្នុងការពិនិត្យបែបបទចុះបញ្ជីផលិតផលសម្គាល់ភូមិសាស្ត្រ និងការការពារផលិតផលសម្គាល់ភូមិសាស្ត្រ។

### ៧.៤-ការងារបោះពុម្ពផ្សាយព្រឹត្តិប័ត្រផ្លូវការ

នេះជាផ្នែកមួយតម្រូវដោយច្បាប់ ដើម្បីឱ្យការចុះបញ្ជីម៉ាកមានតម្លាភាព ទុកលទ្ធភាពឱ្យភាគីទី៣មានសិទ្ធិប្តឹងជំទាស់ទៅនឹងការចុះបញ្ជីម៉ាក។ ក្រសួងបានបោះពុម្ពព្រឹត្តិប័ត្រផ្លូវការ ( Official Gazette) បានចំនួន ១២ លេខ គឺពីលេខ ១០៧ ដល់ ១១៨ ដើម្បីផ្សព្វផ្សាយជាសាធារណៈ។

### ៧.៥-គម្រោងកម្មសិទ្ធិបញ្ញា ៣៩ សកម្មភាព (Pillar 1)

ក្នុងចំណោមគម្រោងអនុវត្តកម្មសិទ្ធិបញ្ញាទាំង ៣៩ សកម្មភាព ក្រសួងបានរៀបចំជាគម្រោងអាទិភាព និងបានបំពេញបែបបទតាមគំរូរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ដើម្បីស្នើសុំជំនួយពីធនាគារពិភពលោក និងអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ព្រមទាំងស្វែងរកដៃគូឧបត្ថម្ភផ្សេងទៀត ដើម្បីអនុវត្តគម្រោងកម្មសិទ្ធិបញ្ញាទាំង ៣៩ សកម្មភាព ឱ្យទទួលបានលទ្ធផលល្អ។

### ៧.៦-សហប្រតិបត្តិការគម្រោង ECAP III

ចំពោះគម្រោង ECAP III ក្រសួងបានសហការអនុវត្ត ប្រកបដោយជោគជ័យ លើផ្នែក :

១-ការកសាងប្រព័ន្ធច្បាប់ និងបទបញ្ញត្តិផ្នែកកម្មសិទ្ធិបញ្ញា

២-ការធ្វើទំនើបភាវូបនីយកម្មប្រព័ន្ធគ្រប់គ្រងកម្មសិទ្ធិបញ្ញា

៣-ការពង្រឹងការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា

៤-ការផ្សព្វផ្សាយចំណេះដឹងសាធារណៈ។

បានចូលរួមតាក់តែង និងផ្តល់យោបល់លើផែនការសកម្មភាព សម្រាប់អនុវត្តគម្រោង ECAP III នៅឆ្នាំ ២០១០ ជាបន្ត។

### ៧.៧-គម្រោងបង្កើនសមត្ថភាពកម្មសិទ្ធិបញ្ញា និងការអភិវឌ្ឍន៍ចីរភាព

បានសហការរៀបចំអនុវត្តគម្រោងបង្កើនសមត្ថភាពកម្មសិទ្ធិបញ្ញា និងការអភិវឌ្ឍន៍ចីរភាពនៅកម្ពុជា ដែលអនុវត្តដោយសន្និសិទសហប្រជាជាតិ ស្តីពីពាណិជ្ជកម្ម និងការអនុវត្តន៍ (UNCTAD) និងមជ្ឈមណ្ឌលអន្តរជាតិសម្រាប់ពាណិជ្ជកម្ម និងការអនុវត្តន៍ចីរភាព (ICTSD)។ គម្រោងនេះត្រូវបានបង្កើតឡើងក្នុងគោលបំណង :

-បង្កើនការយល់ដឹងពីការវិវត្តនៃការអនុវត្តន៍កិច្ចព្រមព្រៀងពាណិជ្ជកម្មពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា។

-ពង្រឹងសមត្ថភាពមន្ត្រីរបស់កម្ពុជាលើការវិភាគ និងចរចាដើម្បីជំរុញឱ្យពួកគេអាចចូលរួមក្នុងការចរចាដែលពាក់ព័ន្ធទៅនឹងវិស័យកម្មសិទ្ធិបញ្ញា ក្នុងគោលបំណងឆ្ពោះទៅរកការអភិវឌ្ឍន៍ ដែលមានចីរភាព។

### ៧.៨-សហប្រតិបត្តិការកិច្ចព្រមព្រៀងក្របខ័ណ្ឌពាណិជ្ជកម្ម និងវិនិយោគ(TIFA) និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី

-បានចូលរួមប្រជុំអំពីទំនាក់ទំនងកិច្ចព្រមព្រៀងវិនិយោគទ្វេភាគី រវាងកម្ពុជា-ជប៉ុន។

-ផ្តល់យោបល់លើកិច្ចព្រមព្រៀងសេរីអាស៊ាន ASEAN-ANZ FTA និង រៀបចំសិទ្ធិប្រទានសម្រាប់ចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។

-ផ្តល់យោបល់លើកិច្ចព្រមព្រៀង ASEAN-EU Non paper

### ៧.៩-ក្រុមការងារអាស៊ាន ស្តីពីកិច្ចសហប្រតិបត្តិការកម្មសិទ្ធិបញ្ញា AWGIPC

បានរៀបចំកិច្ចប្រជុំ AWGIPC លើកទី៣២ និងបានផ្តល់យោបល់ទៅលើ :

-កិច្ចសហប្រតិបត្តិការពិនិត្យខ្លឹមសារប្រកាសនីយប័ត្រតក្កកម្មអាស៊ាន ( ASPEC ) : ត្រូវបានផ្តួចផ្តើមបង្កើតឡើង ដើម្បីផ្តល់លក្ខណៈងាយស្រួលដល់តក្កករ ដើម្បីទទួលបានការចុះបញ្ជីតក្កកម្មកាន់តែងាយស្រួលជាងមុន។

-កម្មសិទ្ធិបញ្ញាផ្ទាល់ (IP DIRECT) : ការផ្តួចផ្តើម IP DIRECT ដែលជាបញ្ជីព័តិមានតាមអាំងទែណែត ផ្តល់ព័តិមាននៃប្រភព និងសេវាដែលពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា នៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន ដែលជាប្រភពបញ្ជូរតែមួយ មានសារៈសំខាន់ និងផលប្រយោជន៏សម្រាប់ការធ្វើអាជីវកម្ម និងភាគីមានផលប្រយោជន៏ដទៃទៀត ។

-ការកម្រិត និងការលើកលែងសិទ្ធិអ្នកនិពន្ធ និងសិទ្ធប្រហាក់ប្រហែល : កិច្ចប្រជុំរបស់ក្រុមការងារអាស៊ាន ស្តីពីកិច្ចសហប្រតិបត្តិការកម្មសិទ្ធិបញ្ញា ស្ថិតក្នុងការពិភាក្សាលើដំណើរការកំណត់ការកម្រិត និងការលើកលែងសិទ្ធិអ្នកនិពន្ធ និងសិទ្ធប្រហាក់ប្រហែល នៅក្នុងប្រព័ន្ធច្បាប់របស់ប្រជាជាតិជាសមាជិកអាស៊ាន ដែលជាផ្នែកមួយនៃការបន្តសកម្មភាពកិច្ចសហប្រតិបត្តិការកម្មសិទ្ធិបញ្ញា។ បញ្ហាសិទ្ធិអ្នកនិពន្ធ គឺជាការដាក់ទម្ងន់ទៅលើសមាជិកអាស៊ាន ក្នុងការបន្តកិច្ចខិតខំប្រឹងប្រែងដើម្បីរក្សាសមតុល្យរវាងផលប្រយោជន៏របស់ម្ចាស់សិទ្ធិ និងផលប្រយោជន៏សាធារណៈ ដោយសារមូលហេតុនៃការកើនឡើងតម្រូវការសង្គម និងអ្នកពាក់ព័ន្ធក្នុងការចូលទៅកាន់ព័តិមានសម្រាប់ការសិក្សាស្រាវជ្រាវ និងចំណេះដឹង កាន់តែទូលំទូលាយថែមទៀត ក្នុងគោលបំណងបង្កើតឱ្យមានផលិតផលវប្បធម៌សម្បូរបែប។

### ៧.១០-កិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុន Microsoft

បន្ទាប់ពីទទួលភារកិច្ច ដែលប្រគល់ឱ្យពីគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា បានជួបប្រជុំគ្នាចំនួន ៣លើក ដើម្បីពិភាក្សាលម្អិតពីគុណសម្បត្តិ និងគុណវិបត្តិ លើអនុស្សរណៈយោគយល់គ្នា (Memorandum of Understanding) រវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុន Microsoft ស្តីពីការធ្វើកិច្ចសហប្រតិបត្តិការជាមួយកម្ពុជា លើការងារបណ្តុះបណ្តាល អប់រំ តាមសាកលវិទ្យាល័យ និងមហាវិទ្យាល័យ ជាថ្នូរមកវិញគឺការប្រើប្រាស់កម្មវិធីកុំព្យូទ័រសុទ្ធ នៅតាមអង្គភាពរដ្ឋ និងគ្រឹះស្ថានសិក្សារបស់កម្ពុជា។

### ៧.១១-គម្រោងបង្កើតអនុគណៈកម្មាធិការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា

អនុគណៈកម្មាធិការនេះ មានគោលបំណងបង្កើនកិច្ចសហប្រតិបត្តិការរវាងអជ្ញាធរមានសមត្ថកិច្ច ដើម្បី

អនុវត្តច្បាប់កម្មសិទ្ធិបញ្ញាឱ្យរលូន និងមានប្រសិទ្ធភាព ហើយនិងមានភារកិច្ចបណ្តុះបណ្តាល ផ្សព្វផ្សាយកម្មសិទ្ធិបញ្ញាទៅដល់សាធារណៈជន រៀបចំកម្មវិធីសិក្សាកម្មសិទ្ធិបញ្ញានៅតាមសាកលវិទ្យាល័យ មហាវិទ្យាល័យ វិទ្យាល័យ និងបកប្រែទៅជាភាសាខ្មែររាល់ឯកសារកម្មសិទ្ធិបញ្ញា សម្រាប់ការបង្រៀន ដើម្បីជាជំនួយដល់គ្រូបង្រៀនសិស្ស និងមន្ត្រីអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា ។

អង្គប្រជុំបានសម្រេចជ្រើសរើសក្រសួងពាណិជ្ជកម្មធ្វើជាប្រធាន ក្រសួងអប់រំ យុវជន និងកីឡា ជាអនុប្រធានអចិន្ត្រៃយ៍។ ចំណែកឯអនុប្រធានធម្មតាមានចំនួន៨ទៀតគឺ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងយុត្តិធម៌ ក្រសួងព័ត៌មាន និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អមដោយសមាជិកអនុគណៈកម្មាធិការមកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន ក្រសួងទេសចរណ៍ ក្រសួងមហាផ្ទៃ និងទីស្តីការគណៈរដ្ឋមន្ត្រី។

### ៧.១២-សេចក្តីពន្យល់នៃវិធាន សំរាប់អនុវត្តមាត្រា ១១ និង មាត្រា ១៣ នៃអនុសញ្ញាស្តីពីការត្រួតពិនិត្យថ្នាំជក់ ក្របខ័ណ្ឌអង្គការសុខភាពពិភពលោក

សេចក្តីពន្យល់នៃវិធានសម្រាប់អនុវត្តមាត្រា ១១ និង ១៣ នៃអនុសញ្ញាស្តីពីការត្រួតពិនិត្យថ្នាំជក់ ក្របខ័ណ្ឌអង្គការសុខភាពពិភពលោក បានហាមឃាត់ចំពោះការប្រើប្រាស់រូបភាព ពណ៌ ឬព័ត៌មាន នៅលើសំបកវេចខ្ចប់នៃផលិតផលថ្នាំជក់ ដែលមានភាពទាក់ទាញ ធ្វើឱ្យអតិថិជនភ័ន្តច្រឡំថា កាត់បន្ថយគ្រោះថ្នាក់ដល់សុខភាព និងហាមឃាត់មិនឱ្យមានការផ្សាយពាណិជ្ជកម្ម ចំពោះទ្រង់ទ្រាយសំបកវេចខ្ចប់នៃផលិតផលថ្នាំជក់ ដែលរចនាឡើងធ្វើឱ្យមានភាពទាក់ទាញអារម្មណ៍ពីអតិថិជន ។

ក្រសួងពាណិជ្ជកម្មបានធ្វើលិខិតជូនក្រសួងសុខាភិបាល ដើម្បីសម្តែងការព្រួយបារម្ភអំពីសេចក្តីពន្យល់នៃវិធានសម្រាប់អនុវត្តមាត្រា ១១ និង១៣ នៃអនុសញ្ញាស្តីពីការត្រួតពិនិត្យថ្នាំជក់ ក្នុងក្របខ័ណ្ឌអង្គការសុខភាពពិភពលោក ដែលផ្ទុយនឹងច្បាប់ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ នៃព្រះរាជាណាចក្រកម្ពុជា និងកិច្ចព្រមព្រៀងពាណិជ្ជកម្ម ទាក់ទងទៅនឹងកម្មសិទ្ធិបញ្ញា (TRIPs) និងអនុសញ្ញាទីក្រុងប៉ារីស (Paris Convention) ។

## ៨-ការធានាសន្តិសុខស្បៀង

-ទំនិញស្បៀង គឺជាទំនិញយុទ្ធសាស្ត្រ ដែលមានឥទ្ធិពលដោយផ្ទាល់ដល់ជីវភាពសង្គមទាំងមូល ដែលចាំបាច់រដ្ឋត្រូវតែធ្វើការគ្រប់គ្រង តាមដាន និងសម្របសម្រួលរាល់ការធ្វើចរាចរ ទិញ លក់ និងស្តុកបម្រុងដើម្បីដោះស្រាយបញ្ហាប្រឈមនានាជាយថាហេតុ។ ក្នុងនាមរដ្ឋ ក្រុមហ៊ុនគ្រីនត្រេដ ដែលជាអង្គភាពក្រោមអាណាព្យាបាលរបស់ក្រសួងពាណិជ្ជកម្ម ទទួលភារកិច្ចផ្ទាល់ក្នុងការទិញស្បៀង កសិផល ដើម្បីរក្សាស្ថេរភាពថ្លៃលើទីផ្សារ និងទ្រទ្រង់ថ្លៃរបស់កសិករ ជាពិសេស បម្រើដល់គោលដៅរក្សាសន្និធិត្រៀមបំរុងជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល សម្រាប់ដោះស្រាយសំណូមពរចាំបាច់ក្នុងពេលប្រទេសជាតិជួបគ្រោះធម្មជាតិ ឬវិបត្តិផ្សេងៗ (គ្រោះទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ..)។ ជាក់ស្តែង ក្នុងឆ្នាំ២០០៩នេះ កម្ពុជាត្រូវទទួលផលប៉ះពាល់ដោយសារខ្យល់ព្យុះកេតសាណា នៅក្នុងខេត្តចំនួន៥ ដែលនៅពេលនោះ ក្រសួងបានចាត់ចែងឱ្យមានការចូលរួមធ្វើអន្តរាគមន៍ជួយដល់ខេត្តភ្លាមៗនូវអង្ករចំនួន ២០០តោន។

-ក្រុមហ៊ុនគ្រីនត្រេដ បានសហការជាមួយសមាគមម៉ាស៊ីនកិនស្រូវ ដើម្បីស្រាវជ្រាវវិធីសាស្ត្រ និងបច្ចេកទេសថ្មីក្នុងការផលិតនូវផលិតផលស្រូវសំរាប់ធ្វើការនាំចេញ។ បរិមាណស្រូវលើសសេចក្តីត្រូវការក្នុងស្រុកដែលអាចធ្វើការនាំចេញមានប្រមាណ ៣,២លានតោន ហើយការនាំចេញផ្លូវការទៅបរទេសឆ្នាំ២០០៩ មានបរិមាណ ១២,០០០តោន ក្នុងនោះ នាំចេញទៅកាន់សហភាពអឺរ៉ុបអាស៊ី អាហ្វ្រិក អាមេរិក។

-តាមការគណនា ស្រូវដែលអាចផលិតបាន នៅឆ្នាំ ២០០៩ មានចំនួន ៧,២០០,០០០តោន (ស្រូវវស្សា ៥,៧០០,០០០តោន ស្រូវប្រាំង ១,៥០០,០០០តោន។ ការប្រើប្រាស់ក្នុងស្រុកអាចមានចំនួន ៤,០០០,០០០តោន និងនៅសល់សំរាប់នាំចេញប្រមាណ ៣,២០០,០០០តោន បរិមាណអង្ករនាំចេញប្រមាណ ១,៧៦០,០០០តោន។ ផ្អែកលើទិន្នន័យទាំងអស់នេះ ក្រសួងពាណិជ្ជកម្មនឹងបន្តតាមដាន គ្រប់គ្រងសកម្មភាពចរាចរទំនិញស្បៀងឱ្យបានជាប់ជាប្រចាំ បម្រុងទុកដោយប្រុងប្រយ័ត្ននូវសន្និធិស្បៀង ហើយបានត្រៀមលក្ខណៈគ្រប់បែបយ៉ាងក្នុងការអនុវត្តកិច្ចអន្តរាគមន៍ស្បៀងសម្រាប់ដោះស្រាយការលំបាកខាងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ នៅពេលជួបគ្រោះមហន្តរាយ ឬបញ្ហារំជើបរំជួលទីផ្សារជាយថាហេតុ។

## III-ទិសដៅអនុវត្តការងារឆ្នាំបន្ត

ផ្តើមចេញពីផែនការសកម្មភាពរបស់ក្រសួងពាណិជ្ជកម្មសម្រាប់រយៈពេល៥ឆ្នាំ(២០០៩-២០១៣) ក្នុងការចូលរួមអនុវត្តនីយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដំណាក់កាលទី២ និងដោយយោងលើការវាយតម្លៃលើលទ្ធផលស្នាដៃក្នុងឆ្នាំកន្លងទៅ ការប្រមើលមើលលើបញ្ហាប្រឈមនានាទាំងកត្តាសត្យានុម័ត និងអត្តនោម័ត និងដោយឆន្ទៈមោះមុតក្នុងការចូលរួមខិតខំអនុវត្តឱ្យបានសម្រេច កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលលើវិស័យសេដ្ឋកិច្ច វិនិយោគ ពាណិជ្ជកម្ម ព្រមទាំងកម្មវិធីកំណែទម្រង់រដ្ឋលើគ្រប់ផ្នែក ដើម្បីកំណើនការងារ វឌ្ឍនភាពសង្គម ភាពសុខដុមរមនា និងការកាត់បន្ថយភាពក្រីក្រ *ក្រសួងពាណិជ្ជកម្មកំណត់នូវទិសដៅភារកិច្ចសម្រាប់ការអនុវត្តក្នុងឆ្នាំ២០១០* ដូចតទៅ:

❖ ***ការងាររដ្ឋបាល ហិរញ្ញវត្ថុ និងអភិវឌ្ឍន៍ធនធានមនុស្ស:***

-ខិតខំបញ្ចប់ដំណើរការផ្ទេរទីតាំងទីស្តីការក្រសួងទៅកន្លែងថ្មី ស្ថិតនៅតាមវិថីក្រសួងពាណិជ្ជកម្ម ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ ឱ្យបានឆាប់រហ័សដោយអនុវត្តការកត់ត្រា ការជម្រះទ្រព្យសម្បត្តិ និងបែបបទផ្ទេរប្រគល់-ទទួល រវាងទីតាំងចាស់ និងទីតាំងថ្មី ឱ្យស្របតាមនីតិវិធីហិរញ្ញវត្ថុ។

-រៀបចំបំពាក់បណ្តាញអ៊ិនធើណែតក្នុងទីស្តីការក្រសួង ដែលឆ្លើយតបបានតម្រូវការប្រើប្រាស់នៅគ្រប់អង្គភាពនាយកដ្ឋាន និងផ្លាស់ប្តូរប្រព័ន្ធចរាចរលិខិតស្នាមលើផ្នែកខ្លះក្នុងកិច្ចការរដ្ឋបាល ឱ្យកាន់តែមានលក្ខណៈជឿនលឿន ឆាប់រហ័ស និងសំចៃបានពេលវេលា ថវិកា ពីវិធីថតចម្លង និងបញ្ជូនឯកសារដោយដៃ ទៅជាការបញ្ជូន និងចែកចាយតាមអ៊ីនធើណែតវិញ។

-បន្តចាត់ចែងគ្រប់គ្រងឱ្យបានច្បាស់លាស់ទ្រព្យសម្បត្តិរបស់ក្រសួង ទាំងនៅទីស្តីការកណ្តាល និងនៅតាមអង្គភាពក្រោមឱវាទ រាប់គិតទាំងក្រុមហ៊ុនគ្រីនត្រេដ មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត និងទ្រព្យសម្បត្តិអតីតក្រុមហ៊ុនកាំប៉ិចស៊ីមដែលទទួលបានមកវិញតាមអំណាចសាលដីការតុលាការកំពូល។ ស្រាវជ្រាវករណីនីមួយៗដែលជាឧបសគ្គរាំរាំងស្ទះដល់ការធ្វើប័ណ្ណសំគាល់កម្មសិទ្ធិដីធ្លីអគាររបស់រដ្ឋ ដើម្បីរិះរកវិធានការដោះស្រាយបញ្ចប់បញ្ហា។

-អនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដោយបន្តផ្អែកលើគោលការណ៍ត្បិតត្បៀតចំណាយ ការបន្តកៀងគរចំណូលពីគ្រប់ប្រភពដើម្បីបំពេញកាតព្វកិច្ចបង់ចំណូលជូនរដ្ឋតាមផែនការ ។

-ចូលរួមជាមួយក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ អនុវត្តកម្មវិធីការងារលើវិស័យកំណែទម្រង់រដ្ឋបាលសាធារណៈ ដោយផ្តោតទៅលើចំណុចដៅចម្បង៧គឺ: (១)ការរៀបចំកែសម្រួល និងបោះពុម្ពកម្រងឯកសារស្តីពីកម្រងព័ត៌មានសេវាសាធារណៈ សម្រាប់ការចែកផ្សព្វផ្សាយទូលាយដល់អ្នកត្រូវការសេវាពីរដ្ឋ និងប្រជាពលរដ្ឋទូទៅ (២)ពិនិត្យលើលទ្ធភាពនៃការបើកការិយាល័យច្រកចេញចូលតែមួយបន្ថែមទៀតនៅតាមស្រុក ក្រុង ខណ្ឌ គោលដៅចំនួន៧ ដែលមានលក្ខណៈសម្បត្តិសមស្រប រួមជាមួយការពិចារណាលើការធ្វើសនិទានកម្មនៃការផ្ទេរមុខងារឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងក្របខ័ណ្ឌនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (**កជអប**) (៣) ការរៀបចំប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ តាមរយៈការធ្វើជំរឿនមន្ត្រីរាជការលើកទី៣ និង ការផ្តល់អត្តសញ្ញាណប័ណ្ណគំរូថ្មី ដែលមានលក្ខណៈស្វ័យប្រវត្តិកម្ម ចាប់ពីត្រីមាសទី២ តទៅ ។

-ពង្រឹងការទទួលខុសត្រូវរបស់មន្ត្រីរាជការ តាមមុខនាទីដែលបានកំណត់ ។ បង្កើតតារាងគ្រប់គ្រងការចាត់បញ្ជូនមន្ត្រីឱ្យចូលរួមក្នុងយន្តការនានា ឬចុះបំពេញបេសកកម្មផ្សេងៗ ពិនិត្យសង្កេតចលនាបម្រែបម្រួលមន្ត្រីរាជការ និងគ្រប់គ្រងដោយមធ្យ័តលើសំណុំឯកសារមន្ត្រីតាមលក្ខការណ៍បច្ចេកទេស ។

-អនុវត្តកម្មវិធីបណ្តុះបណ្តាលមន្ត្រីរាជការ ទាំងនៅក្នុង និងក្រៅប្រទេស លើប្រធានបទដែលទាក់ទងនឹងវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ ការវិភាគស្រាវជ្រាវព័ត៌មានទីផ្សារ និងភាសាអង់គ្លេស ។ល។ ក្រោមរូបភាពជាសិក្ខាសាលា ឬវគ្គសិក្សារយៈពេលខ្លី-មធ្យម និងពិនិត្យលទ្ធភាពបើកវគ្គបណ្តុះបណ្តាលបន្តសម្រាប់មន្ត្រីបង្គោលអាចមានឱកាសចែករំលែកចំណេះដឹងដល់មន្ត្រីដទៃទៀតនៅនឹងកន្លែង តាមរយៈការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលរបស់ក្រសួងពាណិជ្ជកម្មដោយផ្ទាល់មួយ ។

-បន្តចុះជួយបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីរាជការ នៅតាមមន្ទីរពាណិជ្ជកម្ម ដែលជាអ្នកអនុវត្តផ្ទាល់នូវគោលនយោបាយរបស់ក្រសួងនៅមូលដ្ឋាន ឱ្យបានគ្រប់ទាំង២៤មន្ទីរ នៅក្នុងដំណាក់កាលដំបូងនៃការសាកល្បងអនុវត្តកិច្ចសហការជាមួយសាលាភូមិន្ទរដ្ឋបាល ។

### ❖ ការលើកកំពស់ និងពង្រឹងសេវារដ្ឋបាលសាធារណៈឱ្យកាន់តែប្រសើរឡើង

-បន្តចូលរួមកម្មវិធីកំណែទម្រង់រដ្ឋបាល ដើម្បីឱ្យការផ្តល់សេវាសាធារណៈខាងវិស័យពាណិជ្ជកម្ម កាន់តែមានគុណភាព និងឆាប់រហ័ស ឆ្លើយតបតាមការចង់បានរបស់វិស័យឯកជន រួមជាមួយនិងការពង្រឹង ព្រមទាំងការលើកកម្ពស់ប្រសិទ្ធភាពយន្តការសេដ្ឋកិច្ចទីផ្សារ ការកសាងច្បាប់ពាណិជ្ជកម្ម

-បង្កើតគេហទំព័រសម្រាប់វិស័យចុះបញ្ជីពាណិជ្ជកម្ម ដើម្បីសម្រួលដល់ការទទួលព័ត៌មានរបស់ធុរៈជន ។

-ពង្រឹងមណ្ឌលសាខាចុះបញ្ជីតាមបណ្តាខេត្តដែលមានស្រាប់ និងពិនិត្យកែសម្រួលដែនសមត្ថកិច្ចមណ្ឌលសាខាចុះបញ្ជីនៅតាមខេត្តខ្លះ ឱ្យស្របនឹងសំណូមពរនៃការបង្កិតខ្លីនូវចរាចរឯកសារពីសំណាក់អតិថិជន ។

-សហការជាមួយក្រសួង ស្ថាប័ននានា ពិនិត្យលទ្ធភាពបើកការិយាល័យច្រកចេញចូលតែមួយនៅស្រុក ក្រុង គោលដៅចំនួន ៧កន្លែងទៀត ដើម្បីពង្រីកសិទ្ធិអំណាចដល់ថ្នាក់ក្រោមជាតិ តាមរបបវិមជ្ឈការ និងវិសហមជ្ឈការ និងបង្កិតសេវារដ្ឋបាលសាធារណៈឱ្យជិតប្រជាពលរដ្ឋ ។

-រៀបចំបែបបទ និងនីតិវិធីចេញវិញ្ញាបនប័ត្រប្រភពដើមទំនិញ តាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីសម្រួលដល់ការស្នើសុំបែបបទនាំចេញ-នាំចូល របស់អតិថិជន។

-បង្កើតកម្មវិធីលើកទឹកចិត្ត ចំពោះក្រុមហ៊ុនប្រមូលទិញកសិផល និងកសិករ (ក្នុងលក្ខណៈជាកសិ-កិច្ចសន្យា " Contract Farming " ) ។

-យកចិត្តទុកដាក់បន្ថែមទៀត ការអនុវត្តគោលនយោបាយផ្សារភ្ជាប់ពាណិជ្ជកម្ម ទៅនឹងលក្ខខ័ណ្ឌពលកម្ម និងការការពារសិទ្ធិកម្មករ ដែលជាកត្តាស្នូល និងសំខាន់បំផុតក្នុងការដណ្តើមអ្នកបញ្ជាទិញសម្លៀកបំពាក់ពីបរទេស

-ធ្វើសាមញ្ញកាវូបនីយកម្មដំណើរការនាំចេញ តាមរយៈការធ្វើសិក្ខាសាលាផ្សព្វផ្សាយព័ត៌មានអំពី កម្មវិធី និងនីតិវិធីនាំចេញ-នាំចូល ឱ្យបានទូលំទូលាយ។ ជាមួយគ្នានេះដែរ ចូលរួមជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធ ពង្រឹងយន្តការរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស និងបន្តអនុវត្តយន្តការសម្រួលពាណិជ្ជកម្ម តាមរយៈការគ្រប់គ្រងហានិភ័យ ធ្វើឱ្យការនាំចូល នាំចេញទំនិញរបស់ ផ្នែកឯកជនកាន់តែងាយស្រួល រហ័សជាងមុន

-បង្កើនល្បឿនក្នុងការពិនិត្យដោះស្រាយពាក្យបណ្តឹង ស្នើសុំទប់ស្កាត់ការរំលោភបំពានម៉ាក ក៏ដូចជាពាក្យបណ្តឹងលុបម៉ាកឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ជៀសវាងភាពកកស្ទះជាយថាហេតុដែលនាំឱ្យជះឥទ្ធិពលមិនល្អដល់ការអនុវត្តន៍ច្បាប់កម្មសិទ្ធិបញ្ញានៅកម្ពុជា។

-បន្តតាមដាន ការដាក់លក្ខខ័ណ្ឌដល់ការចុះបញ្ជីម៉ាកដែលមានវិវាទក្នុងប្រព័ន្ធ IPAS ដើម្បីធានាដល់ប្រសិទ្ធភាពការងាររបស់ការិយាល័យចំណុះនាយកដ្ឋានកម្មសិទ្ធិបញ្ញា។

-សហការសិក្សាស្រាវជ្រាវ បង្កើនការយល់ដឹងផ្នែកដោះស្រាយវិវាទកម្មសិទ្ធិបញ្ញាបរទេស មានដូចជាការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ វិធាននៃមជ្ឈត្តកម្ម និងសន្ធានកម្ម ដើម្បីពង្រីកសមត្ថភាពក្នុងការពិនិត្យ និងដោះស្រាយពាក្យបណ្តឹងឱ្យកាន់តែមានប្រសិទ្ធភាព ។

-ប្រកាន់ខ្ជាប់វប្បធម៌ណែនាំ បញ្ចុះបញ្ចូលឱ្យអ្នករំលោភបំពានផ្នែកកម្មសិទ្ធិបញ្ញា ប្រែក្លាយខ្លួនឱ្យទៅជាម្ចាស់កម្មសិទ្ធិបញ្ញា ដែលជាកញ្ចប់ទុនជាតិមួយ ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។

-បន្តបញ្ចូលទិន្នន័យម៉ាក ដែលបានចុះបញ្ជីហើយទៅក្នុង Computer Database តាមប្រព័ន្ធ IPAS

-បន្តរៀបចំកែលម្អប្រព័ន្ធចុះបញ្ជីម៉ាក តាមរយៈស្វ័យប្រវត្តិកម្ម (Computerization of Trademark Registration ) ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ និងសុក្រឹត្យ ។

-ជូនដំណឹងដល់អតិថិជន ឱ្យមកចុះបញ្ជីម៉ាករបស់ខ្លួនសាជាថ្មី បន្ទាប់ពីបានចុះបញ្ជីរយៈពេល ១០ឆ្នាំ រួច។

-រៀបចំឱ្យមានមជ្ឈមណ្ឌលព័ត៌មានកម្មសិទ្ធិបញ្ញាមួយ សម្រាប់បម្រើដល់អតិថិជនដែលមានបំណងចង់ស្វែងយល់ពីកម្មសិទ្ធិបញ្ញា និយាយរួម និងនិយាយដោយឡែក ពីម៉ាកដែលបានចុះបញ្ជីរួចហើយ ឬឯកសារនានាដែលទាក់ទងនឹងការចុះបញ្ជីម៉ាក ក៏ដូចជាវិវាទនានានៅកម្ពុជា។

-បន្តរៀបចំគំរូពាក្យស្នើសុំ និងគំរូលិខិតស្នាមផ្សេងៗទៀត ជាភាសាខ្មែរ និងអង់គ្លេស ដើម្បីសម្រួលដល់ការអនុវត្តន៍ការងារចុះបញ្ជីម៉ាក ឱ្យកាន់តែមានភាពប្រសើរឡើងថែមទៀត។

❖ ***ពង្រឹងសមត្ថភាព និងសកម្មភាពត្រួតពិនិត្យផលិតផលទំនិញ ពិសេសម្ហូបអាហារៈ***

-កសាងនិងអនុវត្ត "*កម្មវិធីត្រួតពិនិត្យការនាំចូល*" ទាំងផលិតផលម្ហូបអាហារ ទាំងផលិតផលមិនមែនម្ហូបអាហារ ដែលមានបញ្ញត្តិគ្រប់គ្រងលើមូលដ្ឋាននៃការគ្រប់គ្រងហានិភ័យ

-ពង្រឹងប្រសិទ្ធភាព "*ត្រួតពិនិត្យការនាំចេញ*" ពិសេសការត្រួតពិនិត្យផ្នែករដ្ឋបាល លើផលិតផលកាត់ដេរ សំដៅបំពេញនូវល័ក្ខខ័ណ្ឌតម្រូវអំពីវិធាន GSP/MFN និងលើផលិតផលជាប់កម្រិតកំណត់ផ្សេងៗទៀតក្នុងក្របខ័ណ្ឌនៃកិច្ចសម្រួលពាណិជ្ជកម្ម

-កសាងនិងអនុវត្ត "*កម្មវិធីឃ្លាំពិនិត្យទីផ្សារ*" ក្នុងប្រទេស តាមរយៈការស្រាវជ្រាវ និងសិក្សាវាយតម្លៃនូវកម្រិតគ្រោះថ្នាក់អតិសុខុមជីវសាស្ត្រ និងផ្នែកគីមី លើម្ហូបអាហារកែច្នៃបឋម ឬកែច្នៃជាលក្ខណៈឧស្សាហកម្ម ដែលផលិតក្នុងស្រុកសំដៅធ្វើឱ្យមានភាពសមស្របតាមបញ្ញត្តិបច្ចេកទេស ពាក់ព័ន្ធនឹងម្ហូបអាហារនិងផលិតផលដែលមានបញ្ញត្តិបច្ចេកទេសគ្រប់គ្រង សំដៅលុបបំបាត់ការលួចប្រើសារធាតុគីមីហាមឃាត់ និងកាត់បន្ថយឱ្យនៅត្រឹមកម្រិតសមស្របនូវសំណល់ថ្នាំសម្លាប់សត្វល្អិត លើផលិតផលកសិម្ហូបអាហារសំខាន់ៗមួយចំនួន

-បង្ក្រាបការក្លែងបន្លំពាណិជ្ជកម្មផ្សេង ៗ សំដៅការពារផលប្រយោជន៍សេដ្ឋកិច្ចអ្នកប្រើប្រាស់ ដោយប្រកាន់យកវិធានការច្បាប់ជាចម្បង ជំនួសឱ្យវិធានការអប់រំណែនាំដែលធ្លាប់បានអនុវត្តប៉ុន្មានឆ្នាំកន្លងទៅនេះ ជាមួយនិងការពង្រឹងសមត្ថភាពវិជ្ជាជីវៈនៃការត្រួតពិនិត្យពាណិជ្ជកម្ម

-ពង្រឹង និងអភិវឌ្ឍស្តង់ដារគុណភាពចំពោះផលិតផលកម្ពុជា ជាមួយនឹងការកែលម្អមន្ទីរពិសោធន៍ឱ្យទំនើប ដើម្បីធានាឱ្យមានភាពស៊ីសង្វាក់គ្នាជាមួយសេចក្តីណែនាំស្តីពីសុវត្ថិភាព និងអនាម័យ ចំពោះទីផ្សារក្នុងស្រុក និងទីផ្សារនាំចេញ

-ស្រាវជ្រាវកសាងវិធីសាស្ត្រវិភាគផ្នែកមីក្រូជីវសាស្ត្រ ចំពោះមេរោគបង្កជំងឺមួយចំនួន ជាអាទិ៍ Samonella, Fecal Colifroms, Staphilococcus, Clostidiom, Bacillus Cesens, Vibrio Cholerac, Vibrio Parahaemoliticus, Visteria Monocytogenes

-ស្រាវជ្រាវកសាងវិធីសាស្ត្រវិភាគផ្នែករូប និងគីមីម្ហូបអាហារ ជាអាទិ៍ Sulfur Dioxide, Benzoic and Sorbic Acid, Nitrite Nitrate, Salicylic Acid, Boric Acid, ។ល។

❖ ***ការជំរុញពាណិជ្ជកម្ម និងអភិវឌ្ឍន៍ទីផ្សារ***

-ផ្តល់ឱកាសដល់ធុរៈជន វិនិយោគិន អាជីវករគ្រប់ស្រទាប់ ក្នុងការពង្រីកចំណងទាក់ទងផ្នែកពាណិជ្ជកម្ម ការកសាងភាពជាដៃគូ ជំរុញឱ្យមានកិច្ចចរចា និងជំនួបពាណិជ្ជកម្ម តាមរយៈការរៀបចំពិព័រណ៍ពាណិជ្ជកម្មក្នុង និងក្រៅប្រទេស ដើម្បីជំរុញសន្ទុះនៃការធ្វើចរាចរផលិតផលទំនិញនៅលើទីផ្សារ និងពង្រីកវត្តមានផលិតផលកម្ពុជានៅលើទីផ្សារក្រៅប្រទេស។

-ខិតខំជំរុញ និងលើកស្ទួយផលិតកម្មក្នុងស្រុក ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការទីផ្សារទាំងក្នុងប្រទេស និងក្រៅប្រទេស តាមរយៈការជួយគាំទ្រដល់ការអភិវឌ្ឍក្រុមហ៊ុន សហគ្រាសធុនតូច និងមធ្យម ផ្នែកកែច្នៃផលិតផលសិប្បកម្ម នេសាទ ទេសចរណ៍ និងឧស្សាហកម្មកម្មន្តសាល ដើម្បីពង្រឹងសមត្ថភាពដណ្តើមទីផ្សារ។

-កសាងគោលនយោបាយទីផ្សារក្នុងស្រុក និងទីផ្សារក្រៅប្រទេស ក្នុងទិសដៅជំរុញការនាំចេញ។ ស្របពេលជាមួយគ្នានេះ គ្រប់គ្រងទីផ្សារ និងអនុវត្តគោលនយោបាយពាណិជ្ជកម្មក្នុងស្រុកដូចជា : បិទស្លាកថ្លៃទំនិញ គ្រប់គ្រងអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការ ត្រួតពិនិត្យស្តុកទំនិញយុទ្ធសាស្ត្រ និងទំនិញចាំបាច់ តាមការកំណត់របស់រាជរដ្ឋាភិបាល។

-បន្តសិក្សាស្រាវជ្រាវបន្ថែមទៀតទៅលើ Value Chain Unit ព្រមទាំងបានចុះធ្វើការសិក្សាស្រាវជ្រាវដោយផ្ទាល់ជាមួយនឹងកសិករ ពាណិជ្ជករ និងអ្នកកែច្នៃ ដើម្បីស្វែងយល់អំពីសង្វាក់ផលិតកម្ម នៃផលិតផលសក្តានុពលក្នុងគោលបំណងចងក្រង និងផ្សព្វផ្សាយព័ត៌មានដល់បណ្តាអាជីវករ ពាណិជ្ជករ និងអ្នកវិនិយោគទាំងក្នុង និងក្រៅប្រទេស ដើម្បីជំរុញការអភិវឌ្ឍន៍ផលិតផលកម្ពុជាជាជំហ៊ានៗ ឆ្ពោះទៅកាន់ទីផ្សារពិភពលោក ។

-បន្តលើកកំពស់ផលិតភាព និងពិពិធភាពផលិតកម្ម ឱ្យទទួលបានជោគជ័យ ដោយធ្វើការសិក្សា និងអភិវឌ្ឍន៍ផលិតផលកម្រិតជាតិឱ្យមានសន្ទុះទៅមុខ។ ត្រៀមរៀបចំបោះពុម្ពសៀវភៅផលិតផលសក្តានុពល ១០មុខ ដើម្បីធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់បណ្តាផលិតករ អាជីវករ។ ជំរុញចលនាភូមិមួយ ផលិតផលមួយ ឬខេត្តមួយ ផលិតផលមួយ ឱ្យបានផុលផុសជាងមុន សំដៅពង្រីកការយល់ដឹង និងបង្កើនការយកចិត្តទុកដាក់ដល់ផលិតករ សិប្បករ ឱ្យខិតខំកែលម្អផលិតផលរបស់ខ្លួន ដើម្បីធ្វើការប្រកួតប្រជែងជាមួយមុខទំនិញដែលកំពុងធ្វើចរាចរក្នុងប្រទេស។

❖ ***រៀបចំក្របខ័ណ្ឌលិខិតបទដ្ឋានគតិយុត្តិ បទបញ្ញត្តិ ច្បាប់ ដើម្បីអភិវឌ្ឍន៍ពាណិជ្ជកម្ម***

-ជំរុញឱ្យទទួលបាននូវការអនុម័ត**សេចក្តីព្រាងច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម** ពីគណៈរដ្ឋមន្ត្រីឱ្យបានក្នុងឆ្នាំ ២០១០។

-ខិតខំបញ្ចប់ដំណាក់កាលទី១ក្នុងការជំរុញ**សេចក្តីព្រាងច្បាប់ស្តីពីអ៊ី-ពាណិជ្ជកម្ម សេចក្តីព្រាងច្បាប់ស្តីពីប្រកួតប្រជែង សេចក្តីព្រាងច្បាប់ស្តីពីតុលាការពាណិជ្ជកម្ម** ដើម្បីបញ្ជូនទៅសុំការគាំទ្រពីគណៈរដ្ឋមន្ត្រី។

-រៀបចំ និងជំរុញឱ្យចាប់ដំណើរការ ការបង្កើតមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដើម្បីដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ ដោយក្នុងនោះមាន ការជ្រើសរើសបេក្ខជន ការរៀបចំវិធាន នីតិវិធី ក្រមសីលធម៌ និងសេចក្តីណែនាំសម្រាប់ដំណើរការនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដោយផ្តោតជាពិសេសទៅលើការធានានូវការចូលរួម និងតម្លាភាព ដោយមានកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ ផ្តល់ការបណ្តុះបណ្តាលដល់មជ្ឈត្តករដំបូង ព្រមទាំងការរៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាប្រតិបត្តិ ដើម្បីគ្រប់គ្រងនិងដំណើរការមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។

-រៀបចំ ចងក្រងនិងបោះពុម្ពសៀវភៅច្បាប់ពាណិជ្ជកម្ម និងឯកសារបណ្តុះបណ្តាលសម្រាប់មហាវិទ្យាល័យ និងរាជបណ្ឌិតសភាវិជ្ជាជីវៈចៅក្រម (ចៅក្រមពាណិជ្ជកម្ម)។

-បន្តបញ្ចប់ការរៀបចំ**ច្បាប់ស្តីពី ការសំគាល់ភូមិសាស្រ្តទំនិញ** (Law on Geographical Indications) ។

-បន្តរៀបចំ**សេចក្តីព្រាងច្បាប់ស្តីពីការការពារការសម្ងាត់ពាណិជ្ជកម្ម និងព័ត៌មានសម្ងាត់** ( Law on the Protection of Trade Secrets and Undisclosed Information ) និងពិនិត្យឡើងវិញទៅលើសេចក្តីព្រាងច្បាប់ជាភាសាខ្មែរឱ្យបានកាន់តែល្អិតល្អន់ កាន់តែស៊ីជម្រៅ និងរាវរកផលប៉ះពាល់ទាំងឡាយណាទៅលើច្បាប់ដែលមានស្រាប់របស់អន្តរក្រសួងនីមួយៗ ឆ្ពោះទៅរកការបញ្ចប់ជាស្ថាពរសេចក្តីព្រាងច្បាប់នេះ។

-សិក្សាស្រាវជ្រាវក្នុងការរៀបចំអនុក្រឹត្យស្តីពី " វិធានការណ៍តាមព្រំដែន " ដែលចែងលម្អិតអំពីនីតិវិធីអនុវត្តការទប់ស្កាត់ការរំលោភបំពានកម្មសិទ្ធិបញ្ញាតាមព្រំដែន ដោយអនុញ្ញាតឱ្យម្ចាស់សិទ្ធិលើម៉ាកប្រកាសនីយប័ត្រតក្កកម្ម និងសិទ្ធិអ្នកនិពន្ធ ដាក់ពាក្យទៅអាជ្ញាធរគយ ឬកាំកុងត្រូលជាមុន ដើម្បីផ្អាកការនាំចូលទំនិញដែលសង្ស័យ ឬមានការរំលោភបំពានកម្មសិទ្ធិបញ្ញា។

-សិក្សាស្រាវជ្រាវក្នុងការរៀបចំអនុក្រឹត្យស្តីពី" ការត្រួតពិនិត្យ ការផលិត ការនាំចូលថាស (CDs) ក្នុងគោលបំណងការពារកុំឱ្យកម្ពុជាក្លាយជាប្រទេសផលិត CDs ក្លែងក្លាយ ក្នុងបរិមាណច្រើន ហើយនាំចេញទៅប្រទេសក្រៅ ។

-ជំរុញ និងសហការជាមួយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ(នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ) ក្នុងការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពី " ការបង្កើតអង្គភាពគ្រប់គ្រងសិទ្ធិរួម " ក្នុងគោលបំណងប្រមូលលាភការដល់អ្នកសំដែង និងអ្នកផលិតហ្វូណូក្រាម ។

-បន្តជំរុញ និងសហការជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការពិនិត្យសេក្តីព្រាងច្បាប់ស្តីពី "**សៀគ្វីរួមបញ្ចូលគ្នា**" ឱ្យបានសមស្របតាមស្តង់ដារអន្តរជាតិ ។

-បន្តរៀបចំប្រកាសរបស់ក្រសួងស្តីពី "ការណែនាំក្នុងការចុះបញ្ជីម៉ាក" ឱ្យបានក្នុងឆ្នាំ ២០១០ នេះ ។

-បន្តរៀបចំប្រកាសរបស់ក្រសួងស្តីពី " ភ្នាក់ងារតំណាងចុះបញ្ជី និងការពារម៉ាកនៅកម្ពុជា " ដើម្បីបង្ហាត់បង្រៀនដល់ភ្នាក់ងារតំណាងទាំងនោះ ឱ្យបានក្នុងឆមាសទី២ឆ្នាំ ២០១០ ។

-បន្តសិក្សាស្រាវជ្រាវនីតិវិធីចុះបញ្ជី និងការការពារម៉ាកល្បី រៀបចំប្រកាសរបស់ក្រសួងអំពីការអនុវត្តន៍ការចុះបញ្ជីម៉ាកល្បីក្នុងឆមាសទី១ឆ្នាំ ២០១០ ។

-បន្តសិក្សាស្រាវជ្រាវ ក្នុងការរៀបចំអនុក្រឹត្យស្តីពី " **ការអនុវត្តន៍ច្បាប់កម្មសិទ្ធិបញ្ញា** " ក្នុងគោលបំណងចាត់វិធានការឱ្យមានប្រសិទ្ធភាពជាងមុន ជាមួយកិច្ចសហការល្អរវាងអង្គភាពពាក់ព័ន្ធ ដូចជា តុលាការ ព្រះរាជអាជ្ញា ប៉ូលីសសេដ្ឋកិច្ច និងនាយកដ្ឋានទទួលបន្ទុកកម្មសិទ្ធិបញ្ញានៃក្រសួងស្ថាប័ន ។

-សហការពិនិត្យច្បាប់ប្រកាសនីយប័ត្រតក្កកម្មម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីអាចទាញយកអត្ថប្រយោជន៍ពីឋានៈប្រទេសក្រីក្រ (LDCs) ចំពោះប្រទេសកម្ពុជា ក្នុងការធ្វើវិសោធនកម្មច្បាប់ខាងលើ និង/ឬ រៀបចំច្បាប់បន្ថែមថ្មីស្តីពី "ការផ្តល់អាជ្ញាប័ណ្ណបញ្ជាសម្រាប់សុខភាពសាធារណៈ" ដែលជាអត្ថប្រយោជន៍ក្នុងការផលិតឱសថទូទៅ "Genericrugs" នៅកម្ពុជា ក៏ដូចជាការនាំចេញ-នាំចូលនូវប្រភេទឱថសខាងលើ ។

-ការសហការពិនិត្យផលចំណេញ និងផលប៉ះពាល់ក្នុងការចូលរួមក្នុងពិធីសារទីក្រុងម៉ាឌ្រីត កិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីត និងសន្ធិសញ្ញាស្តីពី ម៉ាក របស់ប្រទេសសឹង្ហបុរី ។

-សហការកសាងនូវសេចក្តីព្រាងច្បាប់ អនុក្រឹត្យ អំពីល័ក្ខខ័ណ្ឌតម្រូវការបច្ចេកទេសសម្រាប់ម្ហូបអាហារ ដោយអនុម័តជាស្វ័យប្រវត្តិនូវស្តង់ដារក្រមអនុវត្តរបស់ Codex ដែលមានលក្ខណៈត្រូវតាមតម្រូវការចាំបាច់របស់ប្រទេសកម្ពុជា ។

-កសាងនូវសេចក្តីព្រាងអនុក្រឹត្យ អំពីសំភារៈវេចខ្ចប់ដាក់ប៉ះពាល់នឹងម្ហូបអាហារ ។

-សហការកសាងនូវល័ក្ខខ័ណ្ឌកំណត់ផ្នែកច្បាប់ សម្រាប់គុណភាពប្រេងឥន្ធនៈប្រើប្រាស់ក្នុងស្រុក ដោយសម្រួលតាមគោលការណ៏របស់អាស៊ាន ។

-សហការជំរុញការអនុម័តប្រកាសអន្តរក្រសួង អំពីភារកិច្ចនិងការទទួលខុសត្រូវនៃបណ្តាស្ថាប័នពាក់ព័ន្ធនឹងសុវត្ថិភាពម្ហូបអាហារ លើមូលដ្ឋាននៃគំនិតប្រឹក្សារបស់គម្រោងជំនួយ ADB ក្នុងបញ្ហា SPS ។

-រៀបចំដំណើរការមជ្ឈមណ្ឌលផ្តល់ព័តិមានអាសន្ន អំពីការពុលអាហារ ដោយអាហារផលិតក្នុងស្រុក ឬនាំចូល (Rapid Alert System on Food Safety ) ។

-រៀបចំដំណើរការមជ្ឈមណ្ឌលផ្តល់ព័ត៌មាន អំពីផលិតផលប្រើប្រាស់ (Consumer Products) ពុំមានភាពស្មោះត្រង់ ឬពុំមានសុវត្ថិភាពក្នុងបណ្តាញអាស៊ាន។

-ចូលរួមការងារក្នុងរចនាសម្ព័ន្ធផ្នែកស្តង់ដារ និងវាយតម្លៃភាពត្រឹមត្រូវ ជាអាទិ៍ ACCSQ និងក្រុមការងារពាក់ព័ន្ធក្នុងអាស៊ាន ប្រទេសជាដៃគូសន្ទនា ( Dialogue Partners) ក្នុង Codex ឬ WTO ឬក្នុង GMS ឬតំបន់ពាណិជ្ជកម្មសេរីផ្សេងទៀត។

## ❖ *ការធ្វើឱ្យប្រសើរឡើងនូវសកម្មភាពសមាហរណកម្មតំបន់ និងពិភពលោក*

-គ្រោងរៀបចំចរចាជាមួយភាគីវៀតណាម ក្នុងការផ្តល់ភាពអនុគ្រោះពន្ធស្មើសូន្យ(0%) លើមុខទំនិញមួយចំនួនដែលមានប្រភពដើមក្នុងប្រទេសរៀងខ្លួន។

-បន្តជំរុញការស្នើសុំសហគមន៍អឺរ៉ុប ធ្វើការបន្ថយកម្រិតការប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក ពី៤៥%មកនៅត្រឹម២៥% ឱ្យដូចប្រទេសកាដាណា ដែលបានផ្តល់ឱ្យកម្ពុជា។ ព្រមជាមួយនេះ ធ្វើការសិក្សានៅលើបញ្ញត្តិស្តីពីវិធានប្រភពដើមថ្មីរបស់សហគមន៍អឺរ៉ុប និងវិធានប្រភពដើមរបស់បណ្តាប្រទេសដ៏ទៃទៀតក្នុងទ្វីបអឺរ៉ុប និងទ្វីបអាហ្វ្រិក ដើម្បីនាំផលិតផលកម្ពុជា ទៅកាន់ទីផ្សារខាងលើ។

-រៀបចំចរចាជាមួយប្រទេសជាដៃគូ ដើម្បីកែសម្រួលកិច្ចព្រមព្រៀងពាណិជ្ជកម្មណាដែលមិនសមស្របតាមស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន។ ទន្ទឹមនឹងនេះ សហការរៀបចំកិច្ចព្រមព្រៀងពាណិជ្ជកម្មជាមួយបណ្តាប្រទេសនានា សំដៅគ្រប់គ្រងការនាំចេញ ព្រមទាំងទាក់ទាញវិនិយោគិន មកវិនិយោគ និងធ្វើពាណិជ្ជកម្មនៅកម្ពុជា។

-រៀបចំបញ្ជីមុខទំនិញស្នើសុំភាពអនុគ្រោះពាណិជ្ជកម្ម សម្រាប់ផ្ញើជូនទៅសហព័ន្ធរុស្ស៊ី ដើម្បីសម្រេចផ្តល់ជូនព្រះរាជាណាចក្រកម្ពុជា។

-បន្តសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តការសន្យានិងកាតព្វកិច្ចនានាក្រោមក្របខ័ណ្ឌអនុតំបន់ និងតំបន់ ព្រមទាំងធ្វើការចរចាក្នុងក្របខ័ណ្ឌអនុតំបន់ និងតំបន់ ដើម្បីធ្វើយ៉ាងណាឱ្យលក្ខខ័ណ្ឌនៃប្រភពដើមទំនិញរបស់កម្ពុជា មានភាពល្អប្រសើរសម្រាប់ការនាំចេញ។

-យកចិត្តទុកដាក់ថែរក្សាការពារភាពអនុគ្រោះពន្ធ MFN/GSP ដែលទទួលបានតាមរយៈការកសាងទំនាក់ទំនងល្អជាមួយមន្ត្រីគយប្រទេសនាំចូល ក្នុងការបំភ្លឺរាល់ចម្ងល់នានា ឬចូលរួមបេសកកម្មត្រួតពិនិត្យមូលដ្ឋានផលិតកម្ម។

-ណែនាំដល់ក្រុមហ៊ុនកាត់ដេរ ដើម្បីជំរុញការនាំចេញសំលៀកបំពាក់ទៅកាន់ប្រទេសកាណាដា ក្នុងពេលដែលប្រទេសកម្ពុជាទទួលបាន DUTY FREE និង QUOTA FREE ដោយគោរពឱ្យបានត្រឹមត្រូវតាមវិធានប្រភពដើមរបស់គេ ដែលបានណែនាំក្នុងអង្គសិក្ខាសាលាកន្លងមក។

-ជំរុញការអនុវត្តឱ្យមានសន្ទុះទៅមុខនូវកម្មវិធីកាត់បន្ថយពន្ធគយរួម សម្រាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន (CEPT for AFTA) ការលប់បំបាត់របាំងមិនមែនពន្ធគយ ការពង្រឹងគុណភាពទំនិញ និងសេវាឱ្យសមស្របតាមស្តង់ដារបច្ចេកទេស និងអនាម័យ-ភូតគាមអនាម័យ។

-សហការគ្រប់ស្ថាប័នពាក់ព័ន្ធ ចូលរួមយ៉ាងសកម្មក្នុងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចក្នុងតំបន់នានា ដូចជាមហាអនុតំបន់មេគង្គ យុទ្ធសាស្ត្រសហប្រតិបត្តិការសេដ្ឋកិច្ចរវាងកម្ពុជា ឡាវ ថៃ មីយ៉ាន់ម៉ា វៀតណាម ក៏ដូចជាកិច្ចសហប្រតិបត្តិការជាទ្វេភាគីផងដែរ និងធ្វើការអភិវឌ្ឍតំបន់ត្រីកោណ កម្ពុជា ឡាវ វៀតណាម។

-ត្រៀមអនុវត្តនីការ សាងសង់ផ្សារគំរូព្រំដែនកម្ពុជា-វៀតណាម ស្ថិតនៅភូមិ ដាកណ្តាល ឃុំដា ស្រុកមេមត់ ខេត្តកំពង់ចាម និងរៀបចំប្លង់មេ និងពន្លឿនការសាងសង់ផ្សារពាណិជ្ជកម្ម តាមព្រំដែនកម្ពុជា-វៀតណាម ។

❖ ***បន្តការអនុវត្តន៍យុទ្ធសាស្ត្រអភិក្រមគ្របដណ្តប់ទូទាំងវិស័យពាណិជ្ជកម្ម ( Trade SWAp )***

-រៀបចំរចនាសម្ព័ន្ធផ្ទៃក្នុងឱ្យសមស្របនឹងការងារ ដោយធានាបានតម្លាភាពគណនេយ្យភាព និងប្រសិទ្ធភាព ការងារទៅតាមស្តង់ដារដៃគូរអភិវឌ្ឍន៍ធនាគារពិភពលោក និងក្រសួងពាណិជ្ជកម្ម ។

-ផ្សព្វផ្សាយព័ត៌មានអំពីតម្លាភាពអនុវត្តគម្រោង និង នីតិវិធីទាំងឡាយតាមរយៈវេបសាយរបស់គម្រោង ។

-ទំនាក់ទំនងជាមួយស្ថាប័នអនុវត្តគម្រោង ដើម្បីសម្របសម្រួលការអនុវត្តន៍គម្រោងឱ្យបានរលូន និងទាន់ពេលវេលា ។

-បង្កើនប្រសិទ្ធភាពគ្រប់គ្រងគម្រោង ដើម្បីធានាមិនឱ្យមានភាពថ្លស់ធ្លោយដោយប្រការណាមួយ និងដើម្បីធានាឱ្យមានព័ត៌មានគ្រប់គ្រាន់ ទាន់ពេលវេលាសម្រាប់ថ្នាក់ដឹកនាំក្រសួង ។

-រៀបចំសម្រួល តាមការចាំបាច់នូវផែនការអនុវត្តន៍ការងារឆ្នាំ២០១០ រាប់ទាំងផែនការថវិកា ផែនការលទ្ធកម្ម ផែនការបណ្តុះបណ្តាល ផែនការការងារត្រួតពិនិត្យវាយតម្លៃ សម្រេចឱ្យបានទាន់ពេលកំណត់ចុងក្រោយ ។

-ត្រៀមរៀបចំកិច្ចប្រជុំដែលមានក្នុងគម្រោងរួចហើយ ( កិច្ចប្រជុំអនុគណៈកម្មការអភិវឌ្ឍន៍ពាណិជ្ជនិង ត្រៀមរៀបចំកម្មវិធីវិនិយោគទាក់ទងពាណិជ្ជកម្ម ( ID-TRI) កិច្ចប្រជុំការងាររបស់អភិក្រមគ្របដណ្តប់វិស័យពាណិជ្ជកម្ម ។

-បន្តកិច្ចការលេខាធិការដ្ឋានសម្របសម្រួលការងារអភិក្រមគ្របដណ្តប់វិស័យពាណិជ្ជកម្ម ការងារ TDSP ការងារ EIF និងគម្រោងជំនួយបច្ចេកទេសផ្សេងទៀត ។

## IV~សេចក្តីសន្និដ្ឋាន

ដោយបច្ចុប្បន្ននេះ កម្ពុជាកំពុងស្ថិតនៅក្នុងស្ថានភាពប្រឈមនឹងវិបត្តិកលិយុគនៃសេដ្ឋកិច្ចសកល ដែលមិនទាន់អាចប៉ាន់ប្រមាណបាននូវចរន្តនៃការថមថយឥទ្ធិពលរបស់វានៅឡើយនោះ ក្រសួងពាណិជ្ជកម្មពិតជាត្រូវរែងពុន និងរ៉ាប់រងបេសកកម្មដ៏ធ្ងន់ធ្ងរ ក្នុងការចូលរួមជួយទ្រោលស្ថានការណ៍សេដ្ឋកិច្ចមិនឱ្យប្រេះស្រាំខូចខាតពីការប៉ះទង្គិចនៃរលកវិបត្តិហិរញ្ញវត្ថុ ។ ការលះបង់កម្លាំងកាយចិត្ត ប្រាជ្ញា ស្មារតីរបស់មន្ត្រីរាជការក្រសួងពាណិជ្ជកម្ម ពិតជាអាចវាស់វែងបាន តាមរយៈការបញ្ចេញឱ្យឃើញយ៉ាងច្បាស់ក្រឡែតនូវគុណសម្បត្តិជាស្នាដៃលើច្រើនវិស័យ ក្នុងបេសកកម្មបម្រើជាតិ រាជរដ្ឋាភិបាល និងប្រជាពលរដ្ឋ ។ ច្បាស់ណាស់ថា ការធ្វើសមាហរណកម្មសេដ្ឋកិច្ចទៅក្នុងសេដ្ឋកិច្ចពិភពលោក ការថែរក្សា និងអភិវឌ្ឍន៍ទីផ្សារ ការអនុវត្តកិច្ចសម្រួលពាណិជ្ជកម្ម ការបង្កើនកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទ្វេភាគី ពហុភាគីជាមួយបណ្តាប្រទេសអភិវឌ្ឍន៍នានា ការចូលរួមអនុវត្តអភិបាលកិច្ច និងលើកកំពស់គុណភាពសេវាសាធារណៈ ដោយបើកផ្លូវឱ្យមានការចូលរួមពីផ្នែកឯកជនក្នុងការពិនិត្យតាមដានចរាចរលិខិតស្នាម និងប្រព័ន្ធឆ្លើយឆ្លងព័ត៌មានឯកសារ ការចាត់វិធានការកែលម្អបរិស្ថានទីផ្សារ វិនិយោគ និងលុបបំបាត់អំពើក្លែងបន្លំ អំពើប្រកួតប្រជែងមិនស្មោះត្រង់ ទាំងអស់នេះពិតជាកត្តាចម្បងដែលនាំឱ្យយើងសម្រេចបាននូវទិន្នន័យនីហរ័ណ អាហរ័ណ ដែលមានតុល្យភាពល្អបង្គួរ បើប្រៀបនឹងឆ្នាំមុន ជួយទ្រទ្រង់ផលិតកម្មទំនិញអាចគេចចេញពីវិបត្តិគ្មានទីផ្សារ ហើយនៅតែ

ភិបាល និងប្រជាពលរដ្ឋ ដើម្បីជំនះផលវិបាកទាំងឡាយ ក្នុងការជំរុញឱ្យស្ថានភាពសេដ្ឋកិច្ច ជីវភាពសង្គម វិលទៅរកវឌ្ឍនៈភាព វិបុលភាព ដែលប្រការនេះ ទាមទារឱ្យមន្ត្រីក្រសួងពាណិជ្ជកម្មសម្លឹងឱ្យបានវែង និងស៊ីជម្រៅទៅលើបទដ្ឋានសូចនាករដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រ ៥ឆ្នាំរបស់ក្រសួង ហើយថ្លឹងថ្លែងវិភាគបញ្ហាដែលចាត់ទុកថា ជាបញ្ហាប្រឈម ព្រមទាំងគប្បីពិនិត្យឡើងវិញបទពិសោធន៍នៃការអនុវត្តភារកិច្ចក្នុងបណ្តាឆ្នាំមុនៗ វះកាត់រាល់ភាពអសកម្ម ហើយជ្រើសយកវិធានការមានប្រយោជន៍នានា មកចាត់ចែងអនុវត្តតាមជំហានៗឱ្យចេញជាទិន្នផលការងារ ជាក់ស្តែង ។

ក្រសួងពាណិជ្ជកម្ម បន្តការប្តេជ្ញាចិត្តខ្ពស់ និងប្រតិបត្តិឱ្យខាងតែបាននូវ **កម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២របស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប៉ិនប្រសប់ ប្រកបដោយបញ្ញាញាណរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាពការងារ រួមចំណែកកាត់បន្ថយភាពក្រីក្រជូនប្រជាពលរដ្ឋកម្ពុជា**។ ដើម្បីសម្រេចបាននូវឆន្ទៈនេះ ក្រសួងពាណិជ្ជកម្ម នឹងប្រមែប្រមូលកម្លាំងសាមគ្គីភាពក្នុងជួរមន្ត្រីរាជការ កសាង និងពង្រឹកសមត្ថភាពស្ថាប័ន អភិវឌ្ឍន៍ធនធានមនុស្ស កសាងមូលដ្ឋានសម្ភារៈ បច្ចេកទេសឱ្យឆ្លើយតបទៅនឹងសំណូមពរនៃការបំពេញតួនាទី ជាប្រេង**រំអិលសម្រាប់ឱ្យម៉ាស៊ីននៃវិស័យផ្សេងៗអាចដំណើរការបាន** ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១០

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

រដ្ឋមន្ត្រីស្តីទី

គឹម_ស៊ីថន

## Table 1: តារាងមុខទំនិញនាំចេញទៅកាន់ទីផ្សារសំខាន់ៗក្នុងពិភពលោក ( ២០០៩)

| No. | DESTINATION | DESCRIPTION | UNIT | 2009 | | 2008 | | VARIATION | |
|---|---|---|---|---|---|---|---|---|---|
| | | | | QTY | AMOUNT (USD) | QTY | AMOUNT (USD) | AMOUNT (USD) | PERCENTAGE |
| **GRAND TOTAL IN VALUE:** | | | | - | **2,669,833,496.39** | - | **3,158,162,652.06** | **(488,329,155.67)** | **-15.46%** |
| 1 | TOTAL | Garments | DOZ | 75,045,434 | 2,389,157,308.95 | 85,618,890 | 2,942,753,411.28 | (553,596,102.33) | -18.81% |
| | | Textiles | N/A | - | 29,407,073.69 | - | 38,503,015.40 | (9,095,941.71) | -23.62% |
| | | Shoes | PRS | 22,801,543 | 110,247,623.49 | 20,915,680 | 88,394,435.11 | 21,853,188.38 | 24.72% |
| | | Others | N/A | - | 141,021,490.26 | - | 88,511,790.27 | 52,509,699.99 | 59.33% |
| 2 | **TOTAL USA** | | | - | **1,518,748,890.62** | - | **1,990,241,131.35** | **(471,492,240.73)** | **-23.69%** |
| | USA | Garments | DOZ | 52,312,209 | 1,489,008,769.50 | 64,267,634 | 1,969,162,760.58 | (480,153,991.08) | -24.38% |
| | | Textiles | N/A | - | 18,538,693.26 | - | 18,780,537.30 | (241,844.04) | -1.29% |
| | | Shoes | PRS | 397,829 | 6,932,254.62 | 154,052 | 1,830,525.47 | 5,101,729.15 | 278.70% |
| | | Others | N/A | - | 4,269,173.24 | - | 467,308.00 | 3,801,865.24 | 813.57% |
| 3 | **TOTAL EU** | | | - | **718,878,525.18** | - | **786,961,457.00** | **(68,082,931.82)** | **-8.65%** |
| | EU | Garments | DOZ | 14,436,179 | 574,110,919.49 | 14,002,716 | 644,201,730.59 | (70,090,811.10) | -10.88% |
| | | Textiles | N/A | - | 3,792,417.99 | - | 14,420,899.56 | (10,628,481.57) | -73.70% |
| | | Shoes | PRS | 16,525,182 | 67,911,075.80 | 15,288,323 | 62,108,684.72 | 5,802,391.08 | 9.34% |
| | | Others | N/A | - | 73,064,111.90 | - | 66,230,142.13 | 6,833,969.77 | 10.32% |
| 4 | **TOTAL CANADA** | | | - | **198,009,020.68** | - | **202,916,765.92** | **(4,907,745.24)** | **-2.42%** |
| | CANADA | Garments | DOZ | 5,432,941 | 192,616,251.22 | 5,054,735 | 195,934,249.21 | (3,317,997.99) | -1.69% |
| | | Textiles | N/A | - | 2,440,763.34 | - | 3,017,223.31 | (576,459.97) | -19.11% |
| | | Shoes | PRS | 138,369 | 1,249,191.85 | 46,658 | 258,613.73 | 990,578.12 | 383.03% |
| | | Others | N/A | - | 1,702,814.27 | - | 3,706,679.67 | (2,003,865.40) | -54.06% |
| 5 | **OTHER MARKETS** | | | - | **234,197,059.91** | - | **178,043,297.79** | **56,153,762.12** | **31.54%** |
